# មូហាំម៉ាត់

## ជាគំរូដ៏ល្អឥតខ្ចោះ

និពន្ធដោយ៖ លោកបណ្ឌិត កាមីលីន ចាមីលីន
ប្រែសម្រួលដោយ៖ សុង ស៊ីប៉

ឈ្មោះសៀវភៅ៖ មូហាំម៉ាត់ជាគំរូដ៏ល្អឥតខ្ចោះ

និពន្ធដោយ៖ លោកបណ្ឌិត កាមីលីន ចាមីលីន

ប្រែសម្រួលដោយ៖ សុង ស៊ីប៊ែ

ត្រួតពិនិត្យដោយ៖ ហ៊ីម ម៉ើសៀត

ឯល យ៉ាក់កូប

លី តឹមឡាង

យ៉េស ស៊េរីហ្វះ

បោះពុម្ពឆ្នាំ៖ ២០២៤

មតិយោបល់៖ 016517221

song.sibair@gmail.com

---

ជាការពិតណាស់!

ពួកអ្នកមានអ្នកនាំសាររបស់ **អល់ឡោះ**

**(ព្យាការីមូហាំម៉ាត់)**

ដែលជាគំរូដ៏ល្អសម្រាប់ពួកអ្នក

គួរអាន អាល់អះហ្សាប ៣៣ : ២១

# មាតិកា


១.អារម្ភកថាអ្នកប្រែសម្រួល ១

២.អារម្ភកថាអ្នកនិពន្ធ ៣

៣.មូហាំម៉ាត់ ( សូមសុខសន្តិភាពកើតមានដល់លោក ) ៥

៤.បុគ្គលគំរូ ៩

៥.បុគ្គលដែលគេទន្ទឹងរង់ចាំមកជាយូរ ១៣

៦.ពូជពង្សដ៏ថ្លៃថ្នូរ ១៥

៧.ទឹកដីកំណើតជាទីស្រលាញ់ ២១

៨.ពីក្មេងកំព្រាដែលស្រលាញ់ និងយល់ចិត្តក្មេងកំព្រាដូចគ្នា ២៥

៩.បុគ្គលដែលមិនធ្លាប់ភូតភរកុហក ២៧

១០.បុរសដែលស្ថិតក្រោមការការពារពីអល់ឡោះជាម្ចាស់ ៣០

១១.អាថ៌កំបាំងដែលទឹកដីអារ៉ាប់ត្រូវបានជ្រើសរើសដាក់ន្លែង
សម្រាប់ការបញ្ចុះវិវរណៈ(វ៉ាហ៊ី) ៣៥

១២.មូហាំម៉ាត់អ្នកនាំសារនៃអល់ឡោះ ៣៨

១៣.អ្នកនាំសារដ៏ថ្លៃថ្លា ៤២

១៤.គម្ពីរគួរអាន គឺជាអព្ភូតហេតុ ( មួកជីសាត់ ) ៤៥

១៥.បុគ្គលពោរពេញដោយជំនាញ និងទេព្យកោសល្យចម្រុះ ៤៩

១៦.បុគ្គលដែលមានភាពពេញលេញជាមនុស្សជាតិ ៥២

១៧.បុគ្គលដែលគេស្គាល់ថាមានចិត្តសប្បុរសបំផុត ៥៧

១៨.បុគ្គលដែលមិនចេះនឿយហត់ក្នុងការជំរុញលើកទឹកចិត្ត
អ្នកដទៃឱ្យប្រព្រឹត្តអំពើល្អ ៦២
១៩.បុគ្គលដែលគ្មាននរណាអាចប្រៀបផ្ទឹមបានឡើយ
ក្នុងការអភ័យទោសដល់អ្នកដទៃ ៦៥
២០.ការទទួលទានរបស់ព្យាការីមូហាំម៉ាត់ ៧២
២១.ការស្លៀកពាក់របស់ព្យាការីមូហាំម៉ាត់ ៧៧
២២.ទម្លាប់នៃការសម្រាន្តរបស់ព្យាការីមូហាំម៉ាត់ ៨២
២៣.គ្រាដ៏រីករាយ និងសោកសៅរបស់បុគ្គល
ជាទីស្រលាញ់នៃយើង ៨៦
២៤.ព្យាការីមូហាំម៉ាត់ ជាមួយជនពុតត្បុត ៩៤
២៥.ព្យាការីមូហាំម៉ាត់ ជាមួយសហការី ១០២
២៦.ព្យាការីមូហាំម៉ាត់ ជាមួយស្ត្រី ១០៩
២៧.ព្យាការីមូហាំម៉ាត់ ជាមួយកុមារ ១២១
២៨.ព្យាការីមូហាំម៉ាត់ ជាមួយអ្នកជិតខាង ១២៩
២៩.ព្យាការីមូហាំម៉ាត់ ក្នុងនាមជាឪពុក ១៣៥
៣០.ប្រសិនបើយើងបាននៅក្បែរលោក… ១៤២

# អារម្ភកថាអ្នកប្រែសម្រួល

## ក្នុងព្រះនាមនៃព្រះអល់ឡោះ ទ្រង់ដ៏សប្បុរស ដ៏មេត្តាករុណា

រាល់ការសរសើរតម្កើង សម្រាប់អល់ឡោះជាម្ចាស់តែមួយអង្គគត់ សូមព្រះជាម្ចាស់ប្រទាននូវពរជ័យ និងសុខសន្តិភាពពេញលេញដល់ព្យាការីមូហាំម៉ាត់ ព្រមទាំងក្រុមគ្រួសារ ហើយនិងសហាការីរបស់លោក ក៏ដូចជាអ្នកទាំងឡាយណា ដែលដើរតាមមាគ៌ារបស់លោករហូតដល់ថ្ងៃបរលោក។

អ្នកប្រាជ្ញមូស្លីមពីមួយជំនាន់ទៅមួយជំនាន់ បានខិតខំយកចិត្តទុកដាក់ក្នុងការសរសេរចងក្រង សង្ខេប និងប្រែសម្រួលស្ទើរគ្រប់ភាសាទាំងអស់ អំពីដំណើរជីវិត ឬជីវប្រវត្តិរបស់ព្យាការីមូហាំម៉ាត់ក្នុងទិដ្ឋភាពផ្សេងៗគ្នា ដើម្បីឱ្យមនុស្សគ្រប់ជាតិសាសន៍បានយល់ និងស្គាល់អំពីព្យាការីមូហាំម៉ាត់ឱ្យកាន់តែច្បាស់។

ហេតុផលដែលជំរុញឱ្យខ្ញុំបកប្រែសៀវភៅមួយក្បាលនេះ គឺដោយសារតែសង្កេតឃើញថា សៀវភៅនេះ បានលើកឡើងនូវរឿងរ៉ាវដ៏សំខាន់ៗជាច្រើន អំពីភាពជាគំរូដ៏ល្អឯក នៃជីវិតរបស់ព្យាការីមូហាំម៉ាត់ ដែលយើងគួរតែបានស្គាល់ និងយកធ្វើជាគំរូ។ ម្យ៉ាងទៀតសៀវភៅនេះ ក៏សមល្មមសម្រាប់បងប្អូនមិត្តអ្នកអាន មិនច្រើនពេក ហើយពាក្យពេចន៍ដែលប្រើក៏មិនពិបាកយល់ផងដែរ។

ខ្ញុំសូមអភ័យទោសទុកជាមុន ប្រសិនបើមានចំណុចខុសឆ្គង ឬការប្រើប្រាស់ពាក្យពេចន៍មិនសមរម្យ ដោយអចេតនាត្រង់ចំណុចណាមួយ។

សូមព្រះជាម្ចាស់ប្រទាននូវផលបុណ្យដល់អ្នកទាំងឡាយណា ដែលតែងតែយកចិត្តទុកដាក់ការពារកិត្តិយសរបស់លោក និងប្រកាន់ខ្ជាប់តាមមាគ៌ារបស់លោក។

ជាចុងក្រោយ ខ្ញុំសូមទូអាបួងសួង ទៅកាន់អល់ឡោះជាម្ចាស់ សូមទ្រង់មេត្តាជួយតម្រង់ចិត្តរបស់យើងទាំងអស់គ្នា ឱ្យមានភាពនឹងនរ និងរឹងមាំ នៅលើសាសនារបស់ទ្រង់ជារៀងរហូតតទៅ ហើយសូមទ្រង់មេត្តាប្រទាននូវឋានសួគ៌ ដែលជាទីប្រាថ្នានៃយើងគ្រប់គ្នាផងចុះ។ **អាមីុន!**

**ពីខ្ញុំ សុង ស៊ីប៉ិ**

# អារម្ភកថាអ្នកនិពន្ធ

សូមសរសើរតម្កើងអល់ឡោះជាម្ចាស់ ដែលគ្រប់គ្រងពិភពទាំងអស់ សូមសន្តិភាព និងពរជ័យនៃព្រះមានដល់ព្យាការីមូហាំម៉ាត់ ដែលជាអ្នកនាំសារដ៏ជាទីទុកចិត្តនៃទ្រង់ ក៏ដូចជា គ្រួសារ សហការី និងអ្នកដែលដើរតាមមាគ៌ារបស់លោកទាំងឡាយ។

ខ្ញុំសូមអរព្រះគុណដល់អល់ឡោះជាម្ចាស់ចំពោះសៀវភៅមួយក្បាលនេះ ដែលជាសេចក្តីសង្ខេប អំពីបុរសម្នាក់ដែលជាទីស្រលាញ់នៃអ្នកមូស្លីមទូទៅ ត្រូវបានបោះពុម្ពដោយជោគជ័យ។ ការពិតសៀវភៅមួយនេះ កើតចេញពីការកត់ត្រានៃការបង្រៀនមួយរបស់ខ្ញុំ ដែលក្រោយមកក៏បានរៀបចំ និងកែសម្រួលសម្រាប់ធ្វើការបោះពុម្ពផ្សាយ។

សៀវភៅនេះ មិនមែនជាសៀវភៅដែលនិយាយលម្អិតអំពីព្រឹត្តិការណ៍ទាំងអស់នៅក្នុងជីវប្រវត្តិរបស់ព្យាការី និងដំណើរជីវិតរបស់លោកទាំងមូលនោះទេ។ ប៉ុន្តែវាគ្រាន់តែជាកូនសោរដើម្បីបើកឱ្យយើងបានដឹងអំពីប្រវត្តិខ្លះៗ ក៏ដូចជាគុណធម៌ សីលធម៌ ទំនាក់ទំនងរបស់លោកជាមួយនឹងមនុស្សជុំវិញ និងទិដ្ឋភាពផ្សេងៗ នៃជីវិតរបស់លោកក្នុងនាមជាមនុស្សធម្មតា និងក្នុងនាមជាអ្នកនាំសាររបស់អល់ឡោះ។ ប្រសិនបើមិនបានយល់ដឹងពីបុគ្គលិកលក្ខណៈដ៏បវររបស់លោកទេនោះ វាពិតជាពិបាកបណ្តុះនូវសេចក្តីស្រលាញ់ចំពោះលោកនៅក្នុងបេះដូងរបស់យើងជាមិនខាន។ ហើយបើគ្មានសេចក្តីស្រលាញ់ចំពោះព្យាការីនៅក្នុងបេះដូងទេ វាក៏នឹងពិបាកអនុវត្តតាមលោកផងដែរ។ ដូចសុភាសិតមួយបានលើកឡើងថា៖ **[បើមិនបានស្គាល់ផង ឱ្យស្រលាញ់ម្តេចនឹងកើតទៅ]**។

សៀវភៅមួយក្បាលនេះ ប្រើប្រាស់ពាក្យពេចន៍សាមញ្ញបំផុត ត្រង់ៗ ងាយយល់ ស័ក្តិសមសម្រាប់មិត្តអ្នកអានគ្រប់វ័យ និងគ្រប់មជ្ឈដ្ឋាន ជាពិសេស សម្រាប់អ្នកដែលចង់ស្គាល់ពីបុគ្គលិកលក្ខណៈរបស់ព្យាការីមូហាំម៉ាត់តែម្តង។

សូមអល់ឡោះប្រទាននូវពរជ័យលើកិច្ចប្រឹងប្រែងដ៏តូចមួយនេះ និងផ្តល់ជាប្រយោជន៍ដល់ពួកយើងទាំងអស់គ្នាផងចុះ។

អល់ឡោះ បានមានព្រះបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

ពិតប្រាកដណាស់ យើងបានបញ្ជូនអ្នក(មូហាំម៉ាត់) ក្នុងនាមជាសាក្សី ក៏ដូចជាផ្តល់ដំណឹងរីករាយ និងព្រមានដាស់តឿន។ដើម្បីឱ្យពួកអ្នក(មនុស្សលោក)មានជំនឿលើអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់(មូហាំម៉ាត់) និងជួយជ្រោមជ្រែង ហើយផ្តល់កិត្តិយសដល់លោក(មូហាំម៉ាត់) ហើយនិងសរសើរតម្កើងទ្រង់ទាំងព្រឹកល្ងាច។

*គួរអាន អាល់ហ្វាត់ហ៍ ៤៨: ៨-៩*

កាមីលីន ចាមីលីន

២០ កុម្ភៈ ២០២០

មូហាំម៉ាត់

សូមសុខសន្តិភាព

កើតមានដល់លោក

មូហាំម៉ាត់ ជាបុគ្គលដែលគេតែងតែធ្លាប់បានឮ និងបានស្គាល់រួចមកហើយ ទាំងអ្នកដែលរស់នៅលើផែនដី ក៏ដូចជាអ្នកដែលនៅលើមេឃផងដែរ។ ឈ្មោះដ៏ពិសិដ្ឋរបស់លោក ត្រូវបានឮពេញត្រចៀក និងត្រូវបានគេលើកយកមកនិយាយជាញឹកញាប់។ បុរសម្នាក់នេះ មានអ្នកដើរតាមរាប់លាននាក់នៅជុំវិញពិភពលោក បើគិតចាប់តាំងពីពេលដែលអល់ឡោះបានតែងតាំងរូបលោកធ្វើជា ព្យាការីរហូតមកដល់បច្ចុប្បន្ននេះ។

ឈ្មោះរបស់លោកតែងតែត្រូវបានគេប្រើជាចំណុចសំខាន់នៃជម្លោះនៅក្នុងសមរភូមិ ឬការជជែកដេញដោលជារឿយៗ ទាំងក្នុងចំណោមអ្នកដែលដើរតាមលោក និងអ្នកដែលរារាំងលោក។ ហើយខណៈពេលដែលមានមនុស្សជាច្រើនក្នុងចំណោមអ្នកកាន់សាសនាអ៊ីស្លាម ដែលនិយាយអំពីបុរសដ៏មានកិត្តិយសម្នាក់នេះ ក៏មានអ្នកខ្លះឈានទៅដល់ការលើកតម្កើងលោកខ្ពស់ហួសកម្រិត ដែលមិនអាចទទួលយកបាន រីឯអ្នកខ្លះទៀត បែរជាប្រឹងបន្ទាបនូវតម្លៃរបស់លោក ឱ្យធ្លាក់ដល់ក្រោមទៅវិញ។

ទោះយ៉ាងណាក៏ដោយសព្វថ្ងៃនេះ មានមនុស្សជាច្រើនដែលអះអាងថាជាប្រជាជាតិ(អ៊ូម៉ាត់)របស់លោក ប៉ុន្តែពួកគេមិនបានស្គាល់លោកច្បាស់នោះទេ។ វាស្ទើរតែគ្រប់រឿងរ៉ាវអំពីជីវិតរបស់លោក ដែលពួកគេមិនបានដឹងសូម្បីបន្តិចសោះឡើយ។ ម្យ៉ាងវិញទៀត ក្នុងចំណោមអ្នកមិនមែនមូស្លីមមួយចំនួន ពួកគាត់ក៏បានបើកចិត្តទូលាយ និយាយអំពីលោក ប្រកបដោយក្រមសីលធម៌។ ហើយក៏មានអ្នកដែលនិយាយប្រមាថ និងតែងតែមានទស្សនៈអវិជ្ជមានមកលើលោកផងដែរ។ ក្នុងពេលជាមួយគ្នានេះ ក៏មានអ្នកមិនមែនមូស្លីមជាច្រើន ដែលស្គាល់ឈ្មោះ មូហាំម៉ាត់ ប៉ុន្តែមិនបានដឹងពីការពិតនៃលោក នៅពីក្រោយឈ្មោះនេះនោះឡើយ។

ភាពអវិជ្ជាទាក់ទងនឹងបុគ្គលម្នាក់នេះ បានធ្វើឱ្យមនុស្សជាច្រើនជុំវិញពិភពលោកទទួលបានពត៌មានក្លែងក្លាយ ឬការពណ៌នាមិនត្រឹមត្រូវអំពីលោក។ អ្នកខ្លះដកស្រង់តែចំណុចខ្លីមួយ ឬពីរប៉ុណ្ណោះ អំពីជីវិតរបស់មូហាំម៉ាត់ដោយមិនយល់ពី

បរិបទនោះឡើយ។ ខណៈពេលដែលអ្នកផ្សេងទៀតគ្រាន់តែដកស្រង់យកមក ដោយមិនបានពិនិត្យអំពីភាពត្រឹមត្រូវនៃរឿងរ៉ាវទាំងនោះឡើយ។ ហើយក៏មានអ្នក ដែលយល់ខុសចំពោះបុរសដ៏អស្ចារ្យម្នាក់នេះ ដោយយោងទៅតាមទស្សនៈរបស់ អ្នកដែលប្រឆាំងនឹងលោក។ ហើយកាន់តែធ្ងន់ធ្ងរជាងនេះទៅទៀត គឺទាញការ សន្និដ្ឋានអំពីលោក ដោយផ្អែកលើការប្រព្រឹត្តិរបស់អ្នកមូស្លីមសព្វថ្ងៃនេះ ដែលពួក គេភាគច្រើនបានវង្វេងឆ្ងាយពីការណែនាំរបស់លោក។

បុរសដ៏មានកិត្តិយសម្នាក់នេះ ជាបុគ្គលដែលគ្មានមុខតំណែងលោកិយ អ្វីនោះឡើយ។ ទោះបីជារូបលោកត្រូវបានគេចោទថា ជាស្ដេចដ៏ត្រចះត្រចង់ មាន ទ្រព្យសម្បត្តិដ៏ស្ដុកស្ដម្ភ ឬជាអ្នកគ្រប់គ្រងដ៏មានឥទ្ធិពល ដែលបានក្ដោបក្ដាប់ ពិភពលោកដោយការធ្វើសង្គ្រាម និងបង្ខំមនុស្សឱ្យទទួលយកសាសនាអ៊ីស្លាម ក៏ដោយ។ តែការពិតទៅ បុរសម្នាក់នេះគឺគ្រាន់តែជាអ្នកនាំសាររបស់អល់ឡោះ ជាម្ចាស់តែប៉ុណ្ណោះ។ ដូចដែលព្រះជាម្ចាស់ បានពិពណ៌នាអំពីលោក ដោយបាន មានព្រះបន្ទូលថា៖ **(RAHMATAN LIL ALAMIN)** ដែលមានន័យថា៖
**(លោកជាពរជ័យដ៏អស្ចារ្យសម្រាប់សកលលោកទាំងមូល)**។

មិនតែប៉ុណ្ណោះ បុរសដែលយើងកំពុងតែនិយាយម្នាក់នេះ ក៏មិនមែនជា អ្នកនយោបាយដែលព្យាយាមបញ្ចូលមនោគមវិជ្ជារបស់លោកជាសាធារណៈ ដើម្បី ទទួលបានឥទ្ធិពល ឬអំណាចនោះដែរ។ ប៉ុន្តែបុរសម្នាក់នេះ ត្រូវបានគេស្រលាញ់ យ៉ាងខ្លាំង ទាំងអ្នកដែលបានឃើញលោក ឬក៏មិនបានឃើញលោកក៏ដោយ។ លោក ជាបុរសម្នាក់ដែលគេតែងតែស្រលាញ់ និងនឹកនាដល់ ទោះបីជាលោកបានចាកចេញ ទៅអស់រយៈពេលជាង ១៤០០ ឆ្នាំទៅហើយក៏ដោយ។

លោកក៏ត្រូវបានគេស្គាល់ផងដែរថាជាអនក្ខរជន(មនុស្សដែលមិនចេះ អាន និងសរសេរ)។ ដូច្នេះលោកមិនអាចបង្កើតស្នាដៃនិពន្ធ ឬបកស្រាយ កំណាព្យពាក្យចួន ដើម្បទាក់ទាញអារម្មណ៍អ្នកស្ដាប់នោះឡើយ។ ផ្ទុយទៅវិញ អ្វីដែលលោកបាននិយាយ ឬបកស្រាយ គឺផ្អែកលើវិវរណៈ(វ៉ាហ៊ី)តែប៉ុណ្ណោះ។

ដូចដែលអល់ឡោះបានមានព្រះបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

**លោក (មូហាំម៉ាត់) មិនបាននិយាយតាមទំនើងចិត្តនោះឡើយ ប៉ុន្តែពាក្យសម្តីដែលលោកនិយាយ គឺគ្មានអ្វីក្រៅពីវិវរណៈ(វ៉ាហ៊ី) ដែលត្រូវបានបើកសម្តែងនោះទេ។**

*គួរអាន អាន់ណាជ្មុ ៥៣ : ៣-៤*

បុរសម្នាក់នេះហើយ ដែលជាទីស្រលាញ់នៃអល់ឡោះជាម្ចាស់ និងជាគំរូដ៏គួរឱ្យគោរព សម្រាប់ប្រជាជាតិមូស្លីមគ្រប់រូប។

# បុគ្គលគំរូ

មូហាំម៉ាត់ គឺជាបុគ្គលដែលអល់ឡោះបានតែងតាំងធ្វើជាអ្នកនាំសាររបស់ទ្រង់។ លោកគឺជាគំរូសម្រាប់យើងទាំងអស់គ្នាដើម្បីយកតម្រាប់តាម។ មិនមែនត្រឹមតែក្នុងកិច្ចការសាសនា ឬការគោរពសក្ការៈប៉ុណ្ណោះទេ ប៉ុន្តែគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរស់នៅរបស់យើង។

ដូចដែលអល់ឡោះបានចែងនៅក្នុងគម្ពីរគួរអានថា៖

**ជាការពិតណាស់ ពួកអ្នកមានអ្នកនាំសាររបស់អល់ឡោះ**
**(មូហាំម៉ាត់) ដែលជាគំរូដ៏ល្អបំផុត សម្រាប់ពួកអ្នក។**

*គួរអាន អាល់អះហ្សាប ៣៣:២១*

ហើយទាក់ទងនឹងការគោរពសក្ការៈផ្សេងៗ គឺលោកបានប្រើឱ្យប្រជាជាតិរបស់លោកដើរតាមការណែនាំរបស់លោក។ ជាក់ស្តែង ទាក់ទងនឹងការថ្វាយបង្គំ ព្យាការីបានមានប្រសាសន៍ថា៖

**ចូរថ្វាយបង្គំ(សឡាត) ដូចដែលអ្នកបានឃើញការថ្វាយបង្គំរបស់ខ្ញុំ។**

*ហាទីស ពូខរី ៦៣១*

ដូច្នេះ ប្រសិនបើយើងចង់ធ្វើការគោរពសក្ការៈឱ្យបានពេញលេញដើម្បីឱ្យអល់ឡោះទទួលយក យើងត្រូវតែគោរពតាមមាគ៌ា និងការពន្យល់ណែនាំរបស់លោក ដែលមានតួនាទីជាអ្នកនាំសាររបស់អល់ឡោះ។

នៅពេលដែលយើងថ្វាយបង្គំ របៀបដែលយើងលើកដៃតឹកពៀរ ឈរសូត្រ អាន ក្រោកឡើង ក្រាបចុះ ឱ្យសាឡាម ទាំងអស់នេះ ត្រូវតែធ្វើតាមរបៀបដែលព្យាការីរបស់យើងបានបង្រៀនយើង។ យើងមិនត្រូវបន្ថែមលើកាតព្វកិច្ចនៅក្នុងការថ្វាយបង្គំ ច្រើនជាងប្រាំពេលក្នុងមួយថ្ងៃ ឬបន្ថែមចំនួនរ៉កអាត់ លើសពីអ្វី

ដែលច្បាប់បានកំណត់នោះឡើយ។ ក៏ដូចគ្នាដែរ រាល់ការគោរពសក្ការៈផ្សេងៗ ដែលច្បាប់មិនបានកំណត់ចែង ឬមិនត្រូវបានណែនាំដោយ ព្យាការីមូហាំម៉ាត់ គឺយើងមិនត្រូវធ្វើនោះទេ។

នៅក្នុងការធ្វើធម្មយាត្រា(ហាជ្ជី) ព្យាការីក៏បានបង្រៀន និងបង្គាប់យើងឱ្យធ្វើតាមរបៀបដែលលោកបានធ្វើ នូវគ្រប់ទិដ្ឋភាពទាំងអស់ ដូចជា អំពីមូលដ្ឋានគ្រឹះ(រូកុន) របៀបនៃការអនុវត្ត និងនីតិវិធីរបស់វា។

ព្យាការីបានមានប្រសាសន៍ថា៖

**ចូរទទួលយករបៀបនៃការធ្វើពិធីធម្មយាត្រា(ហាជ្ជី) របស់អ្នកពីខ្ញុំ(ដោយការមើលនូវការប្រណិបត្តិខ្ញុំ)។**

*ហាទីស មូស្លីម ១២៩៧*

ដូច្នេះហើយ នៅក្នុងការគោរពសក្ការៈ យើងមិនអាចធ្វើកិច្ចការណាមួយព្រោះតែយើងគិតថាវាល្អ ដែលមិនត្រូវបានអនុវត្ត ឬណែនាំដោយព្យាការីនោះឡើយ។ នៅក្នុងហាទីសមួយផ្សេងទៀត មានបុរសបីនាក់បានមកផ្ទះរបស់អ្នកស្រីអាអ៊ីស្ហះ ដែលជាផ្ទះរបស់ព្យាការីមូហាំម៉ាត់ដូចគ្នា ហើយពួកគេបានសួរអ្នកស្រីអាអ៊ីស្ហះ(ដោយសេចក្តីសង្ខេប)ថា៖ តើការថ្វាយបង្គំរបស់ព្យាការីយ៉ាងដូចម្តេច? យើងបានដឹងហើយថា គឺជាអ្នកនាំសារដែលត្រូវបានការពារពី អំពើបាប និងត្រូវបានលើកលែងទោសពីអល់ឡោះជាម្ចាស់ចំពោះអំពើបាបទាំងអស់ពីអតីតកាល និងអនាគតកាល។ ចំណែកពួកយើងជាមនុស្សធម្មតាដែលមានគុណវិបត្តិ និងភាពខ្វះខាតជាច្រើន។ ដូច្នេះការគោរពសក្ការៈដែលធ្វើឡើងដោយព្យាការី គឺកាន់តែល្អក្នុងនាមជាអ្នកនាំសាររបស់អល់ឡោះ។ សហការីទាំងបីនាក់នោះក៏បានគិតថា ទង្វើរបស់ព្យាការីនឹងទទួលបានផលបុណ្យ ឥតឈប់ឈរ និងមិនចប់នោះឡើយ។ បន្ទាប់មកបុរសទីមួយ ក៏បាននិយាយថា៖ មែនហើយ ឥឡូវខ្ញុំនឹងបន្តតមអាហារ(បួស)

ហើយខ្ញុំនឹងមិនស្រាយបួសនោះឡើយ។ ហើយបុរសទីពីរ ក៏បាននិយាយថា៖ ខ្ញុំនឹងថ្វាយបង្គំពេញមួយយប់ មិនគេងនោះឡើយ។ ចំណែកបុរសទីបីវិញ ក៏បាននិយាយដែរថា៖ ខ្ញុំនឹងនៅឱ្យឆ្ងាយពីស្ត្រី (មិនរៀបការ) ដើម្បីផ្តោតលើការគោរពសក្ការៈទៅចំពោះអល់ឡោះ។ ពេលព្យាការីបានឮការសន្ទនារបស់ពួកគេ លោកក៏បានដើរចេញមកហើយសួរថា៖

**តើពួកអ្នកនិយាយបែបនេះឬ? ខ្ញុំសូមស្បថនឹងអល់ឡោះជាម្ចាស់ ខ្ញុំគឺជាអ្នកដែលធ្វើតាមបង្គាប់អល់ឡោះជាម្ចាស់ និងកោតខ្លាចចំពោះទ្រង់បំផុត តែនៅឡើយខ្ញុំបួសហើយស្រាយ ខ្ញុំក្រោកថ្វាយបង្គំហើយគេង ហើយខ្ញុំក៏រៀបការផងដែរ អ្នកណាហើយដែលមិនពេញចិត្តធ្វើតាមស៊ុណ្ណះរបស់ខ្ញុំ នោះគេនឹងមិនមានអ្វីទាក់ទងនឹងខ្ញុំនោះឡើយ (មិនចាត់ទុកថាជាអ្នកដើរតាមខ្ញុំនោះទេ)។**

*ហាទីស ពូខរី ៥០៦៣*

នៅក្នុងហាទីសមួយផ្សេងទៀត ព្យាការីបានមានប្រសាសន៍ថា៖

**អន្តរាយហើយ ចំពោះអ្នកដែលធ្វើហួសព្រំដែន!**

*ហាទីស មូស្លីម ២៦៧០*

ដូច្នេះហើយ មិនថានៅក្នុងកិច្ចការសាសនា ឬក៏នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃនោះទេ ព្យាការីគឺជាគំរូដ៏ល្អបំផុត សម្រាប់ពួកយើងទាំងអស់គ្នា។

# បុគ្គល
# ដែលគេទន្ទឹងរង់ចាំ
# មកជាយូរ

មូហាំម៉ាត់ គឺជាបុគ្គលដ៏អស្ចារ្យម្នាក់ ឈ្មោះរបស់លោកត្រូវបានលើកឡើងនៅក្នុងគម្ពីរគួរអាន ដោយការប្រទានពីព្រះជាម្ចាស់ជាមួយនឹងឈ្មោះថា មូហាំម៉ាត់ រ៉ស៊ូលុលឡោះ (មូហាំម៉ាត់ អ្នកនាំសាររបស់អល់ឡោះ)។ ទ្រង់ថែមទាំងបានប្រទានឈ្មោះជំពូកមួយទាំងមូលនៅក្នុងគម្ពីរគួរអានដល់លោក ដែលត្រូវបានហៅថា ជំពូកមូហាំម៉ាត់។

លើសពីនេះទៅទៀត អល់ឡោះទ្រង់បានមានព្រះបន្ទូលអំពីការមកដល់របស់លោកនៅក្នុងគម្ពីរគួរអាន តាមរយៈពាក្យសម្ដីរបស់ព្យាការីអ៊ីសាថា៖

**និងផ្ដល់ដំណឹងដ៏រីករាយអំពីអ្នកនាំសាររបស់អល់ឡោះ**
**ដែលនឹងមកដល់បន្ទាប់ពីខ្ញុំ ដែលមានឈ្មោះថា អះម៉ាត់។**

*គួរអាន ជំពូកអាល់សហ្វ ៦១:០៦*

អះម៉ាត់ ឬ មូហាំម៉ាត់ ជាឈ្មោះដែលមានន័យដូចគ្នា គឺមានន័យថា អ្នកដែលគេសរសើរ។ ដោយលោកត្រូវបានសរសើរដោយអល់ឡោះ ក៏ដូចជាទេវតា ហើយនិងមនុស្សផងទាំងឡាយ ព្រមទាំងអ្វីគ្រប់យ៉ាងដែលទ្រង់បានបង្កើត មិនថានៅលើមេឃ ឬនៅលើផែនដីឡើយ។

# ពូជពង្សដ៏ថ្លៃថ្នូរ

មូហាំម៉ាត់ ជាឈ្មោះដែលយើងតែងតែធ្លាប់បានឮពិតមែន ប៉ុន្តែតើយើងបានដឹងអ្វីខ្លះ អំពីវង្សត្រកូលរបស់បុគ្គលម្នាក់នេះ? ភាគច្រើននៃយើងទាំងអស់គ្នាស្គាល់តែពូជពង្សរបស់យើងផ្ទាល់ ហើយប្រហែលជាស្គាល់ត្រឹមឈ្មោះរបស់ឪពុកម្តាយ និងជីដូនជីតារបស់យើងតែប៉ុណ្ណោះ។ ហើយវាគួរឱ្យសោកស្តាយបំផុតប្រសិនជាយើងមិនបានស្គាល់វង្សត្រកូលរបស់ព្យាការីរបស់យើង ដែលជាអ្នកដែលយើងបានអះអាងជារឿយៗថាស្រលាញ់លោករាល់ថ្ងៃ រាល់ឆ្នាំ។

ព្យាការីត្រូវបានគេដាក់ឈ្មោះថា មូហាំម៉ាត់ កូនលោកអាប់ទុលឡោះ កូនលោកអាប់ទុលមូតឡិប កូនលោកហាស៊ីម កូនលោកអាប់ទុលម៉ាណាហ្វ កូនលោកគូសៃ កូនលោកគីឡាប កូនលោកមូរ៉ោះ កូនលោកកាអាប់ កូនលោកលូអៃ កូនលោកហ្គូឡិប កូនលោកហ្វីហៀរ។ លោកហ្វីហៀរនេះហើយ គឺជាអ្នកដែលត្រូវបានគេស្គាល់ថាជា គូរ៉ាយស៍ ដែលមានន័យថា ត្រីឆ្លាមតូច។ នេះបើតាមមតិដ៏ច្បាស់ការណ៍របស់អ្នកប្រវត្តិវិទូ។

វង្សត្រកូលនេះ បានផ្តល់នូវឥទ្ធិពល និងអំណាចដល់លោកជាខ្លាំង នៅក្នុងសហគមន៍នៃសម័យកាលរបស់លោក។ កុលសម្ព័ន្ធគូរ៉ាយស៍ គឺជាកុលសម្ព័ន្ធធំបំផុត និងមានឥទ្ធិពលបំផុត នៅក្នុងទីក្រុងម៉ាក្កះជាច្រើនសតវត្ស។ គូរ៉ាយស៍ គឺជាបុព្វបុរសរបស់ព្យាការីរបស់យើង និងសហការីជាច្រើនទៀតរបស់លោកផងដែរ។ ដូចជា អាពូប៉ាកើរ អូមើរ អូស្មាន អាលី តល់ហាស់ អាប់ទុលរ៉ស់ម៉ាន ពិនអោហ្វ ជាដើម។

បំណែកឯបុព្វការីជនរបស់ព្យាការីមុននឹងគូរ៉ាយស៍ (ហ្វីហៀរ)នោះគឺ ហ្វីហៀរ កូនលោកម៉ាលីគ កូនលោកអាល់ណាទើរ កូនលោកគីណាណះ កូនលោកឃូសៃម៉ាស់ កូនលោកមុតរីកាស កូនលោកអ៊ីលយ៉េស កូនលោកមូទើរ កូនលោកនីហ្សើរ កូនលោកមូអាត កូនលោកអាត់ណាន។ នេះគឺជាពូជពង្សរបស់ព្យាការីដែលត្រូវបានទទួលស្គាល់ដោយអ្នកប្រាជ្ញ៖ ទាំងអ្នកប្រាជ្ញប្រវត្តិវិទូ និងអ្នកប្រាជ្ញផ្នែកហាទីស។ ទោះបីជាមានការយល់ឃើញខុសគ្នា ក្នុងការកំណត់ពូជពង្សចាប់ពី

អាត់ណានទៅកាន់ព្យាការីអ៊ីស្មាអែលក៏ដោយ។ តែមូហាំម៉ាត់ គឺត្រូវបានបាត់តាំងធ្វើជាអ្នកនាំសាររបស់អល់ឡោះ បេញពីវង្សត្រកូលដ៏ខ្ពង់ខ្ពស់បំផុតនៅសម័យនោះយ៉ាងជាក់ច្បាស់។ ដោយប្រជាជនគូរ៉ាយស៍មិនដែលប្រកែកអំពីភាពថ្លៃថ្នូរនៃពូជពង្សរបស់ព្យាការីនោះឡើយ។

ប្រហែលជាយើងធ្លាប់បានឮរឿងរបស់ហ៊ីរកាល (Heraclius) ដែលធ្លាប់បានជួប អាពូ សាហ្វយ៉ាន ដែលជាមេដឹកនាំដ៏សំខាន់ម្នាក់នៃកុលសម្ព័ន្ធគូរ៉ាយស៍នៅម៉ាក្កះ ដែលនៅពេលនោះ លោកមិនទាន់បានកាន់សាសនាអ៊ីស្លាមនៅឡើយ។ ពេលនោះ ហ៊ីរកាល បានសួរ អាពូសាហ្វយ៉ាន អំពីពូជពង្សរបស់មូហាំម៉ាត់ ដែលគេតែងតែប្រឆាំងមិនព្រមតាម។ ប៉ុន្តែពេលនោះ អាពូ សាហ្វយ៉ាន មិនដែលប្រកែកឬបដិសេធនោះទេ អំពីភាពថ្លៃថ្នូរនៃពូជពង្សរបស់ព្យាការី ទោះបីជានៅពេលនោះលោកមានការស្អប់ និងមើលងាយមូហាំម៉ាត់យ៉ាងខ្លាំងក៏ដោយ។ ជំនួសមកវិញគាត់បានទទួលស្គាល់ថា ខ្សែលោហិតរបស់ព្យាការី គឺពិតជាអ្នកមានកិត្តិយសនិងជាទីមោទនៈបំផុត។ ជាការឆ្លើយតបទៅនឹងការណ៍នោះ ហ៊ីរកាល បាននិយាយថានោះហើយ គឺជាសញ្ញាសម្គាល់នៃអ្នកនាំសារ ដែលអល់ឡោះបានតែងតាំងពីក្នុងបំណោមអ្នកដែលមានពូជពង្សដ៏ល្អបំផុត។

គួរបញ្ជាក់ផងដែរថា៖ ហ៊ីរកាល គឺជាអធិរាជមួយរូបនៃចក្រភពប៊ីហ្សង់ទីន (Byzantine) ដែលកាន់អំណាចពីឆ្នាំ ៦១០ - ៦៤១ គ.ស។ គាត់មានដើមកំណើតអាមេនី និងជាគ្រីស្ទានសាសនិក។ ចក្រភពរបស់លោក បានប៉ះទង្គិចគ្នា ជាលើកដំបូងជាមួយមូស្លីមក្នុងកំឡុង សមរភូមិមុតអ៊ះ នៅខែទី ៩ ឆ្នាំ ៦២៩ នៃ គ.ស។

នៅក្នុងហាទីសមួយ ព្យាការីមូហាំម៉ាត់ បានមានប្រសាសន៍ថា៖

**ពិតប្រាកដណាស់ អល់ឡោះបានប្រទានកិត្តិយសដល់គីណាណាស់ ក្នុងបំណោមកូនចៅរបស់អ៊ីស្មាអែល ហើយទ្រង់បានប្រទានកិត្តិយស ដល់រូបខ្ញុំ ពីកូនចៅរបស់ហាស៊ីម។**

*ហាទីស មូស្លីម ២២៧៦*

ដូច្នេះពីកូនចៅរបស់គីណាណាស់ អល់ឡោះបានជ្រើសរើសគូរ៉ាយស៍។ បន្ទាប់មក ចាប់ពីគូរ៉ាយស៍ អល់ឡោះបានរើសយកបុរសម្នាក់ ដែលមានឈ្មោះថា ហាស៊ីម។ ដូច្នេះកុលសម្ព័ន្ធរបស់ព្យាការី ត្រូវបានគេស្គាល់ថាជាកូនចៅនៃលោក ហាស៊ីម។ ហើយលោកហាស៊ីម ជាអ្នកដែលមានឋានៈពូជពង្សខ្ពង់ខ្ពស់ និងមាន កិត្តិយសបំផុត។ ខណៈដែល ព្យាការីមូហាំម៉ាត់ ជាបុគ្គលដែលមានឥទ្ធិពលជាង គូរ៉ាយស៍ទៅទៀត។ ដូច្នេះវាមិនខុសនោះទេ ក្នុងការអះអាងថា លោកគឺជាបុរស ដែលមានឥទ្ធិពលបំផុតនៅក្នុងពិភពលោកគ្រប់ពេលវេលា។

មូហាំម៉ាត់ ជាបុគ្គលដែលមានគុណធម៌លើសពីហាស៊ីមទៅទៀត ព្រោះ លោកគឺជាអ្នកនាំសាររបស់អល់ឡោះ និងជាទីស្រលាញ់នៃទ្រង់ ដែលបានពាំនាំ សារដ៏ពិសិដ្ឋ នៃឯកទេពនិយម។ ព្យាការីត្រូវបានគេគោរពច្រើនជាងដូនតាទាំងអស់ របស់លោក សូម្បីតែគីណាណាស់ផ្ទាល់ក៏ដោយ។

មានពេលមួយដែលកុលសម្ព័ន្ធទាំងអស់បាននិយាយថា ពួកគេមិនដែល ឃើញនរណាម្នាក់ក្នុងចំណោមអ្នកគ្រប់គ្រង ឬក៏ជាស្ដេចដែលមានកិត្តិយស និងត្រូវ បានគេគោរព ដូចដែលសហាការីរបស់មូហាំម៉ាត់ គោរព និងឱ្យតម្លៃលោកបែបនេះ ឡើយ។ នេះហើយជាពូជពង្សរបស់ព្យាការី ដែលត្រូវបានអល់ឡោះជាម្ចាស់ការពារ និងថែរក្សាភាពថ្លៃថ្នូរជូនលោក។

នៅក្នុងហាទីសមួយ ព្យាការីមូហាំម៉ាត់ បានមានប្រសាសន៍ថា៖

**ខ្ញុំត្រូវបានប្រសូតចេញពីគ្រួសារដែលមានការរៀបការ ស្របច្បាប់ ហើយមិនមែនជាកូនខុសច្បាប់នោះឡើយ។**

*ហាទីស អាល់តៀរមីហ្ស៊ី ៤៧២*

អត្ថន័យនៃហាទីសនេះគឺ អល់ឡោះបានថែរក្សា និងការពារពូជពង្សរបស់ព្យាការីមូហាំម៉ាត់ ចាប់តាំងតែពីព្យាការីអាដាំ រហូតដល់ព្យាការីមូហាំម៉ាត់ប្រសូត។ ដោយលោកជាពូជពង្សដែលពុំធ្លាប់មានកូនក្រៅអាពាហ៍ពិពាហ៍នោះឡើយ។

នោះហើយជារបៀបដែលអល់ឡោះជាម្ចាស់ បានការពារពូជពង្សរបស់ព្យាការីពីទម្រង់នៃការបង្ខូចណាមួយ។ ដូច្នេះអ្នកដែលមានបំណងរិះគន់លោកខ្លាំងបំផុត ទៅលើប្រព័ន្ធកុលសម្ព័ន្ធ និងភាពថ្លៃថ្នូរនៃពូជពង្ស គឺមិនអាចនិយាយអ្វីបាននោះទេ។ សូម្បីតែពាក្យជំទាស់ណាមួយ ដែលទាក់ទងនឹងពូជពង្សរបស់លោកក៏ដោយ។ ហើយពូជពង្សដ៏ថ្លៃថ្នូរ គឺរឹតតែមានគុណធម៌បន្ថែមទៀត នៅពេលដែលវាត្រូវបានបូកបញ្ចូលជាមួយនឹងការប្រកាន់ខ្ជាប់នូវការប្រព្រឹត្តិអំពើសុចរិត ដូចដែលបានលើកឡើងនៅក្នុងហាទីសមួយថា៖

**មនុស្សមានជាតិកំណើតផ្សេងៗគ្នា ហើយអ្នកដែលល្អបំផុតនៅមុនសម័យអ៊ីស្លាមមកដល់(សម័យចាហ៊ីលីយ៉ះ) គឺគេនឹងល្អបំផុត នៅពេលដែលសាសនាអ៊ីស្លាមបានមកដល់ដូចគ្នា នៅពេលដែលគេទទួលបានការយល់ដឹងអំពីអ៊ីស្លាម។**

*ហាទីស ពូខរី ៣៣៨៣ និង មូស្លីម ២៣៧៨*

សហគមន៍អារ៉ាប់ជាទម្លាប់ពិបាកនឹងទទួលស្គាល់ និងគោរពចំពោះអ្នកដែលមិនត្រូវបានស្គាល់ថា មកពីគ្រួសារថ្លៃថ្នូរ និងខ្ពង់ខ្ពស់ណាស់។ ដូច្នេះវាមានសារៈសំខាន់ណាស់ សម្រាប់ព្យាការីមូហាំម៉ាត់ ដែលលោកមកពីត្រកូលដ៏ខ្ពង់ខ្ពស់ ព្រោះលោកនឹងមិនត្រូវបានគេចោទប្រកាន់ពីការព្យាយាមផ្លាស់ប្តូរជំហររបស់លោកនៅក្នុងសង្គម តាមរយៈការអំពាវនាវរបស់លោកនោះទេ។ ផ្ទុយទៅវិញអ៊ីស្លាមបាននាំមកនូវការអំពាវនាវ និងប្រយុទ្ធប្រឆាំងចំពោះគ្រប់ទម្រង់នៃការរើសអើងជាតិសាសន៍ និងប្រព័ន្ធវណ្ណៈ។ ព្យាការីបានមានប្រសាសន៍ថា៖

## ជនជាតិអារ៉ាប់ពុំមានកិត្តិយសជាងជនជាតិផ្សេងពីអារ៉ាប់នោះឡើយ ហើយជនជាតិផ្សេងពីអារ៉ាប់ក៏ពុំមានកិត្តិយសជាងអារ៉ាប់នោះដែរ។

*ហាទីស អះម៉ាត់ ២៣៤៨៩*

ភាពថ្លៃថ្នូរនៃពូជពង្សរបស់ព្យាការី បានផ្តល់ឱ្យលោកនូវគុណប្រយោជន៍ចំពោះបុគ្គលិកលក្ខណៈរបស់លោក ជាពិសេសគឺនៅក្នុងពិភពនយោបាយតែម្តង។ លោកឪពុករបស់លោក បានទទួលមរណៈភាពបោលលោកតាំងតែពីលោកស្ថិតនៅក្នុងផ្ទៃម្តាយមកម្លេះ។

បន្ទាប់មកម្តាយរបស់លោកក៏បានទទួលមរណៈភាពដូចគ្នានៅពេលដែលលោកមានអាយុ៦ឆ្នាំ ហើយលោកក៏បានរស់នៅជាមួយជីតារបស់លោក អាប់ទុលមូតឡិប ដែលជាមេដឹកនាំកុលសម្ព័ន្ធនៅក្នុងទីក្រុងម៉ាក្កះពេលនោះ។

ក្រោយពេលរស់នៅជាមួយជីតារបស់លោកបានពីរបីឆ្នាំ ជីតារបស់លោកក៏បានទទួលមរណភាពម្នាក់ទៀត ក្រោយមកលោកក៏ត្រូវរស់នៅជាមួយឪពុកមារបស់លោក អាពូ តឡិប ដែលជាមេដឹកនាំកុលសម្ព័ន្ធដ៏សំខាន់ម្នាក់ផងដែរនៅក្នុងទីក្រុងម៉ាក្កះ។

នេះពិតជាបានផ្តល់ឱ្យព្យាការីមូហាំម៉ាត់ នូវបទពិសោធន៍ដ៏អស្ចារ្យជាច្រើនលើកិច្ចព្រមព្រៀង ការគ្រប់គ្រង ជាពិសេស ការដោះស្រាយជម្លោះនៃកុលសម្ព័ន្ធ ក៏ដូចជាការដោះស្រាយបញ្ហាផ្សេងៗ នៅក្នុងសហាគមន៍ និងទីក្រុងនានាដែលនៅជុំវិញ ។

# ទឹកដីកំណើត
# ជាទីស្រលាញ់

មូហាំម៉ាត់បានប្រសូតនៅទីក្រុងមួយដ៏ពិសិដ្ឋ ដែលអល់ឡោះបានលើកតម្កើង។ ទ្រង់បានធ្វើឱ្យទីក្រុងមួយនេះ ក្លាយទៅជាទីក្រុងមួយដែលជាទីស្រលាញ់របស់មនុស្សជាច្រើនជុំវិញសកលលោក។ ជាទីក្រុងដែលពោរពេញទៅដោយគុណតម្លៃយ៉ាងច្រើនក្រៃលែង វានោះគឺ ទីក្រុងម៉ាក្កះ។

នៅក្នុងហាទីសមួយ ព្យាការីបានមានប្រសាសន៍ថា៖

**ខ្ញុំសូមស្បថនឹងអល់ឡោះ! អ្នក(ម៉ាក្កះ) គឺជាទឹកដីដ៏ប្រសើរបំផុតរបស់អល់ឡោះ និងជាទីស្រលាញ់បំផុតរបស់ទ្រង់ ហើយបើខ្ញុំមិនត្រូវបានគេបណ្តេញចេញពីអ្នកទេនោះ នោះខ្ញុំនឹងមិនចាកចេញពីអ្នកឡើយ។**

*ហាទីស អាល់តៀរមីហ្ស៊ី ៣៩២៥*

ម៉ាក្កះ គឺជាទឹកដីដែលត្រូវបានអល់ឡោះធ្វើឱ្យមានការរីកចម្រើនតាមរយៈបិតានៃបណ្តាព្យាការី គឺព្យាការីអ៊ីព្រហ៊ីម និងជាកន្លែងដែលមាន គុណសម្បត្តិជាច្រើន ដូចមានចែងក្នុងគម្ពីរគួរអាន និងបាននិទានដោយបណ្តាព្យាការី។

អល់ឡោះបានមានព្រះបន្ទូលថា៖

**ជាពិតណាស់ កន្លែងដំបូងបង្អស់ នៃការគោរពសក្ការៈ ដែលត្រូវបានកំណត់សម្រាប់មនុស្សលោក គឺទីក្រុងម៉ាក្កះ ដែលពោរពេញដោយពរជ័យ និងការចង្អុលបង្ហាញសម្រាប់សកលលោកទាំងមូល។**

*គួរអាន អាលីអ៊ីមរ៉ន ៣ : ៩៦*

មនុស្សភាគច្រើនបានដឹងជាទូទៅថា ប៉ៃតុលឡោះ(កន្លែងដែលអ្នកមូស្លីមគ្រប់គ្នាតម្រង់ទិសទៅរក នៅរាល់ពេលថ្វាយបង្គំ) ត្រូវបានសាងសង់ឡើងវិញនៅក្នុងសម័យកាលរបស់ព្យាការីអ៊ីព្រហ៊ីម។ ដោយការប្តេងស្តែងរបស់លោក ទីក្រុងម៉ាក្កះ

បានរីកចម្រើនជាបន្តបន្ទាប់ ហើយបានក្លាយជាចំណុចបង្គោលសម្រាប់អ្នកធ្វើធម្មយាត្រា និងពាណិជ្ជករទាំងឡាយ ជាពិសេសមានការផុសចេញនូវទឹកហ្សាំហ្សាំ ដែលជារឿងដ៏ល្បីល្បាញនៃព្យាការីអ៊ីស្មាអែល។ ទីតាំងយុទ្ធសាស្ត្រវាងហ្សាម(តំបន់ផ្នែកខាងកើតនៃសមុទ្រមេឌីទែរ៉ាណេ) និងយេម៉ែន បានជួយរួមចំណែកដល់ភាពរុងរឿងនៃទីក្រុងដ៏មានពរជ័យមួយនេះ។ ទឹកដីម៉ាក្កះ ត្រូវបានគេស្គាល់ផងដែរថាជាទឹកដីហារ៉ម(បម្រាម) ពីព្រោះគេបានហាមឃាត់មិនឱ្យបង្ហូរឈាមនៅក្នុងទឹកដីនេះឡើយ។ ជាការពិតមុនពេលការមកដល់នៃសាសនាអ៊ីស្លាម កុលសម្ព័ន្ធគូរ៉ាយស៍តែងតែគោរពយ៉ាងជ្រាលជ្រៅចំពោះទឹកដីបម្រាមមួយនេះ(ម៉ាក្កះ) ដោយមិនប្រព្រឹត្តនូវអំពើខុសច្បាប់ ដូចជាការសម្លាប់ ឬបង្ហូរឈាមអ្នកដទៃនៅក្នុងទឹកដីដ៏ពិសិដ្ឋនៃក្រុងម៉ាក្កះឡើយ។ ឧទាហរណ៍ ប្រសិនបើនរណាម្នាក់ត្រូវបានរកឃើញថាបានធ្វើឃាតឪពុករបស់គាត់ នៅចំពោះមុខរបស់គាត់នៅក្នុងទីក្រុងម៉ាក្កះ គាត់មិនអាចធ្វើអ្វីបានទាំងអស់នៅក្នុងការសងសឹកចំពោះឃាតករ។ ឃាតករគ្រាន់តែត្រូវចាប់ខ្លួន ឬក៏ធ្វើការសងសឹកនៅខាងក្រៅទីក្រុងម៉ាក្កះប៉ុណ្ណោះ។ ហេតុនេះបានធ្វើឱ្យទីក្រុងម៉ាក្កះ ក្លាយជាកន្លែងមួយដ៏គួរឱ្យប្រណៃនពីតំបន់ដែលនៅជុំវិញ។

អល់ឡោះមានព្រះបន្ទូលនៅក្នុងគួរអានថា៖

**តើពួកគេមិនបានឃើញទេឬ ពិតប្រាកដណាស់យើងបានបង្កើតទឹកដី(ម៉ាក្កះ)ជាទីសក្ការៈដ៏ស្អាតស្អំមានសុវត្ថិភាពបំផុត ខណៈដែលមនុស្សលោកនៅជុំវិញពួកគេកំពុងឆក់ប្លន់ កាប់សម្លាប់គ្នានោះ?**

*គួរអាន អាល់អាន់កាប៊ូត ២៩ : ៦៧*

យើងប្រហែលជាបានឮរឿងរបស់អាប់រ៉ហាស ដែលបានដឹកនាំកងទ័ពដំរីរបស់លោក ដើម្បីមកវាយកម្ទេចកាក់ពះ ដោយសារតែសេចក្តីប្រណៃននឹងទីក្រុងមួយនេះ ដែលមានមនុស្សច្រើនកុះករបានគោរព និងឱ្យតម្លៃ។

អល់ឡោះមានព្រះបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

**តើអ្នក(មូហាំម៉ាត់)មិនបានឃើញទេឬថា ម្ចាស់របស់អ្នក បានធ្វើទៅលើក្រុមទ័ពដំរីយ៉ាងដូចម្ដេច? តើទ្រង់មិនបានធ្វើឱ្យឧបាយកលអាក្រក់របស់ពួកគេវង្វេង(បរាជ័យ)ទេឬ? ដោយទ្រង់បានបញ្ជូនហ្វូងបក្សីដើម្បីប្រយុទ្ធតទល់នឹងពួកគេ។ ហ្វូងបក្សីទាំងនោះ បានទម្លាក់ដុំថ្មស៊ីជ្ជីល(ដែលមកពីភ្លើងនរក) ទៅលើពួកគេ។ ដែលធ្វើឱ្យពួកគេខ្ទេចខ្ទី ប្រៀបដូចនឹងស្លឹកឈើដែលត្រូវជង្គរស៊ី។**

*គួរអាន អាល់ហ្វីល ១០៥ : ១-៥*

នេះហើយ ទឹកដីនៃទីក្រុងម៉ាក្កះ ដែលអល់ឡោះបានប្រទាននូវពរជ័យសិរីមង្គល វិបុលសុខ ព្រមទាំងជាស្រុកកំណើតរបស់ព្យាការីមូហាំម៉ាត់ ដែលជាទីស្រលាញ់របស់យើងគ្រប់គ្នា។ ជាកន្លែងដែលបុរសដ៏អស្ចារ្យម្នាក់នេះ បានរីកធំធាត់ឡើង ហើយបានរស់នៅឆ្លងកាត់ការលំបាក និងរងទុក្ខវេទនាផ្សេងៗ អស់រយៈពេលជាង៥០ឆ្នាំ។

# ពីក្មេងកំព្រា
# ដែលស្រលាញ់
# និងយល់ចិត្ត
# ក្មេងកំព្រាដូចគ្នា

នៅពេលដែលព្យាការីស្ថិតក្នុងផ្ទៃម្តាយរបស់លោក ឪពុករបស់លោកក៏បានលាចែកឋានចោលលោក។ បន្ទាប់មកនៅពេលដែលលោកមានអាយុ៦ឆ្នាំ ម្តាយរបស់លោក ក៏បានបន្តចែកឋានម្នាក់ទៀត ទុកឱ្យរូបលោកក្លាយជាក្មេងកំព្រាឪពុកម្តាយទាំងវ័យក្មេង។ លោកក៏ត្រូវផ្លាស់មករស់នៅជាមួយជីតារបស់លោក តែមិនយូរប៉ុន្មាន ជីតារបស់លោក ដែលតែងតែយកចិត្តទុកដាក់មើលថែរក្សាលោកក៏បានចាកចេញពីលោកជារៀងរហូត។ ការស្លាប់របស់មនុស្សដែលជាទីស្រលាញ់ទាំងបីនាក់នេះ គឺលើសពីពាក្យថាឈឺចាប់ ចំពោះអារម្មណ៍នៃការបាត់បង់របស់លោក។

បទពិសោធន៍មួយនេះ បានធ្វើឱ្យរូបលោកយល់កាន់តែច្បាស់ អំពីរសជាតិជីវិត ហើយក៏ជាហេតុដែលធ្វើឱ្យចិត្តរបស់លោក ពោរពេញដោយសេចក្តីស្រលាញ់ និងអាណិតអាសូរជាខ្លាំង ដល់អ្នកដែលបានរងទុក្ខលំបាកក្នុងជីវិត ជាពិសេសគឺក្មេងកំព្រា។ អល់ឡោះមានបន្ទូលយ៉ាងច្បាស់អំពីរឿងនេះថា៖

**តើទ្រង់មិនបានឃើញអ្នក(មូហាំម៉ាត់)ជាកូនកំព្រា ហើយទ្រង់បានគាំពារអ្នកទេឬ? ហើយទ្រង់បានឃើញអ្នកវង្វេង រួចមកទ្រង់ក៏បានចង្អុលបង្ហាញផ្លូវដល់អ្នកទេឬ? ហើយទ្រង់បានឃើញអ្នកក្រីក្ររួចទ្រង់បានធ្វើឱ្យអ្នកមាន(គ្រប់គ្រាន់ និងពេញចិត្តចំពោះខ្លួនឯង)ទេឬ? ដូច្នេះ ចូរអ្នកកុំកៀបសង្កត់ចំពោះកូនកំព្រាឱ្យសោះ ហើយចូរអ្នកកុំគំហកដាក់អ្នកសុំទានឱ្យសោះ។**

*គួរអាន អាល់ទូហា ៩៣ : ៦-១០*

នៅក្នុងហាទីសមួយ ព្យាការីធ្លាប់បានមានប្រសាសន៍ថា៖

**ខ្ញុំ និងអ្នកដែលមើលថែក្មេងកំព្រា នឹងទទួលបានឋានសួគ៌ដូចនេះ (លោកបានធ្វើជាសញ្ញាដោយដាក់ម្រាមចង្អុល និងម្រាមដៃកណ្តាលរបស់លោកផ្ទឹមគ្នា)។**

*ហាទីស ពូខរី ៦០០៥*

# បុគ្គលដែលមិនធ្លាប់
# ភ្លូតភាវកុបាក

រយៈពេល៦៣ឆ្នាំនៃជីវិតរបស់ព្យាការី គេមិនដែលធ្លាប់ឮសោះឡើយពាក្យថា លោកជាមនុស្សកុហក ខុសស្រឡះពីពួកយើងដែលតែងតែកុហកក្នុងការនិយាយ ឬលេងសើច ជាពិសេសនៅក្នុងរឿងដែលយើងគិតថាមិនសំខាន់។

លោកពិតជាបានហាមឃាត់ប្រជាជាតិទាំងអស់ មិនឱ្យកុហកនោះឡើយ សូម្បីតែជាការនិយាយលេងសើចក៏ដោយ។

ព្យាការីបានមានប្រសាសន៍នៅក្នុងហាទីសមួយថា៖

**ខ្ញុំធានានូវគេហដ្ឋានមួយខ្នងនៅម្តុំឋានសួគ៌ សម្រាប់បុគ្គលដែលជៀសវាងការឈ្លោះប្រកែកគ្នា បើទោះបីជាគាត់មានសិទ្ធិ ឬស្ថិតនៅលើភាពត្រឹមត្រូវក៏ដោយ (ព្រោះខ្លាចធ្លាក់ទៅក្នុងភាពមានះរឹងរូស ដែលនាំឱ្យធ្លាក់ចូលទៅក្នុងរឿងដែលមិនគប្បី ជាបន្តបន្ទាប់កាន់តែវែងឆ្ងាយ) និងធានានូវគេហដ្ឋានមួយនៅកណ្តាលឋានសួគ៌ សម្រាប់បុគ្គលដែលជៀសវាងការនិយាយកុហក បើទោះបីជាការនិយាយលេងក៏ដោយ។**

*ហាទីស អាពូដាវូឌ ៤៨០០*

នេះហើយព្យាការីរបស់យើង ជាបុគ្គលម្នាក់ដែលគេតែងតែបានស្គាល់ថា អាល់អាមីន ដែលមានន័យថា បុគ្គលដែលស្មោះត្រង់ ឬគួរឱ្យទុកចិត្ត។ ដោយមួយជីវិតរបស់លោក គឺមិនដែលធ្លាប់បោកប្រាស់ ឬភូតកុហកនោះឡើយ។ សូម្បីតែអ្នកប្រឆាំងនឹងរូបលោកមកពីកុលសម្ព័ន្ធគូរ៉ាយស៍ដែលស្អប់លោកក៏មិនដែលនិយាយថាលោកជាមនុស្សកុហកនោះដែរ។ នេះគឺដោយសារតែពួកគេទាំងអស់ស្គាល់ពីអត្តចរិត និងអាកប្បកិរិយារបស់ព្យាការីច្បាស់ថាលោកមិនដែលក្បត់ ឬកុហកនៅក្នុងទំនាក់ទំនងណាមួយរបស់លោកជាមួយពួកគេនោះឡើយ។ ទាំងនេះគឺជាការចង្អុលបង្ហាញនៃអស់ឡោះ តាមរយៈបុរសម្នាក់ដែលនាំមកនូវការផ្លាស់ប្តូរដ៏អស្ចារ្យ

នៅក្នុងទឹកដីអារ៉ាប់ និងលើពិភពលោកទាំងមូល។ អល់ឡោះមានព្រះបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

**ហើយពិតប្រាកដណាស់ អ្នក(មូហាំម៉ាត់)ពិតជាអ្នកណែនាំ**
**មនុស្សជាតិទៅកាន់មាគ៌ាត្រឹមត្រូវ(សាសនារបស់អល់ឡោះ)។**
*គួរអាន អាល់ហ្សូរ៉ ៤២ : ៥២*

**សូមបញ្ជាក់ផងដែរថា៖** ការចង្អុលបង្ហាញមានពីរទម្រង់៖

**ទម្រង់ទីមួយ៖** ហ៊ីដាយ៉ាស់ អ៊ីរស្វាត មានន័យថា ការណែនាំ ឬជួយចង្អុលបង្ហាញផ្លូវត្រឹមត្រូវដល់អ្នកដទៃ។ ទម្រង់ទីមួយនេះ គឺជាទម្រង់ដែលព្យាការី និងមនុស្សទូទៅអាចធ្វើបាន។ ដូចដែលបានលើកឡើងក្នុងវាក្យខណ្ឌខាងលើ។

**ទម្រង់ទីពីរ៖** ហ៊ីដាយ៉ាស់ តាវហ្វីក មានន័យថា ការណែនាំ ឬចង្អុលបង្ហាញ ដោយការបំផុសគំនិតឱ្យមានការយល់ដឹង ឆ្ពោះទៅរកការប្រព្រឹត្តិអំពើល្អ និងទទួលមាគ៌ាត្រឹមត្រូវ។ ទម្រង់ទីពីរនេះ ជាទម្រង់នៃការប្រោសប្រទានដោយអល់ឡោះតែម្នាក់គត់។ ដូចដែលអល់ឡោះបានមានព្រះបន្ទូលថា៖

**ពិតប្រាកដណាស់ អ្នក(មូហាំម៉ាត់)មិនអាចចង្អុលបង្ហាញចំពោះអ្នកណាដែលអ្នក**
**ស្រលាញ់បានឡើយ ក៏ប៉ុន្តែមានតែអល់ឡោះម្នាក់ទេ ដែលអាចចង្អុលបង្ហាញ**
**ចំពោះអ្នកណាដែលទ្រង់មានចេតនា។ ហើយទ្រង់ដឹងបំផុត ចំពោះបណ្តាអ្នកដែល**
**បានទទួលការចង្អុលបង្ហាញ។**
*គួរអាន អាល់ក៏សោស្ស ២៨ : ៥៦*

# បុរសដែលស្ថិតក្រោម
# ការការពារពី
# អស់ឡោះជាម្ចាស់

ព្យាការីលោកបានធំធាត់ឡើងនៅក្រុងម៉ាក្កះ នៅក្នុងសម័យកាលមួយដែលទីក្រុងមួយនេះ គឺពោរពេញដោយអំពើបាប និងអំពើអាក្រក់ផ្សេងៗ។ រហូតដល់ក្នុងចំណោមពួកគូរ៉ាយស៍ គឺមានអ្នកដែលសម្លាប់ទារកខ្លួនឯង ដោយសារខ្លាចធ្លាក់ខ្លួនក្នុងភាពក្រីក្រ ហើយថែមទាំងបានបញ្ចុះសពកូនស្រីរបស់ពួកគេទាំងរស់ដោយពួកគេគិតថា កូនស្រីមិនអាចជួយគ្រួសារ ឬក្លាយជាអ្នកចម្បាំងបាននោះឡើយ។ អល់ឡោះទ្រង់បានហាមឃាត់យ៉ាងតឹងរ៉ឹង អំពីការធ្វើនូវទង្វើបែបនេះ។ ដូចដែលទ្រង់មានព្រះបន្ទូលនៅក្នុងគួរអានថា៖

**ហើយចូរពួកអ្នកកុំសម្លាប់កូនចៅរបស់ពួកអ្នក ព្រោះតែខ្លាចភាពក្រីក្រឱ្យសោះ យើងនោះទេ ដែលជាអ្នកប្រទាននូវលាភសក្ការៈ(រីស្ គ)ឱ្យពួកគេ ក៏ដូចជាពួកអ្នក។**

*គួរអាន អាល់អ៊ីសរ៉ក ១៧ : ៣១*

ពួកគេគិតថាអាម៉ាស់ណាស់ដែលមានកូនស្រី ព្រោះមានមនុស្សជាច្រើននៅក្នុងសហគមន៍អារ៉ាប់ពេលនោះ នៅពេលដែលទទួលបានដំណឹងថាពួកគេទទួលបានកូនស្រី មុខរបស់ពួកគេប្រែទៅជាខ្មៅស្រអាប់ដោយសារតែ អៀនខ្មាសក្នុងការដែលមានកូនស្រី។

អល់ឡោះមានព្រះបន្ទូលនៅក្នុងគួរអានថា៖

**ហើយនៅពេលដែលអ្នកណាម្នាក់ក្នុងចំណោមពួកគេ ត្រូវបានគេផ្តល់ដំណឹងថាកើតបានកូនស្រីនោះ មុខរបស់គេប្រែទៅជាខ្មៅស្រអាប់ភ្លាម ហើយពោរពេញទៅដោយទុក្ខសោក។**

*គួរអាន អាល់ណាហាល ១៦ : ៥៨*

គម្ពីរគួរអានបានពិពណ៌នាថា នៅក្នុងថ្ងៃបរលោក ព្រលឹងនៃទារិកាដែលត្រូវបានសម្លាប់ដោយប្រជាជនម៉ាក្កះនោះ នឹងត្រូវពង្រស់ឱ្យមានជីវិតរស់ឡើងវិញ ហើយពួកគេនឹងសួរថា តើយើងត្រូវគេសម្លាប់ដោយសារទោសអ្វី?

**ហើយទារិកាដែលគេបានកប់ទាំងរស់ទាំងនោះ ត្រូវបានគេសួរថា**
**តើដោយសារតែបាបកម្មអ្វីទៅ បានជានាងត្រូវបានគេសម្លាប់?**

*គួរអាន អាល់តឹកវៀត ៨១ : ៨-៩*

មិនត្រឹមតែប៉ុណ្ណោះ ទោះបីជាជនជាតិអារ៉ាប់នៅក្នុងយុគសម័យចាហ៊ីលីយ៉ះ (សម័យនៃភាពល្ងង់ខ្លៅ) ត្រូវបានគេស្គាល់យ៉ាងច្បាស់ថា ពួកគេស្ទាត់ជំនាញខាងវោហារស័ព្ទ និងប្រើប្រាស់ភាសាអក្សរសាស្ត្រយ៉ាងអស្ចារ្យ ព្រមទាំងសុជីវធម៌ល្អមួយចំនួនដូចជា មានចិត្តសប្បុរស និងផ្តល់កិត្តិយសដល់ភ្ញៀវក៏ដោយ។ តែទន្ទឹមគ្នានោះដែរ ពួកគេក៏តែងតែប្រយុទ្ធគ្នាក្នុងរឿងតូចតាចដែលមិននឹងគួរកើតឡើង ព្រមទាំងយកឈ្លើយសឹកធ្វើជាទាសករ និងធ្វើបាបជារឿយៗ។ និងចាត់ទុកស្ត្រីដូចជារបស់លេង រកស៊ីបោកប្រាស់ ក៏ដូចជាប្រព្រឹត្តិអំពើទុច្ចរិតគ្រប់បែបយ៉ាង ដែលរឿងទាំងនេះ ជាការអនុវត្តទូទៅរបស់ពួកគេទៅហើយនៅសម័យនោះ។

នេះហើយ គឺជាស្ថានភាពនៅសម័យកាលនោះ ហើយក៏ជាដំណាក់កាលមួយនៃជីវិត ដែលព្យាការីរបស់យើងបានឆ្លងកាត់។ លោកបានធំឡើងនៅក្នុងសង្គមដែលប្រាសចាកសីលធម៌ និងខូចខាតរចនាសម្ព័ន្ធសង្គមជាខ្លាំង។ តែទោះជាយ៉ាងណា អល់ឡោះ បានការពារព្យាការីពីការជាប់ពាក់ព័ន្ធនៅក្នុងអំពើប្រាសចាកសីលធម៌ទាំងនោះ។ ខណៈអ្នកស្រុកម៉ាក្កះ កំពុងស្ថិតក្នុងស្ថានភាពស្រវឹងជោកជាំ និងគ្មានការអាណិតអាសូរបំពោះអ្នកទន់ខ្សោយ ដែលត្រូវបានគេកៀបសង្កត់បន្តិចសោះឡើយ។

ព្យាការីលោកធ្លាប់រត់គេចពីភាពវឹកវរ នៃអ្នកស្រុកម៉ាក្កះ ដើម្បីស្វែងរកសន្តិភាព និងភាពស្ងប់ស្ងាត់។ ការកៀបសង្កត់ និងអំពើទុច្ចរិត ដែលប្រជាជននៃទីក្រុងម៉ាក្កះ បានប្រព្រឹត្តជារឿយៗ បានធ្វើឱ្យព្យាការីត្រូវគេចចេញពីទីក្រុងមួយនេះ ដើម្បីសម្រាលកង្វល់។ ដោយលោកតែងតែឡើងទៅរូងភ្នំ ហ៊ីរ៉ក ហើយនៅម្នាក់ឯង ដើម្បីស្វែងរកការលួងលោមចិត្ត និងសម្រាលទុក្ខ នៅមុនពេលលោកមានអាយុ ៤០ ឆ្នាំ។ លោកក៏បានត្រឡប់មកផ្ទះ ដើម្បីនាំយកម្ហូបចំណី ដែលបានរៀបចំដោយភរិយាជាទីស្រលាញ់របស់លោក គឺអ្នកស្រីខទីជះ ហើយក៏ត្រឡប់ទៅរូងភ្នំហ៊ីរ៉កវិញ។

លោកបានធ្វើបែបនេះជារឿយៗ រហូតដល់ថ្ងៃមួយនោះ នៅពេលដែលព្រឹត្តិការណ៍នៃវិវរណៈ(វ៉ាហ៊ុ)បានកើតឡើង ដែលធ្វើឱ្យលោកប្រញាប់ទៅផ្ទះវិញនៅពេលនោះ ដោយសារតែភាពភ័យខ្លាច។ ពេលដល់ផ្ទះ លោកបានសុំអ្នកស្រីខទីជះដណ្តប់ភួយឱ្យលោក។ បន្ទាប់មក ភរិយាគំរូដ៏ឈ្លាសវៃរបស់លោកម្នាក់នេះ បានលួងចិត្តប្តីដោយពាក្យពេចន៍ដ៏ពីរោះ ដែលបានជួយសម្រាលទុក្ខលោកជាខ្លាំងនៅគ្រានោះ។ ដោយអ្នកស្រីក៏បាននិយាយទៅកាន់ប្តីរបស់អ្នកស្រី ដោយសម្តីទន់ភ្លន់ថា៖ មិនអីនោះទេបង អល់ឡោះនឹងមិនធ្វើឱ្យបងអាប់ឱននោះឡើយ! បងជាមនុស្សដែលមានទំនាក់ទំនងល្អជាមួយ ញាតិមិត្ត ចេះជួយយកអាសាជនក្រីក្រទុរគត បម្រើភ្ញៀវដោយចិត្តសប្បុរស និងតែងតែជួយដល់អ្នកដែលជួបគ្រោះមហន្តរាយ មិនចឹង?

ដោយសារតែពាក្យលួងលោមរបស់អ្នកស្រី ធ្វើឱ្យព្យាការីបានធូរស្រាលចិត្ត និងមានកម្លាំងឡើង ក្នុងការអំពាវនាវទៅរកឯកទេពនិយម (តាវហេទ) និងបញ្ចប់ការថ្វាយបង្គំរូបបដិមា និងពហុទេពនិយម(ស្ហ៊ីរិក) ដែលជាការគោរព និងការអនុវត្តនៃសហគមន៍របស់លោក ដែលពោរពេញដោយភាពវង្វេង និងគ្មានជំនឿត្រឹមត្រូវ។

បន្ទាប់ពីរឿងនេះបានកើតឡើង អល់ឡោះក៏បានបញ្ចុះនូវជំពូកមួយនៅក្នុងគម្ពីរគួរអាន ដោយទ្រង់មានព្រះបន្ទូលថា៖

ឱអ្នកដណ្ដប់ភួយ! (មូហាំម៉ាត់) ចូរអ្នកក្រោកឡើង ហើយចាប់ផ្ដើមដាស់តឿនព្រមាន(មនុស្សលោក អំពីទារុណកម្មរបស់អល់ឡោះ)។ ចូរអ្នកលើកតម្កើងម្ចាស់របស់អ្នក។ ចូរអ្នកសំអាតសំលៀកបំពាក់របស់អ្នក។ ចូរអ្នកជៀសឱ្យឆ្ងាយពីប្រការស្ហ៊ីរិក។ ចូរអ្នកកុំឱ្យអ្វីដល់គេ ដោយអ្នកចង់បានការតបស្នងបន្ថែមមកវិញឱ្យសោះ។ ហើយដើម្បីបំពេញបទបញ្ញានៃម្ចាស់របស់អ្នក ចូរអ្នកអត់ធ្មត់។

*គួរអាន អាល់មូទ្ទេសសៀត ៧៤ : ១-៧*

# អាថ៌កំបាំងដែលទឹកដីអារ៉ាប់ត្រូវបានជ្រើសរើសជាកន្លែងសម្រាប់ការបញ្ចុះវិវរណៈ(វ៉ាហ៊ី)

បន្ថែមពីលើការប្រាសចាកសីលធម៌របស់ជនជាតិអារ៉ាប់មុននឹងអ៊ីស្លាមមកដល់ដូចដែលបានរៀបរាប់ខាងលើរួចមក។ ពួកគេក៏ត្រូវបានគេស្គាល់ដែរថាជាអនក្ខរភាព(មិនចេះអាន និងសរសេរ) និងឃ្លាតឆ្ងាយពីអរិយធម៌ និងនគររូបនីយកម្មផងដែរ។ អល់ឡោះមានបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

**យើងបានចាត់តាំងអ្នកនាំសារម្នាក់ (មូហាំម៉ាត់) អំពីពួកគេ ក្នុងចំណោមពួកអនក្ខរជន ដោយឱ្យលោកសូត្រនូវគម្ពីររបស់ទ្រង់ ឱ្យពួកគេស្ដាប់ និងសំអាតពួកគេអំពីប្រការស្ហ៊ីរិក(ជំនឿលើពហុទេព) ព្រមទាំងបង្រៀនគម្ពីរគួរអាន និងស៊ុណ្ណះដល់ពួកគេ ខណៈដែលពួកគេកាលពីមុន គឺស្ថិតនៅក្នុងភាពវង្វេងយ៉ាងជាក់ច្បាស់។**

*គួរអាន អាល់ជូមូអះ ៦២ : ២*

ប្រសិនបើប្រទេសអារ៉ាប់មុនអ៊ីស្លាមមកដល់នោះ មានអរិយធម៌ដូចជាចក្រភពដែលនៅជុំវិញ ដូចជា រ៉ូម ពែក្ស និងក្រិចពេលនោះ គឺនឹងមានមនុស្សដែលនឹងធ្វើការអះអាងថា អ៊ីស្លាមគឺជាសាសនាដែលមនុស្សបង្កើត ឬជាទស្សនវិជ្ជាដែលកើតមកពីអរិយធម៌ជាមិនខាន។ ទោះយ៉ាងណាក៏ដោយ ដោយសារអំណាចរបស់អល់ឡោះ ទ្រង់បានបញ្ជូនសាររបស់ទ្រង់ ទៅកាន់ប្រជាជនដែលរស់នៅក្នុងតំបន់វាលខ្សាច់មួយនេះ ដែលវាគឺជាសញ្ញានៃភាពជាព្យាការីសម្រាប់អ្នកដែលនឹងយកគិតពិចារណា និងឆ្លុះបញ្ចាំងការពិត។

**ហើយអ្នក(មូហាំម៉ាត់)មិនធ្លាប់ចេះសូត្រគម្ពីរណាមួយ មុននឹងគម្ពីរគួរអានមកដល់នោះឡើយ។ ហើយដៃស្ដាំរបស់លោក ក៏ពុំចេះសរសេរសៀវភៅណាមួយពីមុនមកដែរ។ មិនដូច្នោះទេ ពួកដែលប្រឆាំងនឹងមានការសង្ស័យថា អ្នកបានចម្លងគួរអានពីគម្ពីរមុនៗជាមិនខានឡើយ។**

*គួរអាន អាល់អាន់កាពួរ ២៩ : ៤៨*

លើសពីនេះ តំបន់អារ៉ាប់មានទីតាំងនៅចំកណ្តាលអរិយធម៌ធំៗរបស់ពិភពលោកនៅពេលនោះ ដូចជា រ៉ូម ពែក្ស និងឥណ្ឌា ដែលអាចអនុញ្ញាតឱ្យតំបន់នេះក្លាយជាមជ្ឈមណ្ឌលយ៉ាងល្អបំផុតនៃការផ្សព្វផ្សាយអ៊ីស្លាម ទៅកាន់ពិភពលោកទាំងមូល។ ហើយអ្វីដែលលើសពីនេះទៅទៀត អត្ថិភាពនៃកាក់ពះ និងប្រភពទឹកហ្សំហ្សំ នៅកណ្តាលក្រុងម៉ាក្កះ បានបង្កើតជាចំណុចសំខាន់ដល់មនុស្សជាច្រើន ក៏ដូចជាមជ្ឈមណ្ឌលពាណិជ្ជកម្មសម្រាប់ឱ្យពាណិជ្ជករទាំងឡាយធ្វើដំណើរទៅទីនោះ។ នេះជារបៀបដែលអល់ឡោះ បានប្រទានតាមបំណងប្រាថ្នារបស់អ្នកជាទីស្រលាញ់របស់ទ្រង់ គឺព្យាការីអ៊ីព្រហ៊ីម ដែលលោកបានទូអាបួងសួងថា៖

**បពិត្រអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាតែងតាំងអ្នកនាំសារម្នាក់ អំពីពួកគេ (កូនចៅអ៊ីស្មាអែល) ឱ្យពួកផង ដែលលោកនឹងសូត្រខគម្ពីររបស់ទ្រង់ឱ្យពួកគេស្តាប់ ហើយបង្រៀនគម្ពីរគួរអាន និងមាគ៌ារបស់លោកដល់ពួកគេ ហើយនិងដើម្បីជំរះបាបកម្មពួកគេផង។ ពិតប្រាកដណាស់ ទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។**

*គួរអាន អាល់ហ្គាក៏រ៉ោះ ២ : ១២៩*

# មូហាំម៉ាត់

# អ្នកនាំសារនៃ

# អល់ឡោះ

មូហាំម៉ាត់ រ៉ស៊ូលុលឡោះ គឺជាអ្នកទទួលសារដ៏សិរីរុងរឿងក្រៃលែងពីអល់ឡោះជាម្ចាស់។ ជាសារដែលផ្តល់នូវសេចក្តីមេត្តាករុណា និងបង្ហាញផ្លូវត្រឹមត្រូវសម្រាប់មនុស្សជាតិ និងសកលលោកទាំងមូល។ ចំណែកឯអ្នកនាំសារមុនៗ គឺត្រូវបានបញ្ជូនមកចំពោះប្រជាជាតិរៀងៗខ្លួន របស់ពួកគេតែប៉ុណ្ណោះ។

អល់ឡោះមានបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

**ពួកគេ(ពួកអ្នកគ្មានជំនឿ)មានបំណងពន្លត់ពន្លឺរបស់អល់ឡោះ(សាសនាអ៊ីស្លាម) តាមរយៈមាត់របស់ពួកគេប៉ុណ្ណោះ តែអល់ឡោះមិនអនុញ្ញាតឡើយ ផ្ទុយទៅវិញ ទ្រង់នឹងបំពេញពន្លឺរបស់ទ្រង់ថែមទៀត ទោះបីពួកគេប្រឆាំងមិនពេញចិត្តក៏ដោយ។**

*គួរអាន អាល់តាវប៉ាត់ ៩ : ៣២*

សាររបស់ទ្រង់ បាននាំមកនូវការចង្អុលបង្ហាញ និងចំណេះដឹងជាច្រើនប្រៀបដូចជាទឹកភ្លៀងដែលបាននាំមកនូវគុណប្រយោជន៍ជាច្រើនដល់មនុស្សដូចគ្នាដែរ។ ដូចដែលមានចែងនៅក្នុងហាទីសមួយ ដោយព្យាការី លោកបានមានប្រសាសន៍ថា៖

**ការដែលអល់ឡោះបានចាត់តាំងខ្ញុំមក គឺដើម្បីចង្អុលបង្ហាញ និងផ្តល់ចំណេះដឹង វាប្រៀបបានទៅនឹងទឹកភ្លៀង ដែលធ្លាក់ចុះមកលើផែនដីអ៊ីចឹងដែរ។ ដីខ្លះជាដីដែលមានជីជាតិ ហើយអាចស្រូបយកទឹកភ្លៀងបានល្អ ដែលធ្វើឱ្យរុក្ខជាតិ និងស្មៅដុះលូតលាស់យ៉ាងបរិបូរណ៍។**

អត្ថន័យនៅទីនេះគឺចង់សំដៅលើមនុស្សមួយចំនួន ដែលស្រដៀងនឹងដីដែលល្អមានជីជាតិ ដែលអាចស្រូបយកទឹក និងអាចដាំបន្លែផ្លែឈើបានយ៉ាងល្អ។ ដែលអាចឱ្យអ្នកដទៃអាចទទួលផលពីដី ឬរុក្ខជាតិទាំងនោះ។ មនុស្សប្រភេទនេះ

នឹងផ្សព្វផ្សាយយ៉ាងសកម្មនូវចំណេះដឹង ក៏ដូចជាណែនាំមនុស្ស តាមចំណេះដឹង និងការអនុវត្តដែលពួកគេមាន ដែលវាត្រូវបានជំរុញ និងអនុវត្តដោយអ្នកនាំសារ របស់អល់ឡោះរួចមកហើយ។ មនុស្សប្រភេទនេះគឺចាត់ទុកថាជាមនុស្សល្អបំផុត ព្រោះនៅពេលដែលពួកគេទទួលបានចំណេះដឹងហើយ ពួកគេអាចប្រើវាឱ្យវាមាន ប្រយោជន៍សម្រាប់ខ្លួនឯង និងអ្នកដទៃបន្ថែមទៀត។

**មនុស្សប្រភេទទីពីរនេះ ត្រូវបានពិពណ៌នាដោយព្យាការីផងដែរ នោះគឺ ដូចជា ដីដែលរឹងស្ងួត គ្មានជីជាតិ តែអាចស្តុកទឹកភ្លៀង សម្រាប់មនុស្ស ដើម្បីប្រើប្រាស់ ឬសម្រាប់សត្វផឹក និងសម្រាប់ស្រោចស្រពដាំដុះផ្សេងៗ។**

អត្ថន័យនៅទីនេះគឺ សំដៅលើពួកគេមានចំណេះដឹង ហើយអនុវត្តតែខ្លួនគេប៉ុណ្ណោះ ប៉ុន្តែមិនបានចែករំលែក ឬផ្សព្វផ្សាយចំណេះដឹងដែលពួកគេមានដល់អ្នកដទៃឡើយ លុះត្រាតែមាននរណាម្នាក់ចូលទៅជិតពួកគេ ទើបអាចទទួលបានចំណេះដឹងពីពួកគេ។ ឬក៏អាចថា គេមានចំណេះដឹង ហើយចែករំលែកចំណេះដឹងរបស់ពួកគេដល់អ្នកដទៃ ប៉ុន្តែគេខ្លួនឯង មិនបានអនុវត្តតាមចំណេះដឹងនោះឡើយ។

**មនុស្សប្រភេទទីបី ព្យាការីបានប្រៀបធៀបទៅនឹងដីដែលគ្មាន ផ្តល់ផលប្រយោជន៍អ្វីសោះ គ្មានជីជាតិ សម្រាប់ដំណាំដាំដុះ ហើយក៏មិនអាចផ្ទុកទឹកសម្រាប់យកមកប្រើប្រាស់បានឡើយ។**

*ហាទីស ពូខរី ៧៩ និង មូស្លីម ២២៩២*

អត្ថន័យនៅទីនេះ គឺចង់សំដៅទៅលើអ្នកដែលមានឱកាសរៀនសូត្រ ស្វែងរកចំណេះដឹង តែពួកគេមិនបានប្រឹងប្រែងឈ្វេងយល់ ចងចាំ ឬអនុវត្តនោះឡើយ។ ដូច្នេះ ចំណេះដឹងនេះ គឺមិនបានផ្តល់ប្រយោជន៍ដល់រូបគេ ឬអ្នកដទៃឡើយ។

សូមបួងសួងទៅកាន់អល់ឡោះជាម្ចាស់ សូមទ្រង់ការពារពួកយើងពីក្រុមមនុស្សប្រភេទទីបីនេះផងចុះ។

ពន្លឺនៃការចង្អុលបង្ហាញនេះ ត្រូវបាននាំមកដោយបុរសម្នាក់ឈ្មោះ ជា មូហាំម៉ាត់ ដែលជាអ្នកនាំសាររបស់អល់ឡោះ ជាអ្នកសង្គ្រោះមនុស្សជាតិ ហើយដឹកនាំពួកគេចេញពីជ្រលងភ្នំនៃភាពគ្មានជំនឿ ទៅកាន់ជ្រលងនៃសេចក្តីជំនឿ។

អស់រយៈពេល២៣ឆ្នាំ លោកពិតជាមានការតស៊ូ និងនឿយហត់ជាខ្លាំងក្នុងការបំពេញតួនាទីរបស់លោកជាអ្នកនាំសាររបស់អល់ឡោះ ដោយការពង្រឹងនិងកំណែប្រព័ន្ធជំនឿរបស់មនុស្សជាតិ និងកែប្រែសីលធម៌មិនល្អ រហូតទាល់តែសាសនាមួយនេះ ត្រូវបានបំពេញដោយអល់ឡោះជាម្ចាស់។

អល់ឡោះមានបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

**ថ្ងៃនេះ យើងបានបំពេញសាសនារបស់ពួកអ្នកឱ្យពួកអ្នក និងបានបង្គ្រប់នូវនៀកម៉ាត់( លាភសក្ការៈ )របស់យើងឱ្យពួកអ្នក ហើយយើងបានជ្រើសរើសសាសនាអ៊ីស្លាមជាសាសនាសម្រាប់ពួកអ្នក។**

*គួរអាន អាល់ម៉ាអ៊ីតាស ៥ : ៣*

# អ្នកនាំសារដ៏ថ្លៃថ្លា

សាសនាអ៊ីស្លាម គឺជាមាគ៌ាទេសស័ក្ដិ៍ពេញលេញ និងទូលំទូលាយបំផុត សម្រាប់គ្រប់ទិដ្ឋភាពនៃជីវិតរបស់យើង។ ចំពោះអ្នកដែលធ្វើការស្រាវជ្រាវបានត្រឹមត្រូវ ច្បាស់ជានឹងរកឃើញថាគ្មានសាសនាណាមួយនៅលើផែនដីនេះ ដែលផ្ដល់ឱ្យមនុស្សនូវការណែនាំដ៏ម៉ត់ចត់ នៅគ្រប់ទិដ្ឋភាពនៃជីវិតបែបនេះនោះឡើយ លើកលែងតែសាសនាអ៊ីស្លាមមួយប៉ុណ្ណោះ។

សាសនាអ៊ីស្លាមតែមួយគត់ ដែលផ្ដល់នូវការណែនាំ ដែលគ្របដណ្ដប់នូវទំនាក់ទំនងរបស់មនុស្សជាមួយព្រះ ទាំងនៅក្នុងបញ្ហានៃជំនឿ និងការគោរពសក្ការៈ ក៏ដូចជាទំនាក់ទំនងរបស់មនុស្សជាមួយនឹងអ្វីផ្សេងទៀតដែលទ្រង់បានបង្កើត មិនថាជាមនុស្ស សត្វ ឬបរិស្ថានជុំវិញនោះទេ មាគ៌ាទេសស័ក្ដិ៍នេះ គឺពេញលេញបំផុត។ ប្រសិនបើយើងពិនិត្យមើលគោលការណ៍ និងសេចក្ដីណែនាំនៃសាសនមួយនេះ អំពីទំនាក់ទំនងរបស់មនុស្សជាតិ យើងនឹងឃើញថា សាសនាមួយនេះ បានគូសបញ្ជាក់ពីគោលការណ៍ និងកិច្ចណែនាំក្នុងការដោះស្រាយជាមួយមនុស្សគ្រប់ប្រភេទ មិនថាជាមួយអ្នកមូស្លីម មិនមែនមូស្លីម ជាមួយឪពុកម្ដាយ អ្នកជិតខាង គ្រួសារ ប្ដីប្រពន្ធ បុរស ស្ត្រី មិត្តភក្ដិ សត្រូវ កុមារ និងសូម្បីតែទារកជាដើម។

ជាក់ស្ដែង ក្នុងការណែនាំអំពីទំនាក់ទំនងជាមួយឪពុកម្ដាយ គឺមានការលើកឡើងជាច្រើនកន្លែងនៅក្នុងគម្ពីរគួរអាន និងក្នុងហាទីសរបស់ព្យាការី។ ក៏ដូចគ្នាដែរ នៅក្នុងទំនាក់ទំនងជាមួយអ្នកជិតខាង មានការណែនាំ និងការដាស់តឿនផ្សេងៗ ដើម្បីជានាបាននូវទំនាក់ទំនងជាមួយអ្នកជិតខាង ប្រកបដោយសុខដុមរមនា និងយូរអង្វែង។ ហើយសូម្បីតែជាមួយសត្រូវក្នុងសមរភូមិ ក៏អ៊ីស្លាមមានច្បាប់ និងក្រមសីលធម៌ ក្នុងការដោះស្រាយផងដែរ។ ចំពោះអ្នកដែលបានសិក្សាអំពីអ៊ីស្លាមបានទូលំទូលាយ ពួកគេពិតជាមិនអាចបដិសេធនូវភាពល្អឥតខ្ចោះនៃសាសនាមួយនេះបានឡើយ។

អ៊ីស្លាមជាសាសនាដែលបានបង្រៀនយ៉ាងច្បាស់ នូវគ្រប់ទិដ្ឋភាពនៃជីវិតមនុស្ស។ វាពិតជាការបាត់បង់ដ៏ធំធេង សម្រាប់អ្នកដែលមិនព្រមឈ្វេងយល់ ឬមិន

បានមើលឃើញពន្លឺនៃភាពឥតខ្ចោះរបស់សាសនាអ៊ីស្លាម ក៏ដូចជាអ្នកដែលបានព្យាយាមពន្លត់នូវពន្លឺមួយនេះ ដើម្បីរក្សាមនុស្សគ្រប់គ្នានៅក្នុងភាពងងឹតដោយសារតែពួកគេខ្លួនឯងជាប់នៅក្នុងទីងងឹត ដូច្នេះបើទោះបីជាពន្លឺនៅពីមុខពួកគេភ្លឺយ៉ាងណាក៏ដោយ ក៏ពួកគេមិនអាចទទួលបានពន្លឺនៃការចង្អុលបង្ហាញបាននោះឡើយ។

អល់ឡោះបានមានបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

**អ្នកណាហើយដែលស្វែងរកសាសនាផ្សេង ក្រៅពីសាសនាអ៊ីស្លាម នោះអល់ឡោះមិនទទួលយកទង្វើល្អពីគេឡើយ ហើយនៅថ្ងៃបរលោក រូបគេនឹងស្ថិតនៅក្នុងចំណោមពួកអ្នកដែលខាតបង់ជាមិនខាន។**

*គួរអាន អាលីអ៊ីមរ៉ន ៣ : ៨៥*

ក្នុងនាមជាអ្នកដែលកើតមកជាមូស្លីម ឬអ្នកដែលទទួលបាននូវការចង្អុលបង្ហាញពីអល់ឡោះ យើងគួរអរព្រះគុណ ដែលសាររបស់ព្យាការីបានមកដល់យើងក្នុងសម័យទំនើបដូចសព្វថ្ងៃនេះ ដែលអាចឱ្យយើងទទួលបាននូវចំណេះដឹង និងអាចទទួលនូវព័ត៌មានបានយ៉ាងងាយស្រួល។ គ្រាន់តែធ្វើការសិក្សា ស្រាវជ្រាវ ឈ្វេងយល់ប៉ុណ្ណោះ ហើយបន្ទាប់ពីមានចំណេះដឹង និងមានជំនឿ ចាំបាច់យើងត្រូវអនុវត្ត និងចែករំលែកវា ដើម្បីផ្តល់ជាអត្ថប្រយោជន៍ដល់មនុស្សជាតិគ្រប់រូប។

# គម្ពីរគួរអាន
# គឺជាអព្ភូតហេតុ
# (មួកជីសាត់)

គួរអាន គឺជាអព្ភូតហេតុដ៏អស្ចារ្យបំផុត ដែលអល់ឡោះបានប្រទានដល់ព្យាការីមូហាំម៉ាត់ ដោយលោកមានសមត្ថភាពក្នុងការប្រៀនប្រដៅមនុស្ស និងធ្វើឱ្យពួកគេបេះបន្ទាបខ្លួនពីទិដ្ឋភាពជាច្រើន ដែលមានដូចជា ភាសាវិទ្យា របនាសម្ព័ន្ធប្រភពបំណេះដឹង គតិបណ្ឌិត និង ១០០១ ប្រភេទផ្សេងគ្នា នៃអព្ភូតហេតុ ដែលបង្ហាញពីការពិតនៃព្រះដែលព្យាការីមូហាំម៉ាត់បាននាំមក។

ជាការពិតណាស់ រហូតមកដល់សព្វថ្ងៃនេះ បន្ទូលនៃព្រះជាម្ចាស់ ក៏កំពុងត្រូវបានសិក្សានៅឡើយ។ អាថ៌កំបាំងរបស់វានៅតែបើកបង្ហាញឱ្យឃើញ ប្រៀបដូចជាអព្ភូតហេតុនៃធម្មជាតិ ដែលកើតឡើងមិនចេះចប់ ឬប្រៀបដូចត្បូងពេជ្រដែលនៅតែកំពុងត្រូវបានគេជីកកកាយរក។

អល់ឡោះមានបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

**តើពួកគេមិនបានគិតពិចារណាអំពី(អត្ថន័យ)នៃគម្ពីរគួរអានទេឬ? ឬនៅក្នុងចិត្តរបស់ពួកគេត្រូវបិទជិត(មិនយល់អ្វីសោះអំពីគម្ពីរគួរអាន)?**

*គួរអាន មូហាំម៉ាត់ ៤៧ : ២៤*

ដួងចិត្តដែលគ្មានការឈ្វេងយល់ពីគួរអាន គឺស្រដៀងទៅនឹងទ្វារដែលបិទជិត ចាក់សោយ៉ាងក្រាស់ ទោះបីជាគួរអាន គឺជាថ្នាំ និងជាការណែនាំ ដើម្បីឱ្យមនុស្សបានចេញពីភាពងងឹតក៏ដោយ។

នៅក្នុងគួរអាន ផ្ទុកនូវបំណេះដឹងគ្រប់ប្រភេទ ដែលមានសារៈសំខាន់បំផុតសម្រាប់យើងយកមកអនុវត្តនៅក្នុងជីវិត។ ហើយការសូត្រគួរអាន ដោយមិនទាន់បានយល់អំពីអត្ថន័យរបស់វា ក៏អាចទទួលបានផលបុណ្យដ៏អស្ចារ្យផងដែរ។

ព្យាការីបានមានប្រសាសន៍ ដោយមានអត្ថន័យថា៖

**អ្នកណាហើយ សូត្រមួយអក្សរ នៃគម្ពីរអល់ឡោះ(គួរអាន) អ្នកនោះនឹងទទួលបានផលបុណ្យ១ ហើយ១នោះនឹងក្លាយជា១០ដង។ ដូច្នេះអ្នកណាដែលសូត្រ ពាក្យ (الم) អាលេហ្វ ឡាម មីម អ្នកនោះនឹងទទួលបានផលបុណ្យចំនួន ៣០។**

*ហាទីស អាល់តៀរមីហ្ស៊ី (អាល់ម៉ាហ្វាទាសហ៍ ហ្វីសើរម៉ាសាពាសហ៍ ៣:៨៤)*

សូម្បីតែអ្នកដែលកំពុងរៀនអាន ហើយព្យាយាមសូត្រគម្ពីរដ៏ពិសិដ្ឋនេះ ក៏នឹងទទួលបានផលបុណ្យជាច្រើនផងដែរ។ ដូចដែលព្យាការីមានប្រសាសន៍ថា៖

**អ្នកដែលស្ទាត់ជំនាញនៅក្នុងការសូត្រគម្ពីរគួរអាន នឹងត្រូវបានផ្សារភ្ជាប់ជាមួយនឹងពពួកទេវតាដែលកត់ត្រាអំពើសុចរិតដ៏ថ្លៃថ្នូរ ហើយអ្នកណាដែលពិបាក(ភ្លាត់ភ្លាំង ឬទាក់ៗ) ពេលសូត្រគម្ពីរគួរអាន នឹងទទួលបានផលបុណ្យទ្វេដង។**

*ហាទីស មូស្លីម ៧៩៨*

ចូរសូត្រគម្ពីរគួរអាន ហើយរក្សាខ្លួនឱ្យជិតព្រះបន្ទូលជានិច្ច ព្រោះវានឹងនាំឱ្យខ្លួនយើង ខិតជិតក្តីមេត្តាករុណានៃទ្រង់ វាជាសេចក្តីពិត និងជាសាររបស់ព្រះជាម្ចាស់ ហើយក៏អាចជួយសង្គ្រោះយើងនៅថ្ងៃបរលោកផងដែរ។ ដោយវាជាថ្ងៃដែលយើងគ្រប់គ្នាត្រូវការជំនួយខ្លាំងបំផុត។

ព្យាការីបានមានប្រសាសន៍ថា៖

**ចូរសូត្រគួរអាន ព្រោះគួរអាននឹងជួយអន្តរាគមន៍**
**ដល់អ្នកដែលបានសូត្រវា នៅថ្ងៃបរលោក។**

*ហាទីស មូស្លីម ៨០៤*

ប៉ុន្តែការសូត្រគម្ពីរគួរអាន ដោយមិនគោរពប្រតិបត្តិតាមសេចក្ដីណែនាំនៃគម្ពីរគួរអាននោះ ក៏មិនគ្រប់គ្រាន់ដើម្បីទទួលបានអត្ថាគមន៍អំពីគម្ពីរគួរអាននោះឡើយ។ ផ្ទុយទៅវិញ គួរអាននឹងក្លាយជាភស្តុតាងប្រឆាំងនឹងរូបគេវិញនៅថ្ងៃនោះ(ថ្ងៃបរលោក)។

គម្ពីរគួរអានមួយនេះ ត្រូវបានបញ្ចុះជាភាសាអារ៉ាប់ ជាភាសាដែលស្ទាត់ជំនាញដោយក្រុមគូរ៉ាយស៍។ ភាពស្ទាត់ជំនាញនៃអក្សរសិល្ប៍អារ៉ាប់ ទាំងភាសានិងច្បាប់ ត្រូវបានគេចាត់ទុកថាល្អបំផុតគ្រប់ពេលវេលា។ ទោះយ៉ាងណាក៏ដោយដួងចិត្តរបស់ពួកគេបានចាប់ចិត្ត និងបានទាក់ទាញដល់ដួងព្រលឹងរបស់ពួកគេនៅពេលដែលពួកគេបានស្ដាប់គួរអាន។

ទោះបីភាសានៃគម្ពីរគួរអាន មានភាពស្រស់ស្អាតយ៉ាងណាក៏ដោយ ប៉ុន្តែដោយសារភាពក្រអឺតក្រទមរបស់ពួកគេ វាបានរារាំងពួកគេទាំងស្រុង មិនឱ្យទទួលយកគម្ពីរគួរអាន។ ប្រសិនបើពួកគេអះអាងថា មូហាំម៉ាត់គឺជាកវី ដែលបានសរសេរគម្ពីរគួរអានដោយខ្លួនឯង គឺវាមិនអាចទៅរួចឡើយ ព្រោះគម្ពីរគួរអាន មិនដូចកម្រងនៃកំណាព្យនោះឡើយ។ លើសពីនេះ ព្យាការីមូហាំម៉ាត់ ជាអនក្ខរជន (មិនចេះអាននិងសរសេរ) តើលោកមានសមត្ថភាពឯណា ក្នុងការសរសេរកំណាព្យដែលត្រូវពិចារណា និងថ្លឹងថ្លែង អំពីទម្រង់អក្សរសាស្ត្រដ៏ត្រចះត្រចង់បំផុតនៃពិភពអារ៉ាប់នាសម័យនោះ?

# បុគ្គល
# ពោរពេញដោយជំនាញ
# និងទេព្យកោសល្យចម្រុះ

មូហាំម៉ាត់ គឺជាគំរូដ៏ល្អឥតខ្ចោះ និងពោរពេញដោយទេព្យកោសល្យ។ ដោយយើងនឹងមិនអាចរកឃើញព្យាការីមុនៗណាម្នាក់ ដែលមានសមត្ថភាពដូចលោកក្នុងការចាត់ចែងគ្រប់យ៉ាងក្នុងពេលតែមួយនោះទេ។ ព្យាការីគឺជាស្វាមីផង និងជាឪពុកផង។ មិនមែនព្យាការីទាំងអស់បានរៀបការ ហើយក៏មិនមែនព្យាការីទាំងអស់ក្លាយជាឪពុកគេនោះឡើយ។ ឧទាហរណ៍ ព្យាការីខ្លះគឺនៅលីវ ដូចជាព្យាការី យ៉ះយ៉ា(យ៉ូហាន)ជាដើម។

លើសពីនេះ នៅក្នុងសមរភូមិ ព្យាការីគឺជាមេបញ្ជាការផង ជាឧត្តមសេនីយ៍ផង និងជាអ្នកចម្បាំងផងដែរ។ លោកមានភាពអង់អាចក្លាហាន មានគតិបណ្ឌិត និងមានយុទ្ធសាស្ត្រច្បាស់លាស់។ មានការប្រយុទ្ធរាប់សិបដង ដែលត្រូវបានដឹកនាំដោយលោកផ្ទាល់ និងប្រតិបត្តិការប្រយុទ្ធជាច្រើនទៀតដែលត្រូវបានចាត់ចែង និងរៀបចំយុទ្ធសាស្ត្រដោយលោក។ មិនមែនព្យាការី និងអ្នកនាំសារទាំងអស់មានឱកាសប្រយុទ្ធក្នុងសមរភូមិ ឬដឹកនាំប្រតិបត្តិការយោធាដូចលោកនោះទេ។

ព្យាការី ក៏ជាអ្នកអប់រំ និងទូន្មានដ៏មានទេពកោសល្យម្នាក់ ដែលមនុស្សគ្រប់វ័យ តែងតែយកលោកធ្វើជាគំរូ។ ភាពអត់ធ្មត់ ប្រាជ្ញាស្មារតី វិធីសាស្ត្រក្នុងការទំនាក់ទំនង និងបែករំលែករបស់លោក ត្រូវបានទុកជាឯកសារយោង និងជាមូលដ្ឋាននៃការសិក្សា នៅក្នុងវិស័យអប់រំ និងទំនាក់ទំនងនានា។ ព្យាការីក៏ជាមេដឹកនាំដ៏ឈ្លាសវៃម្នាក់ផងដែរ។ លោកបានទទួលជោគជ័យក្នុងការរៀបចំទឹកដីម៉ាទីណះ ពីរដ្ឋមួយដែលពោរពេញទៅដោយការបង្ហូរឈាម ដោយសារសង្គ្រាមស៊ីវិលរវាងកុលសម្ព័ន្ធធំៗទាំងពីរ(អាហ្វ និង ខោសស្រុប) ទៅរដ្ឋមួយដែលមានការរួបរួមយ៉ាងរឹងមាំ។ រដ្ឋដែលធ្លាប់ត្រូវបានសង្កត់សង្កិន ផ្នែកសេដ្ឋកិច្ចផ្ដាច់មុខដោយកុលសម្ព័ន្ធយ៉ាហ៊ូទ(យូដា) បានក្លាយជារដ្ឋ ដែលមានប្រព័ន្ធសេដ្ឋកិច្ចល្អប្រសើរ មានរចនាសម្ព័ន្ធទីផ្សារ និងអាជីវកម្ម។ មានការតស៊ូមតិសម្រាប់អាជីវកម្ម និងកសិកម្ម លុបបំបាត់ភាពក្រីក្រ និងការអនុវត្តន៍ហ្សាកាហ្វ(ទាយជូទាន)។

គួរបញ្ជាក់ផងដែរថា៖ កុលសម្ព័ន្ធយ៉ាហ៊ូទ (យូដា) ដែលមានឥទ្ធិពលបំផុតនៅក្រុងម៉ាទីណះ មុនពេលហ៊ីជរ៉ោះ (ការធ្វើចំណាកស្រុក) របស់ព្យាការីមូហាំម៉ាត់ មានបីគឺ៖ កុលសម្ព័ន្ធប៉ានីគូរ៉ាយសោះ កុលសម្ព័ន្ធប៉ានីកុយណាកក និងកុលសម្ព័ន្ធប៉ានីណាទៀរ។

# បុគ្គលដែលមាន
# ភាពពេញលេញ
# ជាមនុស្សជាតិ

រ៉ស៊ូលុលឡោះ គឺជាទីស្រលាញ់នៃអល់ឡោះ ដោយទ្រង់បានប្រទានជូនលោក នូវឋានៈដ៏ខ្ពង់ខ្ពស់បំផុតនៅក្នុងស្ថានសួគ៌។ ទោះជាយ៉ាងណា លោកមិនដែលមានអំនួតលើខ្លួនឯងឡើយ បើទោះបីជារូបលោក ទទួលបានការពេញចិត្តពីព្រះជាម្ចាស់យ៉ាងនោះក្តី។ លោកត្រូវបានគេស្គាល់យ៉ាងច្បាស់ អំពីភាពរាបសារ និងការមានវិន័យលើខ្លួនឯងរបស់លោក។ លោកមិនចូលចិត្តឡើយ នៅពេលដែលសហការីរបស់លោក ឬអ្នកណាម្នាក់ គោរពលោកលើសពីអ្វីដែលលោកមាន។ នៅក្នុងហាទីសមួយ ព្យាការីបានមានប្រសាសន៍ថា៖

**ចូរកុំបំផ្លើសក្នុងការសរសើរខ្ញុំ ដូចដែលគ្រិស្តបរិស័ទសរសើរកូនប្រុសរបស់ម៉ារី (ព្យាការីអ៊ីសា) ឱ្យសោះ។ សម្រាប់ខ្ញុំគ្រាន់តែជាខ្ញុំបម្រើរបស់ទ្រង់តែប៉ុណ្ណោះ។ ចូរហៅខ្ញុំថា អ្នកបម្រើរបស់អល់ឡោះ និងជាអ្នកនាំសាររបស់ទ្រង់បានហើយ។**

*ហាទីស ពូខរី ៣៤៤៥*

ការលើកតម្កើងរបស់គ្រិស្តបរិស័ទចំពោះព្យាការីអ៊ីសានោះ គឺហួសព្រំដែន ដោយសារពួកគេបានអះអាងថាលោក គឺជាកូនប្រុសរបស់អល់ឡោះជាម្ចាស់។

ព្យាការីក៏មិនពេញចិត្ត ឱ្យសហការីរបស់លោកក្រោកឈរគោរពលោកនោះទេ គ្រប់ពេលដែលលោកមកជួបជុំពួកគេ។ ប៉ុន្តែសព្វថ្ងៃនេះវាបានក្លាយជាទម្លាប់សម្រាប់អ្នកចូលរួមក្នុងពិធីជួបជុំណាមួយ ត្រូវក្រោកឈរឡើងជាសញ្ញានៃការគោរព គ្រប់ពេលដែលមានបុគ្គលសំខាន់ ឬបុគ្គលលេចធ្លោ មកដល់ក្នុងកម្មវិធី។ អ្នកខ្លះមានអារម្មណ៍ថាមានមោទនភាព និងសប្បាយចិត្តនៅពេលបានគេផ្តល់កិត្តិយស និងការគោរពបែបនេះ។ មានពេលមួយនោះ សហការីរបស់លោក បានក្រោកឈរឡើងដើម្បីគោរពលោក ប៉ុន្តែលោកបានហាមឃាត់ពួកគេមិនឱ្យធ្វើដូច្នេះឡើយ។ ផ្ទុយទៅវិញ លោកបានបង្គាប់ឱ្យពួកគេអង្គុយចុះ ព្រោះមិនចង់បានការគោរព ឬផ្តល់កិត្តិយសតាមរបៀបនោះនោះឡើយ។

ការគោរពចំពោះព្យាការីមូហាំម៉ាត់ អាចធ្វើទៅបានមិនឱ្យលើសពីអ្វីដែលបានកំណត់ដោយអល់ឡោះឡើយ ដូចជា ការពារភាពស្អាតស្អំរបស់លោក រក្សាសុជីវធម៌ និងអាកប្បកិរិយាល្អជាមួយលោក ហើយនិងការពារភាពបរិសុទ្ធនៃហាទីស ឬស៊ុណ្ណះរបស់លោក ក៏ដូចជាអនុវត្តន៍តាមអ្វីដែលលោកបានបង្គាប់ប្រើជាដើម។ អល់ឡោះមានបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

**ចូរអ្នក(មូហាំម៉ាត់)ពោលថា៖ ខ្ញុំក៏ជាមនុស្សលោកដូចពួកអ្នក**
**រាល់គ្នាដែរ គ្រាន់តែទ្រង់បានផ្តល់វ៉ាហ៊ីមកឱ្យខ្ញុំតែប៉ុណ្ណោះ...។**

*គួរអាន អាល់កះហ្វិ ១៨:១១០*

នេះបានបញ្ជាក់ថា លោកគឺជាមនុស្សធម្មតា ដែលមានសេចក្តីត្រូវការសេចក្តីប៉ងប្រាថ្នា និងមានអាយុកាលដូចគ្នានឹងមនុស្សទូទៅដែរ។ គ្រាន់តែអល់ឡោះបានលើកឋានៈរបស់លោកជាងអ្នកដទៃ ដោយបានតែងតាំងលោក ជាព្យាការី និងជាអ្នកនាំសារ ដែលទ្រង់បានប្រទានវិវរណៈ(វ៉ាហ៊ី)តែប៉ុណ្ណោះ។

ប្រសិនបើព្យាការីចង់បានអំណាច និងឋានៈ នោះលោកអាចទទួលបានយ៉ាងងាយស្រួលនូវអំណាច និងឋានៈអ្វីក៏ដោយដែលលោកចង់បាន។ ប៉ុន្តែនោះមិនមែនជាអ្វីដែលលោកចង់បាននោះឡើយ ដោយលោកដឹងច្បាស់ថា សម្ភារៈលោកិយនេះគឺតិចតួចណាស់ បើប្រៀបធៀបទៅនឹងភាពត្រចះត្រចង់ និងសុភមង្គលនៅថ្ងៃបរលោក។

ក្នុងដំណាក់កាលដំបូងនៃសាសនាអ៊ីស្លាមនៅម៉ាក្កះ ក្រុមនៃអ្នកដែលស្ទីរិក (ពហុទេពនិយម) មកពីគូរ៉ាយស៍ បានជួបព្យាការី និងបានព្យាយាមចរចាគ្នាជាមួយលោក ហើយបានសន្យាថានឹងផ្តល់តំណែងជូនលោក បើសិនជាលោកព្រមតាមពួកគេ ដោយពួកគេនិយាយថា៖ បើអ្នកចង់ធ្វើជាស្តេច យើងនឹងតាំងអ្នកជាស្តេចរបស់យើង បើអ្នកចង់បានទ្រព្យសម្បត្តិ យើងនឹងផ្តល់ឱ្យអ្នកនូវទ្រព្យសម្បត្តិរបស់យើងទាំងអស់!

តើអ្វីទៅជាចម្លើយរបស់ព្យាការី ចំពោះពាក្យល្បួងនៃពួកគេ ដោយការផ្ដល់ជូនទាំងអស់នោះ ?

ទេ! ព្យាការីបានបដិសេធការផ្ដល់ជូនទាំងអស់នោះ ហើយបានជ្រើសរើសបន្តបេសកកម្មរបស់លោក ក្នុងការផ្សព្វផ្សាយសាររបស់អល់ឡោះ ដើម្បីសម្រេចបាននូវភាពជោគជ័យ និងសុភមង្គលជាអមតៈនៅក្នុងឋានសួគ៌។

បាទ! លោកនឹងអាចក្លាយជាអ្នកដែលមានទ្រព្យសម្បត្តិដ៏ស្ដុកស្ដម្ភ ប្រសិនបើលោកបានជ្រើសរើសធ្វើដូច្នេះ ប៉ុន្តែលោកបានជ្រើសរើសជីវិតរស់នៅដោយសាមញ្ញជីវិតដែលមានភាពស្កប់ស្កល់នូវអ្វីដែលខ្លួនមាន ព្រោះទ្រព្យសម្បត្តិក្នុងលោកនេះ គ្រាន់តែជាការលម្អ និងការត្រេកត្រអាលនឹងខ្លួនឯងប៉ុណ្ណោះ។ ចំណែកទ្រព្យសម្បត្តិពិតប្រាកដនោះ គឺនៅថ្ងៃបរលោក ដ៏សម្បូរហូរហៀរ ដែលកើតចេញពីផលបុណ្យដែលអល់ឡោះទ្រង់ព្រះប្រទាន។

ក្នុងហាទីសមួយព្យាការីលោកបានមានប្រសាសន៍ថា៖

**ភាពមានបាន មិនមែនជាការដែលមានទ្រព្យសម្បត្តិហូរហៀរនោះទេ ផ្ទុយទៅវិញ វាគឺជាការចេះស្កប់ស្កល់ចំពោះអ្វីដែលខ្លួនឯងមាន។**

*ហាទីស ពូខរី ៦៤៤៦*

ទោះបីជាអល់ឡោះបានប្រគល់ឯកសិទ្ធិដល់ព្យាការី ក្នុងការទទួលបានមួយភាគប្រាំនៃជ័យភណ្ឌ (ទ្រព្យដែលទទួលបានពីការឈ្នះសង្គ្រាម) ក៏ពិតមែនតែយើងធ្លាប់ឮថា ជីវិតរបស់លោកពោរពេញដោយទ្រព្យសម្បត្តិដែរឬទេ?

មិនមែនមានន័យថា យើងត្រូវបានបង្គាប់ឱ្យរស់នៅក្នុងភាពក្រីក្រនោះឡើយ។ ជាក់ស្ដែងព្យាការី ក៏បានបួងសួងដល់អល់ឡោះ ឱ្យរួបលោកជៀសឆ្ងាយពីភាពទុរគតផងដែរ។ ដូចដែលមានក្នុងហាទីសខាងក្រោមនេះ៖

**បពិត្រអល់ឡោះជាម្ចាស់! សូមទ្រង់បញ្ចៀសរូបខ្ញុំ ពីភាពក្រីក្រទុរគត ហើយសូមទ្រង់មេត្តាការពាររូបខ្ញុំ អំពីការបំពានទៅលើអ្នកដទៃ ឬរងការបំពានពីអ្នកដទៃផង។**

*ហាទីស អាពូដាវូឌ ១៥៤៤*

តែក្នុងនាមជាអ្នកនាំសារ និងជាអ្នកដឹកនាំគំរូម្នាក់ លោកមានអារម្មណ៍ថា មិនស័ក្តិសមសម្រាប់ឱ្យលោករស់នៅក្នុងភាពប្រណិតឡើយ ព្រោះវានឹងបណ្តាលឱ្យមានការសង្ស័យលើចេតនារបស់លោក នៅក្នុងបេសកកម្មផ្សព្វផ្សាយសាររបស់អល់ឡោះជា ដើម្បីតែទទួលបានអំណាច និងទ្រព្យសម្បត្តិប៉ុណ្ណោះ។

# បុគ្គល
# ដែលគេស្គាល់ថា
# មានចិត្តសប្បុរសបំផុត

យើងតែងតែបានស្តាប់ឮជាញឹកញាប់ អំពីចិត្តសប្បុរសរបស់បុគ្គលមួយចំនួន ដែលយើងស្គាល់ដោយផ្ទាល់ ឬដោយប្រយោល។ ហើយនៅពេលដែលយើងសិក្សាអំពីប្រវត្តិសាស្រ្តអ៊ីស្លាម ក៏គេតែងតែប្រាប់យើងអំពីសេចក្ដីសប្បុរសរបស់សហការីជាច្រើន ដូចជា អាពូប៉ាកើរ អ៊ូមើរ និង អាប់ទុលរ៉សម៉ាន ពិន អោហ្វ ជាដើម។ ប៉ុន្តែយើងតែងតែភ្លេចក្រឡេកមើលទៅបុរសម្នាក់ ដែលមានឈ្មោះថា មូហាំម៉ាត់ ដែលមានចិត្តសប្បុរសជាងសប្បុរសជនដទៃទៀត គ្រប់ពេលទាំងអស់។

ជារឿយៗ លោកបានលើកទឹកចិត្តប្រជាជាតិរបស់លោក ឱ្យបេះដួយអ្នកផ្សេង ចែករំលែកលាភដែលអល់ឡោះបានប្រទាន ជាមួយអ្នកដែលមានតម្រូវការ ហើយចំណាយទ្រព្យសម្បត្តិរបស់ពួកគេតាមមាគ៌ារបស់ទ្រង់។

ដូចមានការលើកឡើងក្នុងហាទីសមួយថា៖

**ព្យាការីគឺជាមនុស្សដែលមានចិត្តសប្បុរសបំផុត! ហើយលោកកាន់តែមានភាពសប្បុរសជាងមុនទៀត នៅក្នុងខែរ៉ម៉ាទន។ ដោយសេចក្ដីសប្បុរសរបស់លោកលឿនជាងភ្លៀងខ្យល់ ដែលបក់យ៉ាងលឿននោះទៅទៀត។**

*ហាទីស ពូខរី ៣៥៥៤*

អត្ថន័យនៃហាទីសនេះ គឺចង់បញ្ជាក់ប្រាប់យើងថា៖ ព្យាការីគឺជាមនុស្សដែលសប្បុរសបំផុត លោកមិនដែលស្ទាក់ស្ទើរ ក្នុងការបំពេញតម្រូវការដល់អ្នកណាដែលមករកលោក ដើម្បីសុំជំនួយនោះឡើយ។

ក្នុងហាទីសមួយផ្សេងទៀត៖ មានបុរសម្នាក់បានមករកលោក ដើម្បីសុំជំនួយ ហើយព្យាការីក៏បានផ្ដល់អំណោយខ្លះដល់គេ។ បន្ទាប់មកគាត់បានក៏មកសុំបន្ថែមទៀតជាលើកទីពីរ ហើយលោកក៏បន្តផ្ដល់ឱ្យគាត់ទៀត ដោយក្ដីស្រលាញ់ចំពោះបុរសម្នាក់នោះ។ បន្ទាប់មកគាត់ក៏បានមកជាលើកទីបីម្ដងទៀត ក្នុងគោលបំណងដូចមុន ហើយលោកក៏បានមានប្រសាសន៍ទៅកាន់គាត់ថា៖ ខ្ញុំគ្មាននៅសល់

អ្វីទៀតទេ ប្រសិនបើខ្ញុំមានអ្វីដែលអ្នកត្រូវការ ខ្ញុំនឹងផ្តល់ឱ្យវាដល់អ្នក ប៉ុន្តែឥឡូវនេះ អ្វីដែលខ្ញុំអាចផ្តល់ឱ្យអ្នកគឺជាដំបូន្មាន...។

ដំបូន្មាននោះ បានធ្វើឱ្យគាត់បានយល់ និងបានប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ ហេតុធ្វើឱ្យរូបគាត់ឈប់សុំជំនួយពីអ្នកដទៃទៀត។ ថែមទាំងរូបគាត់មិនទទួលយកទ្រព្យដែលគាត់មានសិទ្ធិក្នុងការទទួលបានពីការចូលរួមប្រយុទ្ធក្នុងសង្គ្រាមឡើយ នៅក្នុងសម័យកាលដែលដឹកនាំដោយ អាពូប៉ាកើរ និងអូមើរ ពីព្រោះគាត់ចង់រក្សាការពារបេះដូងរបស់គាត់ពីការរំពឹងចង់បានអ្វីមួយពីអ្នកដទៃ។

ពេលខ្លះយើងអាចមានអារម្មណ៍ភ្ញាក់ផ្អើល និងឆ្ងល់ថា តើព្យាការីអាចបរិច្ចាគទ្រព្យសម្បត្តិទាំងអស់របស់លោក ដោយមិនស្ទាក់ស្ទើរបានដោយរបៀបណា ហាក់ដូចជាលោកគ្មានបំណងប្រាថ្នាតិចតួចទាល់តែសោះ ចំពោះទ្រព្យសម្បត្តិ និងសម្ភារៈទាំងនោះ? ប៉ុន្តែប្រសិនបើយើងដឹងថា នៅពេលដែលឋានសួគ៌ និងអ្វីៗទាំងអស់ដែលអល់ឡោះបានសន្យាសម្រាប់រូបលោក និងប្រជាជាតិរបស់លោកត្រូវបានបង្ហាញឱ្យលោកបានឃើញ ក្នុងអំឡុងពេលព្រឹត្តិការណ៍ អ៊ីសរ៉ក និងមាយរ៉ជ (ដំណើរឡើងទៅលើមេឃរបស់ព្យាការីមូហាំម៉ាត់ដើម្បីទទួលកាតព្វកិច្ចសឡាតថ្វាយបង្គំ) ដែលពោរពេញដោយភាពស្រស់ស្អាត ដែលមិនអាចនឹងពណ៌នាបាននោះ។ យើងនឹងដឹងថា លោកពិតជាមានអារម្មណ៍ថាសេចក្តីរីករាយនៃពិភពលោកនេះ និងអ្វីៗទាំងអស់នៅទីនេះ គឺគ្មានតម្លៃអាចប្រៀបផ្ទឹមទៅនឹងភាពរីករាយនៃស្ថានសួគ៌បានឡើយ ហើយភាពលំបាកនៅក្នុងលោកិយនេះ គឺគ្មានអ្វីអាចប្រៀបធៀបទៅនឹងភាពភ័យខ្លាច និងវេទនានៃនរកនោះទេ។

លោកជឿជាក់ និងយល់យ៉ាងច្បាស់ថា រាល់ប្រតិបត្តិការជាមួយអល់ឡោះនឹងមិនបណ្តាលឱ្យមានការខាតបង់ឡើយ ព្រោះទ្រង់បានធានានូវការប្រទានផលបុណ្យត្រឡប់មកវិញយ៉ាងជាក់ច្បាស់។

អល់ឡោះមានព្រះបន្ទូលថា៖

**ហើយអ្វីដែលពួកអ្នកបានបរិច្ចាគនោះ ទោះបីតិចតួចក៏ដោយ គឺទ្រង់នឹងតបស្នងមកវិញ ហើយទ្រង់ជាអ្នកប្រទានលាភសក្ការៈដ៏ល្អបំផុត។**

*គួរអាន អាល់សាប៉ាក់ ៣៤ : ៣៩*

ហើយព្យាការីក៏បានមានប្រសាសន៍ អំពីការធ្វើនូវសប្បុរសធម៌ដែរថា៖ សប្បុរសធម៌មិនបានធ្វើឱ្យទ្រព្យសម្បត្តិនោះថយចុះនោះឡើយ។ ប៉ុន្តែតើយើងប៉ុន្មាននាក់ ដែលមានជំនឿលើរឿងនេះ? តើមានប៉ុន្មាននាក់ដែលជឿលើការសន្យានេះ? បើយើងលះបង់ទ្រព្យសម្បត្តិរបស់យើងខ្លះ សម្រាប់ធ្វើការបរិច្ចាគ ឬសប្បុរសធម៌ នោះទ្រព្យសម្បត្តិរបស់យើងនឹងត្រូវកាត់បន្ថយ។ នោះជាមូលដ្ឋានគ្រឹះនៃការគណនាក្នុងគណិតវិទ្យា ប៉ុន្តែនៅក្នុងការគណនារបស់ព្យាការីគឺ៖

**ពិតប្រាកដណាស់ អល់ឡោះ គឺជាអ្នកដែលប្រទាននូវលាភសក្ការៈគ្រប់យ៉ាង។**

*គួរអាន អាល់ស៊ូរីយ៉ាត ៥១ : ៥៨*

ដូចគ្នាដែរ ប្រសិនបើយើងស្វែងយល់ពីជីវប្រវត្តិសហការីរបស់លោក យើងនឹងឃើញថា តើពួកគេមានសេចក្តីសប្បុរសធម៌ និងមនុស្សធម៌ប៉ុណ្ណា។ ជាពិសេសនៅក្នុងស្ថានភាពតានតឹង ឬសម្រាប់បុព្វហេតុសាសនា។ ប្រៀបដូចជាទ្រព្យសម្បត្តិរបស់ពួកគេត្រូវបានដាក់នៅលើបាតដៃរបស់ពួកគេ ងាយស្រួលឱ្យទៅអ្នកដែលមានតម្រូវការលូកយកគ្រប់ពេលវេលា។មានពេលមួយនោះ ដែលទាហានអ៊ីស្លាមត្រូវការជំនួយផ្នែកសេដ្ឋកិច្ចជាខ្លាំង ស្ទើរគ្មានសង្ឃឹម ដោយសារស្ថានភាពលំបាកនៅពេលនោះ ដែលធ្វើឱ្យព្យាការីសម្តែងនូវការព្រួយបារម្ភជាខ្លាំងអំពីរឿងនេះ ហើយបានបញ្ជាឱ្យសហការីរបស់លោកធ្វើការបរិច្ចាគ។ ពេលនោះ អូមើរ បាន

បរិច្ចាគពាក់កណ្ដាលនៃទ្រព្យសម្បត្តិទាំងអស់របស់គាត់។ វាស្មើរតែមិននឹកស្មានដល់ សម្រាប់យើងរាល់គ្នានាពេលបច្ចុប្បន្ននេះ ដែលស្ម័គ្រចិត្តផ្ដល់ទ្រព្យសម្បត្តិពាក់កណ្ដាលរបស់យើង តាមមាគ៌ារបស់អល់ឡោះ។ បន្ទាប់ពីនោះ អូមើរ បានឃើញអាពូប៉ាកើរ ផ្ដល់ទ្រព្យសម្បត្តិរបស់គាត់។ ដោយលោកគិតថា ចិត្តសប្បុរសរបស់លោក នឹងអាចលើសពីចិត្តសប្បុរសរបស់កល្យាណមិត្តរបស់គាត់។ ប៉ុន្តែជាក់ស្ដែង អាពូប៉ាកើរ បានផ្ដល់ទ្រព្យសម្បត្តិរបស់គាត់ទាំងអស់។

បន្ទាប់មក ព្យាការីបានសួរអាពូប៉ាកើរថា៖ តើអ្នកទុកអ្វីសម្រាប់គ្រួសាររបស់អ្នក? អាពូប៉ាកើរ បានឆ្លើយតបថា៖ ខ្ញុំទុកអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់សម្រាប់ពួកគេ។ ពេលឮចម្លើយរបស់អាពូប៉ាកើរ អ៊ូមើរក៏បាននិយាយថា៖ ដោយអល់ឡោះជាម្ចាស់! គ្រប់យ៉ាងទាំងអស់ ដែលខ្ញុំមិនអាចយកឈ្នះគាត់បានឡើយ។

# បុគ្គល
# ដែលមិនចេះនឿយហត់
# ក្នុងការជំរុញលើកទឹកចិត្ត
# អ្នកដទៃឱ្យប្រព្រឹត្តអំពើល្អ

រ៉ស៊ូលុលឡោះ គឺជាបុគ្គលម្នាក់ដែលតែងតែជំរុញលើកទឹកចិត្តដល់ប្រជាជាតិរបស់លោក ឱ្យប្រព្រឹត្តអំពើល្អចំពោះអ្នកដទៃ ព្រោះអ៊ីស្លាមគឺជាសាសនាដ៏ល្អប្រពៃ និងពោរពេញដោយក្តីមេត្តាករុណា។

**អ្នកណាហើយ ដែលមានជំនឿលើអល់ឡោះ និងថ្ងៃបរលោក**
**ចូរឱ្យគេធ្វើល្អចំពោះអ្នកជិតខាង។**
**អ្នកណាហើយ ដែលមានជំនឿលើអល់ឡោះ និងថ្ងៃបរលោក**
**ចូរឱ្យគេបង្ហាញការរាក់ទាក់ចំពោះភ្ញៀវ។**

*ហាទីស ពូខរី ៦០១៨*

សាសនាអ៊ីស្លាម មានភាពស្រស់ស្អាត និងទូលំទូលាយក្រៃលែង ព្រោះសាសនាមួយនេះ បានផ្តល់នូវការណែនាំផ្សេងៗជាច្រើន សូម្បីតែនៅក្នុងទំនាក់ទំនងជាមួយអ្នកជិតខាង ក៏អ៊ីស្លាមបានយកចិត្តទុកដាក់ខ្ពស់ផងដែរ។ តែសព្វថ្ងៃនេះ មានមនុស្សជាច្រើន បានព្រងើយកន្តើយ និងបានបោះបង់ចោល ព្រោះផ្តល់សំខាន់តែលើខ្លួនឯង និងប្រើលេសថាមិនចង់លូកដៃចូលក្នុងរឿងអ្នកដទៃ។ ហើយមនុស្សភាគច្រើន ចូលចិត្តឈ្លោះប្រកែកជាមួយអ្នកជិតខាងរបស់គេ ហើយថែមទាំងធ្វើឱ្យអ្នកជិតខាងរបស់គេមានការឈឺចាប់ទៀតផង ដោយពួកគេមិនព្រមពិភាក្សាគ្នាអំពីបញ្ហាដែលពួកគេមាននោះឡើយ។

ព្យាការីលោកបានព្រមានថា៖

**មនុស្សដែលអល់ឡោះចាត់ទុកថាអាក្រក់បំផុត នៅថ្ងៃបរលោក គឺជាអ្នកដែលមនុស្សម្នានាំគ្នានៅឆ្ងាយពីគេ ព្រោះតែចង់គេចចេញពីអំពើអាក្រក់របស់ពួកគេ។**

*ហាទីស ពូខរី ៦០៣៣ និង មូស្លីម ២៥៩១*

រ៉ស៊ូលុលឡោះ ក៏បានបង្រៀនយើងឱ្យចេះរួសរាយរាក់ទាក់ចំពោះភ្ញៀវ គ្រួសារ និងមនុស្សគ្រប់រូប។ ថែមទាំងបង្រៀនយើងឱ្យចេះអាណិតអាសូរចំពោះសត្វផងដែរ។ នៅពេលដែលយើងចង់សម្លាប់សត្វ លោកក៏បានបង្រៀនយើងនូវរបៀបសំឡេះវាផងដែរ ដោយលោកមានប្រសាសន៍ថា៖

**ពិតប្រាកដណាស់ អល់ឡោះបានត្រាស់បង្គាប់នូវសេចក្ដីល្អចំពោះអ្វីៗទាំងអស់ ដូច្នេះ ពេលសម្លាប់ត្រូវសម្លាប់ដោយវិធីដែលល្អ ហើយពេលសំឡេះ ត្រូវសំឡេះដោយវិធីដែលល្អ។ ដូចនេះអ្នករាល់គ្នាត្រូវតែប្រើកាំបិតដែលមុត ដើម្បីសំឡេះ ហើយទុកឱ្យសត្វដែលត្រូវបានសំឡេះនោះស្លាប់តាមសម្រួល។**

*ហាទីស មូស្លីម ១៩៥៥*

លើសពីនេះ ព្យាការីក៏បានព្រមានយ៉ាងខ្លាំងផងដែរ ចំពោះអ្នកដែលបំពាន ឬកៀបសង្កត់លើអ្វីទាំងឡាយ(ម៉ាឃ្លូក) ដែលអល់ឡោះបានបង្កើត៖

**ស្ត្រីម្នាក់នឹងចូលក្នុងភ្លើងនរក ដោយសារតែសត្វឆ្មាមួយក្បាលដែលនាងចងទុកមិនឱ្យចំណីវា ហើយនាងក៏មិនបានដោះលែងវា ដើម្បីស្វែងរកចំណីហូតដល់ស្លាប់។**

*ហាទីស មូស្លីម ២៦១៩*

# បុគ្គលដែលគ្មាននរណា
# អាចប្រៀបផ្ទឹមបានឡើយ
# ក្នុងការអភ័យទោសដល់អ្នកដទៃ

រស៊ូលុលឡោះ ជាមនុស្សដែលមិនធ្លាប់ប្រកាន់ខឹងនឹងនរណាម្នាក់នោះឡើយ។ លោកត្រូវបានគេស្គាល់យ៉ាងច្បាស់ថា តែងតែអត់ទោសដល់អ្នកដទៃ។ សូម្បីតែអ្នកដែលប្រឆាំង ឬសត្រូវដែលធ្លាប់បានធ្វើបាបលោកយ៉ាងខ្លាំងក៏ដោយ។

នៅក្នុងហាទីសមួយដែលត្រូវបានរៀបរាប់ដោយលោកប៉ៃហាគីថា៖ នៅពេលដែលព្យាការី និងកងទ័ពអ៊ីស្លាមបានដណ្តើមយកទីក្រុងម៉ាក្កះវិញ បន្ទាប់ពីភាគីមូសរីគីនម៉ាក្កះបានរំលោភលើសន្ធិសញ្ញា ហូតៃពីយ៉ះ ក្នុងឆ្នាំ ទី៦ ហ៊ីជរ៉ោះ (ម.ស)។ ពេលនោះប្រជាជនម៉ាក្កះមានការភ័យខ្លាចយ៉ាងខ្លាំង ដោយសារតែពួកគេធ្លាប់បានធ្វើបាបលើព្យាការី និងសហាការីរបស់លោក។

អស់រយៈពេលប្រហែល១៣ឆ្នាំ នៅក្នុងទីក្រុងម៉ាក្កះ ដែលលោកបានដឹកនាំប្រជាជនមូស្លីម ធ្វើចំណាកស្រុកទៅ ហាប៉ាសះ(អេត្យូពី) ហើយក្រោយមកទៅក្រុងម៉ាទីណះ ដើម្បីស្វែងរកការការពារ។ ការធ្វើទុក្ខបុកម្នេញផ្សេងៗ នៃភាគីមូស្ហរីគីនមកលើប្រជាជនមូស្លីមទាំងផ្លូវកាយ និងផ្លូវចិត្ត ដូចជា ការសើចចំអក ការលួចទ្រព្យសម្បត្តិ និងការធ្វើទារុណកម្មផ្សេងៗ រហូតមានអ្នកដែលបានបាត់បង់ជីវិតដោយសារតែការធ្វើទារុណកម្ម និងការកៀបសង្កត់នៅពេលនោះ។ ទីបំផុតប្រជាជនមូស្លីមក៏បានបោះបង់ចោលផ្ទះសំបែង និងទ្រព្យសម្បត្តិរបស់ពួកគេ ហើយបានធ្វើចំណាកស្រុកដើម្បីរក្សាជីវិតរបស់ពួកគេ។ ដូច្នេះទ្រព្យសម្បត្តិ និងផ្ទះសំបែងរបស់ពួកគេត្រូវបានភាគីមូស្ហរីគីនកាន់កាប់ និងលក់ដូរតាមអំពើចិត្ត ហើយបានប្រយុទ្ធប្រឆាំងជាមួយព្យាការី និងប្រជាជនមូស្លីមអស់រយៈពេល ២០ ឆ្នាំ។ ប៉ុន្តែពេលនេះ ព្យាការី និងប្រជាជនមូស្លីមបានត្រលប់ចូលទីក្រុងម៉ាក្កះវិញដោយកម្លាំងរឹងមាំ។

ដូច្នេះ ពួកគេខ្លាចថាលោកនឹងសងសឹកពួកគេវិញ ចំពោះអំពើឃោរឃៅ និងការក្បត់ដែលពួកគេបានប្រព្រឹត្ត។ ប៉ុន្តែអ្វីដែលព្យាការីបានធ្វើនៅពេលដែលលោកបានឃើញការភ័យខ្លាច ដែលបង្ហាញនៅលើទឹកមុខរបស់អ្នកក្រុងម៉ាក្កះ? លោកបានមានប្រសាសន៍ថា៖

## ចូរទៅចុះ អ្នកទាំងអស់គ្នា មានសេរីភាពហើយ!

*ហាទីស ប៉ៃហាគី ១៨៣២៣*

នៅក្នុងសេចក្ដីរាយការណ៍មួយផ្សេងទៀត នៅពេលដែលក្រុមមូស្ហរីគីន បានប្រមូលផ្ដុំគ្នានៅជុំវិញកាក់ពះ កំពុងរង់ចាំការកាត់ទោស ឬការសម្រេចចិត្តពីព្យាការីនោះ លោកបានសួរទៅពួកគេថា៖ តើអ្នកគិតថាខ្ញុំនឹងធ្វើអ្វីដាក់អ្នកទៅ? ពួកគេឆ្លើយថា៖ ច្បាស់ជាធ្វើល្អ ព្រោះលោកគឺជាមនុស្សល្អ និងជាកូនចៅរបស់បុគ្គលដែលថ្លៃថ្នូរ។ បន្ទាប់មកលោកមានប្រសាសន៍ទៅកាន់ពួកគេថា៖

**ខ្ញុំមិនស្ដីបន្ទោសអ្នកទាំងអស់គ្នាទេថ្ងៃនេះ ចូរអ្នកទាំងអស់គ្នាទៅចុះ! ហើយសូមអល់ឡោះ ប្រទាននូវការអភ័យទោសដល់អ្នកទាំងអស់គ្នា។**

*ហាទីស ណាសាអុី ១១២៣៤*

អល់ឡោះ បានមានព្រះបន្ទូលថា៖

**ហើយប្រសិនបើពួកអ្នកដាក់ទណ្ឌកម្ម(លើសត្រូវរបស់ពួកអ្នក) ចូរពួកអ្នកដាក់ទណ្ឌកម្មដូចនឹងអ្វីដែលពួកគេបានដាក់ទណ្ឌកម្មមកលើពួកអ្នកចុះ។ តែប្រសិនបើពួកអ្នកស៊ូទ្រាំអត់ធ្មត់វិញនោះ វាពិតជាប្រសើរបំផុតសម្រាប់បណ្ដាអ្នកដែលអត់ធ្មត់។**

*គួរអាន អាល់ណាហាល ១៦ : ១២៦*

ព្យាការីផ្ទាល់ បានធានាសុវត្ថិភាពរបស់ អាពូសាហ្វយ៉ាន ដែលជាមេដឹកនាំនៃក្រុមម៉ាក្កះនៅពេលនោះ។ ពេលនោះគាត់គឺជាមនុស្សដែលមានឥទ្ធិពលបំផុតនៅក្នុងទីក្រុងម៉ាក្កះ ជាពិសេសបន្ទាប់ពីការស្លាប់នៃដៃគូដ៏ជិតស្និទ្ធបំផុតរបស់គេ គឺ អាពូចាហាល និង អុម៉ៃយ៉ះ ពិន ខឡាហ្វ នៅសមរភូមិ ប៉ាទើរ។ បន្ទាប់ពីការស្លាប់របស់

អាប់ទុលមូតឡិប ដែលជាជីតារបស់ព្យាការី ដែលគ្មាននរណាម្នាក់មានឥទ្ធិពលខ្លាំងដូចរូបលោកនោះទេ លើកលែងតែ អាពូសាហ្វយ៉ាន ប៉ុណ្ណោះ។ ជារឿយៗ អាពូសាហ្វយ៉ាន បានដឹកនាំកងទ័ពប្រឆាំងនឹងប្រជាជនមូស្លីម នៅក្នុងការប្រយុទ្ធជាបន្តបន្ទាប់។ ទោះបីជារឿងរ៉ាវកន្លងមកយ៉ាងណា នៅពេលដែលអ្នកមូស្លីមបានយកឈ្នះ ក្នុងការដណ្តើមយកទីក្រុងម៉ាក្កះមកវិញ ក៏ព្យាការីលោកនៅតែផ្តល់តម្លៃជូនដល់ អាពូសាហ្វយ៉ាន៖

**អ្នកណាហើយ ដែលចូលក្នុងផ្ទះរបស់ អាពូសាហ្វយ៉ាន អ្នកនោះនឹងបានសុខ!**

*ហាទីស មូស្លីម ១៧៨០*

នេះគឺព្រោះតែព្យាការី លោកឱ្យតម្លៃនូវតំណែងដែល អាពូសាហ្វយ៉ានធ្លាប់មានពីមុនមក។ ព្រោះលោកបានដឹងច្បាស់ថា ប្រសិនបើមេដឹកនាំមានការបន្ទន់ចិត្តនោះសាសនាអ៊ីស្លាម ដែលជាសាសនារបស់អល់ឡោះ នឹងត្រូវបានទទួលយកយ៉ាងងាយស្រួល និងមានអ្នកដើរតាមជាច្រើន។ ភាពសោកសៅ និងកំហឹងទាំងអស់ចំពោះ អាពូសាហ្វយ៉ាន និងគូរ៉ាយស៍ អស់រយៈពេលជិត២ទសវត្សរ៍មកនោះត្រូវបានរលត់ ក៏ព្រោះតែដើម្បីសាសនារបស់អល់ឡោះ។

មានហេតុការណ៍មួយ នៅពេលដែលព្យាការីបានចេញទៅទីក្រុងតអ៊ីហ្វ ដើម្បីណែនាំ និងបង្ហាញអំពីសាសនាអ៊ីស្លាមទៅកាន់ពួកគេ ក៏ប៉ុន្តែរូបលោកត្រូវបានពួកគេដេញចេញ ជេរស្តី និងគប់ដុំថ្មលើលោក រហូតដល់ឈាមហូរចុះដល់ជើងរបស់លោក ហើយស្បែកជើងរបស់លោកពោរពេញដោយឈាម។ ទីបំផុតលោកត្រូវបង្ខំចិត្តរត់ចេញពីទីនោះ។ ពេលកំពុងធ្វើដំណើរត្រលប់ទៅម៉ាក្កះវិញក្នុងចិត្តរបស់លោក ពោរពេញដោយទុក្ខព្រួយចំពោះការសាកល្បងដ៏ធ្ងន់ធ្ងរ ដែលលោកបានប្រឈមមុខនៅតអ៊ីហ្វនេះ។ ពេលនោះទេវតាជីបរេល បានចុះមកមើលលោក ដោយនាំទេវតាភ្នំមកជាមួយហើយបង្គាប់ទេវតានោះ ឱ្យគោរពតាមបង្គាប់

របស់ព្យាការី។ ហើយជីបរេលបានមានប្រសាសន៍ទៅកាន់លោកថា៖ ពិតប្រាកដណាស់ អល់ឡោះទ្រង់សណ្តាប់ឮនូវអ្វីដែលពួកគេបាននិយាយទៅកាន់អ្នក និងអ្វីដែលពួកគេបានធ្វើចំពោះអ្នក។ ហើយអល់ឡោះបានចាត់បញ្ជូនទេវតាភ្នំមកកាន់លោក ដើម្បីឱ្យលោកបញ្ជាគេឱ្យធ្វើអ្វីក៏បានតាមដែលលោកចង់ទៅលើពួកគេ។

បន្ទាប់មក ទេវតាភ្នំបានមានប្រសាសន៍ទៅកាន់លោកថា៖ ឱ មូហាំម៉ាត់! ប្រសិនបើលោកចង់ឱ្យខ្ញុំយកភ្នំទាំងពីរដែលទល់មុខគ្នានេះ ទម្លាក់សង្កត់កំទេចលើពួកគេ ខ្ញុំនឹងធ្វើភ្លាម!

តើព្យាការីបានប្រើឱកាសនោះដើម្បីសងសឹកដែរទេ? ប្រសិនបើជាយើងនៅក្នុងស្ថានភាព ឬកំពុងតែពាក់ស្បែកជើងដែលប្រលាក់ដោយឈាមរបស់លោកវិញនោះយើងនឹងឆ្លើយតបដោយគ្មានស្ទាក់ស្ទើរឡើយថា៖ បាទ បំផ្លាញពួកគេទៅសមមុខពួកគេហើយ ជាមិនខានឡើយ!

ផ្ទុយទៅវិញ ព្យាការីមិនធ្វើបែបនោះឡើយ តែលោកមានប្រសាសន៍ថា៖

**ខ្ញុំសង្ឃឹមថា អាចនឹងមានកូនចៅជំនាន់ក្រោយ នៃពូជពង្សរបស់ពួកគេ ដែលនឹងគោរពសក្ការៈទៅចំពោះអល់ឡោះតែមួយគត់ ហើយមិនធ្វើស្ទីរិកចំពោះទ្រង់នោះឡើយ នៅពេលខាងមុខណាមួយជាមិនខាន។**

*ពូខរី ១៦០០ និង មូស្លីម ១០៦២*

លើសពីនេះទៅទៀត នៅក្នុងពេលមួយ បន្ទាប់ពីសមរភូមិ ហូណៃនបានបញ្ចប់ អ៊ីបនូ ម៉ាសអូដ បានមករកព្យាការី ហើយបានប្រាប់លោកថា៖ មាននរណាម្នាក់ក្នុងចំណោមសហការីរបស់លោកបានត្អូញត្អែរថា៖ ព្យាការីគ្មានភាពយុត្តិធម៌ក្នុងការបែងចែករបស់ដែលទទួលបានពីសង្គ្រាមទេ។ ពាក្យទាំងនេះ វាគ្រប់គ្រាន់ក្នុងការទម្លុះបេះដូងរបស់លោក ដែលមិនធ្លាប់ប្រព្រឹត្តនូវទង្វើអយុត្តិធម៌ដាក់អ្នកណាម្នាក់ពីមុនមកសោះឡើយ។ បន្ទាប់មកព្យាការីក៏បានមានប្រសាសន៍ទៅកាន់ អ៊ីបនូ

ម៉ាសអ៊ូដថា៖ ព្យាការីមូសា(ម៉ូសេ)ត្រូវបានគេធ្វើបាបច្រើនជាងនេះ ប៉ុន្តែលោកបានជ្រើសយកការអត់ធ្មត់។

អល់ឡោះបានបើកសម្តែងដល់ព្យាការី នូវរឿងរ៉ាវរបស់ព្យាការីមុនៗមួយចំនួន ដើម្បីឱ្យលោកអាចរៀនសូត្រពីពួកគេបាន និងមានការអត់ធ្មត់ដូចពួកគេ។

អល់ឡោះមានបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

**ហើយជាការពិតណាស់ បណ្តាអ្នកនាំសារមុនៗ ក៏ត្រូវបានគេបដិសេធផងដែរ ប៉ុន្តែពួកគេបានអត់ធ្មត់ ចំពោះការបដិសេធ និងការធ្វើទុក្ខបុកម្នេញទាំងនោះ រហូតទាល់តែអល់ឡោះបានផ្តល់ជ័យជំនះដល់ពួកគេ ហើយគ្មាននរណាម្នាក់អាចកែប្រែព្រះបន្ទូលរបស់អល់ឡោះបានឡើយ។ ហើយដំណឹងអំពីអ្នកនាំសារមុនៗមួយចំនួន ពិតជាបានមកដល់អ្នក។**

*គួរអាន អាល់អាន់អាម ៦ : ៣៤*

ដូច្នេះហើយ ព្យាការីក៏បានព្យាយាមអត់ធ្មត់ ដូចជាអ្នកនាំសារមុនៗរបស់អល់ឡោះផងដែរ ក្នុងការអំពាវនាវទៅកាន់មនុស្សលោក នូវអ្វីដែលអល់ឡោះបានបង្គាប់ប្រើ។ ព្យាការីមូហាំម៉ាត់ដែលយើងដឹងគឺជាបុរសម្នាក់ ដែលពោរពេញដោយក្តីមេត្តានៅក្នុងការថ្លែងសារអ៊ីស្លាម។

អល់ឡោះក៏បានណែនាំលោកនៅក្នុងគម្ពីរគួរអានថា៖

**ដោយក្តីមេត្តាករុណានៃអល់ឡោះ អ្នក(មូហាំម៉ាត់)ត្រូវធ្វើទន់ភ្លន់ចំពោះពួកគេ តែបើអ្នកមានអាកប្បកិរិយាកោងកាច និងរឹងរូសវិញនោះ ពួកគេនឹងបាកបេញពីអ្នកជាមិនខាន។ ដូច្នេះចូរអ្នកអធ្យាស្រ័យដល់ពួកគេ និងសុំអភ័យទោសឱ្យពួកគេ ហើយចូរអ្នកពិភាក្សាជាមួយពួកគេគ្រប់កិច្ចការ។ នៅពេលដែលអ្នកបានសម្រេច**

**ចិត្តហើយនោះ ចូរអ្នកប្រគល់ការទុកចិត្តលើអល់ឡោះចុះ។ ពិតប្រាកដណាស់ អល់ឡោះស្រលាញ់បណ្តាអ្នកដែលប្រគល់ការទុកចិត្តលើទ្រង់។**

*គួរអាន អាលីអ៊ីមរ៉ន ៣ : ១៥៩*

មូហាំម៉ាត់ត្រូវបានគេស្គាល់ថាជាបុរសដែលមានសុជីវធម៌ និងសីលធម៌ល្អបំផុត។ តែប្រសិនបើយើងក្រឡេកមើលអាកប្បកិរិយា និងសីលធម៌របស់ប្រជាជនមូស្លីមភាគច្រើនបច្ចុប្បន្ននេះ វាទំនងជាយើងមិនអាចទទួលស្គាល់បុគ្គលិកលក្ខណៈរបស់ព្យាការីបាននោះទេ។ ដោយអាកប្បកិរិយា និងសីលធម៌ដ៏អាក្រក់របស់មនុស្សសព្វថ្ងៃនេះ បណ្តាលឱ្យមានការយល់ច្រឡំជាខ្លាំងអំពីសាសនាអ៊ីស្លាម ពីអ្នកមិនមែនជាមូស្លីម និងអ្នកមូស្លីមដូចគ្នា។

ព្យាការីលោកបានមានប្រសាសន៍ថា៖

**ពិតប្រាកដណាស់ ខ្ញុំត្រូវបានគេបញ្ជូនមកឱ្យមានអត្តចរិតល្អឥតខ្ចោះ។**

*ហាទីស អះម៉ាត់ ៨៩៥២*

ជាក់ស្តែង អ្នកណាហើយដែលបានឃើញព្យាការី ដូចជាសហការីរបស់លោក ឬអ្នកដែលបានធ្វើការសិក្សាស្រាវជ្រាវអំពីលោក ឬស្គាល់លោកច្បាស់ ប្រាកដជាគោរពស្រលាញ់ និងសរសើរលោកជាមិនខានឡើយ។ ជឿខ្ញុំចុះ!

# ការទទួលទានរបស់
# ព្យាការីមូហាំម៉ាត់

ប្រសិនបើយើងអាចត្រលប់ថយក្រោយវិញ ហើយបានទទួលទានអាហារជាមួយព្យាការី នោះយើងនឹងឃើញថា តើលោកពិតជាបានផ្តល់តម្លៃចំពោះអាហារកម្រិតណា? ប្រសិនបើលោកអាចពិសាអាហារនោះបាន លោកនឹងពិសា ប៉ុន្តែបើលោកមិនអាចពិសាបាន លោកក៏មិនប្រមាថអាហារនោះដែរ។ លោកមិនត្រូវបានគេរកឃើញថា ធ្លាប់ត្អូញត្អែរ ឬប្រមាថចំពោះអាហារណាមួយ ដែលគេបានរៀបចំជូនដល់លោកឡើយ សូម្បីពាក្យថា៖ ក្តៅ ប្រៃ ឬសាប ក៏លោកមិនដែលហាមាត់និយាយសោះឡើយ។ អាពូហ៊ូរ៉យរ៉ោះ បាននិយាយថា៖

**ព្យាការីមិនដែលរិះគន់អាហារណាមួយ ដែលគេរៀបចំជូនដល់លោកនោះឡើយ លោកនឹងពិសាវា ប្រសិនបើលោកអាចពិសាបាន តែបើលោកមិនអាចពិសាបាន នោះលោកនឹងទុកវាចោល ដោយមិននិយាយ ឬបង្ហាញពីការមិនចូលចិត្តនោះឡើយ។**

*ហាទីស ពូខរី ៣៥៦៣ និង មូស្លីម ២០៦៤*

មានពេលមួយលោកត្រូវបានគេរៀបចំជូននូវម្ហូបអាហារបង្គុយវាលខ្សាច់ (ទុប)ជូនលោក។ ពេលនោះទោះបីជាលោកមិនបានពិសាក៏ដោយ តែលោកមិនបានបង្ហាញប្រតិកម្មអវិជ្ជមានចំពោះម្ហូបនោះទេ។ ហើយនៅពេលគេសួរលោកអំពីមូលហេតុដែលលោកមិនបានពិសាវានោះ លោកក៏បានឆ្លើយថា៖

**មិនមែនគេហាមមិនឱ្យបរិភោគនោះទេ គ្រាន់តែវាមិនធ្លាប់មាននៅក្នុងទឹកដីដែលខ្ញុំរស់នៅតែប៉ុណ្ណោះ ខ្ញុំមានអារម្មណ៍ថាដូចជាមិនសូវស្និទ្ធនឹងវាទេ។**

*ហាទីស មូស្លីម ១៩៤៦*

ព្យាការីក៏មិនមែនជាអ្នកដែលពិសាច្រើននោះដែរ។ លោកមិនដែលបានពិសារហូតដល់មានអារម្មណ៍ថាឆ្អែតឡើយ។ បើលោកមានអាហារដើម្បីពិសា

លោកក៏ពិសាល្មមឱ្យលោកមានកម្លាំង ដើម្បីអាចអនុវត្តសកម្មភាពប្រចាំថ្ងៃរបស់លោក។ ហើយលោកក៏បានផ្តល់ដំបូន្មានដល់ប្រជាជាតិរបស់លោកថា៖

**មនុស្សយើងមិនបានបំពេញចំណុះណាដែលអាក្រក់ជាងបំពេញក្រពះនោះទេ គ្រប់គ្រាន់ហើយសម្រាប់មនុស្សលោកធ្វើការបរិភោគ ដើម្បីរក្សាឆ្អឹងខ្នងឱ្យត្រង់ (មានកម្លាំងគ្រប់គ្រាន់ដើម្បីអនុវត្តសកម្មភាពប្រចាំថ្ងៃ)។ ប៉ុន្តែប្រសិនបើនូវតែត្រូវការបំពេញវានោះ គឺត្រូវតែមួយភាគបីសម្រាប់អាហារ មួយភាគបីសម្រាប់ទឹក និងមួយភាគបីសម្រាប់ខ្យល់ដកដង្ហើម។**

*ហាទីស តៀរមីហ្ស៊ី ២៣៨០ និង អ៊ីបនូ ម៉ាចាស់ ៣៣៤៩*

លោកបានបង្រៀនប្រជាជាតិរបស់លោក ឱ្យថ្លែងអំណរព្រះគុណដល់ព្រះជាម្ចាស់ សម្រាប់ពរជ័យ និងលាភសក្ការៈទាំងអស់ដែលទ្រង់បានប្រទាន។ នៅក្នុងហាទីសមួយ លោកបានសូត្រទូអាបួងសួងមួយនេះ បន្ទាប់ពីពិសាអាហាររួច៖

**រាល់ការសរសើរតម្កើង គឺសម្រាប់អល់ឡោះតែមួយគត់ ដែលបានប្រទាននូវអាហារ និងការទ្រទ្រង់ដល់រូបខ្ញុំ ដោយគ្មានសមត្ថភាព ឬអំណាចណាមួយដែលរូបខ្ញុំអាចទទួលបាននោះឡើយ ប្រសិនបើគ្មានជំនួយពីទ្រង់នោះ។**

*ហាទីស តៀរមីហ្ស៊ី ៣៤៥៨*

ហើយអ្នកណាហើយដែលសូត្រនូវទូអាបួងសួងមួយនេះ នោះអំពើបាបកន្លងមករបស់គេនឹងត្រូវបានលើកលែងទោស។

នោះហើយជាអ្វីដែលព្យាការីបានបង្រៀនប្រជាជាតិរបស់លោក។ លោកជាគំរូដែលគួរតែយកតម្រាប់តាម ដើម្បីទទួលបាននូវសេចក្តីមេត្តាករុណា និងការអភ័យទោសពីព្រះជាម្ចាស់។ ព្យាការីបានមានប្រសាសន៍ថា៖

**អល់ឡោះពិតជាពេញចិត្តនឹងខ្ញុំបម្រើរបស់ទ្រង់ ដែលកោតសរសើរ ទៅចំពោះទ្រង់ នៅពេលដែលគេបរិភោគអាហារ ឬពិសាភេសជ្ជៈរួច។**

*ហាទីស មូស្លីម ២៧៣៤*

លោកមិនមែនជាមនុស្សដែលរើសអាហារនោះទេ។ អ្វីក៏ដោយដែលមាន លោកនឹងពិសាវាក្នុងកម្រិតមធ្យម។ បងជីដូនមួយរបស់លោកអ្នកស្រី អ៊ុំមូ ហានៀក ធ្លាប់បានប្រាប់រឿងមួយអំពីលោក នៅពេលលោកបានទៅផ្ទះអ្នកស្រី ហើយសួរអ្នកស្រីថា៖ តើមានម្ហូបអ្វីពិសាដែរទេ? អ្នកស្រីក៏ឆ្លើយថា៖ មានតែនំប៉័ងដែលរឹង និងទឹកខ្មេះប៉ុណ្ណោះ។ បន្ទាប់មក លោកក៏ពិសាវា ហើយថែមទាំងសរសើរតម្កើងដល់ព្រះជាម្ចាស់ និងបានឱ្យតម្លៃដល់អាហារនោះ ដោយលោកបានមានប្រសាសន៍ថា៖

**ផ្ទះដែលមានទឹកខ្មេះ គឺមិនបាត់ទុកថាក្រីក្រនោះទេ។**

*ហាទីស តៀរម៉ីហ្ស៊ី ១៨៤២*

នេះហើយគឺជាការដឹងគុណរបស់បុគ្គលម្នាក់ ដែលដួងចិត្តរបស់លោកពោរពេញទៅដោយភាពស្កប់ស្កល់ និងសាមញ្ញបំផុត។ ជាមេដឹកនាំដែលជីវិតរបស់លោកសាមញ្ញជាងអ្នកដែលលោកបានដឹកនាំទៅទៀត។ ពេលមួយមានសហការីម្នាក់ឈ្មោះ អាល់នួកម៉ាន ពិន ប៉ាសៀរ ធ្លាប់បានរិះគន់ទៅកាន់បុគ្គលខ្លះ ដែលគាត់បានឃើញថា កំពុងហូបយ៉ាងខ្ជះខ្ជាយ ដោយគាត់បានប្រាប់ពួកគេថា៖

**ខ្ញុំបានឃើញព្យាការីរបស់អ្នក ពិសាល្មើដែលមានគុណភាពអន់តែប៉ុណ្ណោះ ដើម្បីបំពេញក្រពះរបស់លោក។ មានច្រើនដងណាស់ ដែលព្យាការី និងក្រុមគ្រួសាររបស់**

**លោកពុំមានអ្វីសម្រាប់បរិភោគទាល់តែសោះ។ លោកបានចងពោះរបស់លោក ជាមួយនឹងដុំថ្ម ដើម្បីទប់នឹងការស្រេកឃ្លាន។**

*ហាទីស ពូខរី ៤១០១*

ប្រសិនបើមាននរណាម្នាក់ឱ្យផ្លែល្មើដល់លោក នោះលោកនឹងមិនពិសាទាំងអស់តាមការឃ្លាននោះឡើយ។ លោកនឹងបែងចែកវា ហើយពិសាតែមួយចំណែកតូច ដើម្បីបំពេញក្រពះរបស់លោកតែប៉ុណ្ណោះ។

នេះហើយគឺជាភាពសាមញ្ញនៃរបបអាហាររបស់បុគ្គល ដែលជាអ្នកដឹកនាំដ៏អស្ចារ្យម្នាក់នេះ ប្រសិនបើលោកចង់ឱ្យផ្ទះរបស់លោក ពោរពេញទៅដោយអាហារប្រណិតគ្រប់ប្រភេទវិញនោះ លោកប្រាកដជាអាចធ្វើបានច្បាស់ណាស់។ តែទោះជាយ៉ាងណាក៏ដោយ លោកចង់ឱ្យជីវិតរបស់លោកមានការស្កប់ស្កល់នឹងអាហារអ្វីក៏ដោយ ដែលព្រះជាម្ចាស់ទ្រង់បានប្រទាន។

# ការស្មេ្បៀកពាក់របស់
# ព្យាការីមូហាំម៉ាត់

ព្យាការីមូហាំម៉ាត់ បាននាំមកជាមួយលោកនូវច្បាប់មួយ ដែលពោរពេញទៅដោយសោភ័ណភាព និងផ្អែកលើគោលការណ៍៖

**អល់ឡោះស្អាតបំផុត ហើយទ្រង់ស្រលាញ់ភាពស្អាត។**

*ហាទីស មូស្លីម ៩១*

មានឱកាសមួយលោកបានទូន្មានដល់សហការីរបស់លោកពីរនាក់ ដែលមិនបានថែរក្សា និងអនាម័យបំពោះសក់ និងសម្លៀកបំពាក់របស់ពួកគេ ដោយលោកបានមានប្រសាសន៍ថា៖

**ហេតុអ្វីបានជាពួកគេមិនរកអ្វីមួយមកប្រើ ដើម្បីសម្អាតសក់របស់ពួកគេ? ហេតុអ្វីពួកគេមិនរកទឹកមកប្រើ ដើម្បីសម្អាតសម្លៀកបំពាក់របស់ពួកគេ?**

*ហាទីស អះម៉ាត់ ១៤៨៥០*

ទោះបីជាភាពស្រស់ស្អាត ត្រូវបានជំរុញ និងគាំទ្រដោយសាសនាអ៊ីស្លាមក៏ដោយ តែព្យាការីក៏បានហាមឃាត់ប្រជាជាតិរបស់លោក ពីការស្លៀកពាក់នូវសំលៀកបំពាក់ណា ដែលអាចធ្វើឱ្យជះឥទ្ធិពលមិនល្អដល់ដួងចិត្តរបស់ពួកគេ និងបំផ្លាញសីលធម៌ក្នុងសង្គម ដោយការបណ្តោយទៅតាមចំណង់តណ្ហារបស់ពួកគេ ដូចជា ការប្រើប្រាស់សម្លៀកបំពាក់ភេទផ្ទុយគ្នា សម្លៀកបំពាក់លាតត្រដាងអាវ៉ាត់(កន្លែងដែលត្រូវបិទបាំងនៅលើរាងកាយ) ឬជានិមិត្តរូបនៃសាសនាដទៃ ឬសម្លៀកបំពាក់ដែលចម្លែកខុសគេ ដែលទាក់ទាញចំណាប់អារម្មណ៍ពីអ្នកដទៃ។

ព្យាការីមិនបានកំណត់ប្រភេទសម្លៀកបំពាក់ជាក់លាក់ណាមួយឡើយ ប៉ុន្តែលោកបានដាក់នូវគោលការណ៍ និងសេចក្តីណែនាំដែលអាចប្រើប្រាស់បានគ្រប់ពេលវេលា និងអាចបត់បែនបានសម្រាប់គ្រប់សង្គមជាតិទាំងអស់ ចំពោះការ

ស្លៀកពាក់សម្រាប់បុរស និងស្ត្រី។ សម្លៀកបំពាក់ដែលព្យាការីប្រើប្រាស់បាន បង្ហាញយ៉ាងច្បាស់ថា សាសនាអ៊ីស្លាមមិនបានប្រើឱ្យប្រជាជាតិរបស់លោកពាក់នូវសម្លៀកបំពាក់ឱ្យដូចនឹងជនជាតិអារ៉ាប់នោះឡើយ ដែលជាធម្មតាពួកគេពាក់អាវវែង( ជូប៉ាស ) និងក្រម៉ារុំក្បាល( សាល់ )។ ផ្ទុយទៅវិញ អ៊ីស្លាមបានអនុញ្ញាតិឱ្យស្លៀកសំលៀកបំពាក់គ្រប់ប្រភេទដែលយើងមាន ឬអាចរកបានយ៉ាងងាយស្រួល និងមិនត្រូវបានចាត់ទុកថាចម្លែកដោយសហគមន៍ជុំវិញនោះទេ។ ព្យាការីធ្លាប់បានស្លៀកសម្លៀកបំពាក់ច្រើនប្រភេទ និងម៉ូតផ្សេងៗគ្នា។ ជាឧទាហរណ៍ លោកធ្លាប់ពាក់អាវរ៉ូម៉ាំងដែលមានដៃអាវរឹប។ ហើយក្នុងឱកាសផ្សេងទៀត លោកបានពាក់អាវក្រណាត់ និងអាវជូប៉ាស ដែលជាប្រភេទសំលៀកបំពាក់ដែលលោកចូលចិត្ត។

នៅក្នុងសេចក្តីរាយការណ៍ផ្សេងទៀត ព្យាការីបានហាមឃាត់ការស្លៀកពាក់មួយចំនួន ដូចជា ហាមបុរសមិនឱ្យស្លៀកសម្លៀកបំពាក់ដែលធ្វើពីសូត្រ ព្រោះសូត្រត្រូវបានចាត់ទុកថាជាសម្លៀកបំពាក់សម្រាប់តែស្ត្រី ព្រោះតែភាពភ្លឺរលោង និងប្រណិតរបស់វា ដែលអាចបណ្តាលឱ្យអ្នកពាក់មានចិត្តអំណួត ហើយម្យ៉ាងទៀតវាក៏ជាប្រភេទនៃសម្លៀកបំពាក់ដែលមានតម្លៃថ្លៃផងដែរ។ ព្យាការីក៏ធ្លាប់ត្រូវបានទទួលសូត្រមួយចំនួនផងដែរ ប៉ុន្តែលោកបានប្រគល់វាទៅឱ្យ អាលី ពិន អាពីតឡិប ដើម្បីឱ្យគាត់យកវាទៅចែកចាយដល់សាច់ញាតិរបស់គាត់ ហើយពួកគេបានប្រើប្រាស់សូត្រដើម្បីធ្វើជាស្បៃជាដើម។

ជាទូទៅ មនុស្សភាគច្រើន មានទំនោរលើពណ៌ដែលខ្លួនចូលចិត្តរៀងៗខ្លួនដូចគ្នាដែរ ព្យាការីលោកចូលចិត្តពណ៌ស។ លោកបានមានប្រសាសន៍ថា៖

**ចូរស្លៀកសម្លៀកបំពាក់ពណ៌ស ដ្បិតវាជាសម្លៀកបំពាក់ដ៏ល្អបំផុតរបស់អ្នក។**

*ហាទីស អាពូដាវូឌ ៣៨៧៨*

ទោះជាបែបនេះក៏ដោយ ក៏មិនមែនមានន័យថា មិនត្រូវបានអនុញ្ញាតឱ្យយើងស្លៀកពាក់ពណ៌ផ្សេងទៀតក្រៅពីពណ៌សនោះទេ។ តាមពិត ព្យាការីត្រូវបាន

គេប្រទះឃើញលោកស្លៀកសម្លៀកបំពាក់ពណ៌ក្រហម ដែលមានភាពស្រស់ស្អាត និងត្រូវបានសរសើរយ៉ាងខ្លាំងដោយសហការីរបស់លោក ដែលមានឈ្មោះថា អាល់ប៉ារ៉ក ពិន អាស៊ីប ថា៖

**ព្យាការីមានកម្ពស់មធ្យម(មិនខ្ពស់ពេក ឬទាបពេក) ខ្ញុំបានឃើញលោកពាក់អាវពណ៌ក្រហម ដោយខ្ញុំមិនដែលឃើញនរណាល្អស្អាតដូចលោកនោះទេ។**

*ហាទីស ពូខរី ៥៨៤៨*

ព្យាការីលោកក៏មានរៀបចំសំលៀកបំពាក់ពិសេសផង សម្រាប់ស្លៀកពាក់ក្នុងឱកាសសំខាន់ៗផងដែរ ដូចជា ពិធីបុណ្យអ៊ីឌទាំងពីរ (អ៊ីឌុលហ្វិតរី និង អ៊ីឌុលអុដហា) ថ្ងៃសុក្រ ឬពេលទទួលគណៈប្រតិភូ និងភ្ញៀវជាដើម។ លោកក៏បានជំរុញលើកទឹកចិត្តដល់សហការីរបស់លោកឱ្យធ្វើដូចគ្នាដែរ។ ព្យាការីធ្លាប់បានមានប្រសាសន៍ថា៖

**មិនមានអ្វីខុសនោះទេ សម្រាប់អ្នកណាដែលគេមានលទ្ធភាព ទិញសម្លៀកបំពាក់ពីរឈុតសម្រាប់ប្រើប្រាស់នៅថ្ងៃសុក្រ ដែលមិនមែនជាសំលៀកបំពាក់សម្រាប់ពាក់ប្រចាំថ្ងៃរបស់គេ។**

*ហាទីស អ៊ីបនូម៉ាជះ ១០៩៦*

តាមរយៈបញ្ហានៃការស្លៀកពាក់នេះ ព្យាការីបានបង្រៀនប្រជាជាតិរបស់លោកអំពីអត្ថន័យនៃការគោរពសក្ការៈ ដែលត្រូវបានហ៊ុំព័ទ្ធដោយសុជីវធម៌ និងការដឹងគុណ។ ដោយនៅពេលណាព្យាការី លោកចង់ស្លៀកសម្លៀកបំពាក់ថ្មី លោកនឹងធ្វើការសូត្រទូអាបួងសួងថា៖

**រាល់ការសរសើរតម្កើងសម្រាប់អល់ឡោះតែម្នាក់គត់ ដែលបានប្រទានសម្លៀកបំពាក់ និងបានប្រទាននូវការទ្រទ្រង់ដល់ខ្ញុំ ដោយគ្មានការប្រឹងប្រែង ឬអំណាចណាមួយពីខ្ញុំនោះឡើយ។**

*ហាទីស អាពូដាវូឌ ៤០២៣*

បន្ទាប់មក លោកក៏បានទូអាបួងសួងដល់អល់ឡោះ សូមឱ្យទ្រង់ប្រទាននូវសម្លៀកបំពាក់ថ្មីនោះ ជាសម្លៀកបំពាក់ដែលអាចជួយឱ្យលោកបានខិតជិតប្រការល្អ ហើយជៀសឆ្ងាយអំពីប្រការអាក្រក់ទាំងឡាយផងដែរ។

**បពិត្រអល់ឡោះជាម្ចាស់! ខ្ញុំសូមសរសើរតម្កើងទ្រង់ ដែលបានប្រទានសម្លៀកបំពាក់ដល់រូបខ្ញុំ សូមទ្រង់ប្រទាននូវសេចក្តីល្អ និងសេចក្តីល្អនៃអ្វីដែលវាត្រូវបានបង្កើតឡើង ហើយសូមទ្រង់ការពាររូបខ្ញុំអំពីប្រការអាក្រក់ និងអំពើអាក្រក់នៃអ្វីដែលវាត្រូវបានបង្កើតឡើងផង។**

*ហាទីស តៀរមីហ្ស៊ី ១៧៦៧*

នេះហើយគឺជាសុជីវធម៌របស់ព្យាការីមូហាំម៉ាត់ នៅក្នុងការស្លៀកពាក់ដែលបានបង្ហាញពីភាពរាបសា ហើយនិងការយកចិត្តទុកដាក់ទៅចំពោះអ្នកដទៃប្រកបដោយភាពស្រស់ស្អាត ការដឹងគុណ និងភាពអៀនខ្មាស។

# ទម្លាប់
# នៃការសម្រាន្តរបស់
# ព្យាការីមូហាំម៉ាត់

ទង្វើដែលព្យាការីមូហាំម៉ាត់បានធ្វើ មិនថាជាការបរិភោគ ស្លៀកពាក់ ឬការសម្រាន្តនោះទេ ជាទូទៅសកម្មភាពទាំងអស់របស់លោក គឺជាការគោរពសក្ការៈ។ ប៉ុន្តែការសម្រាន្តរបស់លោកមិនដូចជាការសម្រាន្តនៃមនុស្សទូទៅភាគច្រើននោះឡើយ ដែលសម្រាន្តដើម្បីគេចវេសពីបញ្ហាជីវិត ឬដើម្បីផ្តាច់ទំនាក់ទំនងពីអ្នកដទៃ។ ផ្ទុយទៅវិញលោកបានប្រើការសម្រាន្តរបស់លោក គឺជាការវិភាគដើម្បីបានខិតជិតព្រះជាម្ចាស់តែប៉ុណ្ណោះ។

នៅពេលណាដែលព្យាការីរៀបចូលសម្រាន្ត នោះលោកនឹងចំណាយពេលខ្លះនៅក្នុងការរំលឹកដល់ព្រះជាម្ចាស់ និងនឹកគិតដល់ថ្ងៃជំនុំជម្រះ ដែលគួរឱ្យភ័យខ្លាចបំផុត ហើយលោកបានសូត្រទូអាបួងសួងថា៖

**បពិត្រព្រះជាម្ចាស់នៃទូលបង្គំអើយ សូមការពារទូលបង្គំឱ្យរួចពីទណ្ឌកម្មរបស់ព្រះអង្គ នៅថ្ងៃដែលព្រះអង្គពង្រស់ខ្ញុំបម្រើរបស់ទ្រង់ឱ្យរស់ឡើងវិញផង។**

*ហាទីស តៀរម៉ីស៊ី ៣៣៩៩*

ហើយពេលខ្លះលោកក៏សូត្រទូអាបួងសួងនេះជំនួសវិញ៖

**បពិត្រព្រះជាម្ចាស់នៃទូលបង្គំអើយ! ដោយព្រះនាមនៃទ្រង់តែមួយគត់ ខ្ញុំស្លាប់(សម្រាន្ត) ហើយរស់(ភ្ញាក់ពីសម្រាន្ត)។**

ហើយនៅពេលភ្ញាក់ពីដំណេក លោកសូត្រថា៖

**រាល់ការសរសើរតម្កើងគឺសម្រាប់អល់ឡោះតែមួយគត់ ជាអ្នកដែលបានប្រទានជីវិតដល់យើង(ដាស់យើងឱ្យភ្ញាក់ឡើង) បន្ទាប់ពីបានយកជីវិតយើង(ធ្វើឱ្យយើងគេងលក់) ហើយយើងនឹងវិលត្រឡប់ទៅកាន់ទ្រង់វិញជាមិនខាន។**

*ហាទីស ពូខរី ៦៣១៤*

នេះហើយជាអ្វីដែលព្យាការីនឹកគិតដល់ គឺអំពីសេចក្តីស្លាប់នៅពេលដែលលោកសម្រាន្ត និងការដឹងគុណទៅចំពោះទ្រង់ ដែលបានប្រទានជីវិតបន្តទៅមុខទៀត បន្ទាប់ពីការស្លាប់(ការសម្រាន្ត)នៅពេលយប់។

រ៉ស៊ូលុលឡោះមិនមែនជាអ្នកដែលសម្រាន្តច្រើននោះទេ ហើយការសម្រាន្តរបស់លោក ក៏មិនធ្លាប់រំខាន ឬធ្វើឱ្យប៉ះពាល់ដល់ការគោរពសក្ការៈរបស់លោកដែរ។ តាមពិតទៅលោកសម្រាន្តបានតែពាក់កណ្តាលយប់ ឬតិចជាងនេះទៅទៀត។ បន្ទាប់មកលោកនឹងក្រោកឡើង ដើម្បីធ្វើការថ្វាយបង្គំ ឬសូត្រគម្ពីរគួរអាន និងរំលឹកដល់អល់ឡោះជាម្ចាស់។

អល់ឡោះបានមានបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

**ឱ អ្នកដែលដណ្តប់ភួយ(មូហាំម៉ាត់)! ចូរអ្នកក្រោកនៅពេលយប់(ដើម្បីសឡាត) លើកលែងតែ បន្តិចបន្តួចប៉ុណ្ណោះ(ដើម្បីសម្រាក)។ ពាក់កណ្តាលយប់ ឬមុនជាងនេះបន្តិច។ ឬច្រើនជាងពាក់កណ្តាលយប់បន្តិច។ ហើយចូរអ្នកសូត្រគម្ពីរគួរអានតាមបែបបទយឺតៗ និងឱ្យច្បាស់លាស់។ ពិតប្រាកដណាស់ យើងនឹងបញ្ចុះទៅឱ្យអ្នកនូវគម្ពីរគួរអានដ៏ឧត្តុង្គឧត្តម(ដែលមានច្បាប់គ្រប់បែបយ៉ាង)។ ពិតប្រាកដណាស់ ការក្រោកនៅពេលយប់(ដើម្បីថ្វាយបង្គំ) គឺវាធ្វើឱ្យចិត្តមានភាពនឹងនរ និងធ្វើឱ្យការសូត្រគម្ពីរគួរអាន មានភាពត្រឹមត្រូវជាងពេលថ្ងៃ។ ពិតប្រាកដណាស់ សម្រាប់អ្នក(មូហាំម៉ាត់)នៅពេលថ្ងៃ គឺមានការងារជាច្រើន។ ហើយចូរអ្នករំលឹកនាមនៃម្ចាស់របស់អ្នក និងត្រូវគោរពសក្ការៈចំពោះទ្រង់ដោយចិត្តស្មោះស។**

*គួរអាន អាល់មូសាំមីល ៧៣ : ១-៨*

ព្យាការីមិនដែលគិតចង់បានកន្លែងសម្រាន្តរបស់លោក ឱ្យល្អប្រណិត ឬគេងស្រួល តាមដែលអាចធ្វើទៅបានដូចពួកយើងភាគច្រើននោះទេ ផ្ទុយទៅវិញ

ពូករបស់លោកគឺសាមញ្ញបំផុត ដូចដែលភរិយារបស់លោកអ្នកស្រីអាអ៊ីស្ហះបានប្រាប់ថា៖

**ពូកដែលព្យាការីលោកគេងនោះគឺធ្វើពីស្បែកសត្វ ដែលប្រកទ្រាប់ដោយជាងល្មើ។**
*ហាទីស ពូខរី ៦៤៥៦ និង មូស្លីម ២០៨២*

អូមើរ ពិន ខុត្តប ធ្លាប់បានឃើញស្លាកស្នាមនៅលើខ្នងរបស់ព្យាការី ដែលជាលទ្ធផលនៃការគេងលើពូកដែលរឹង និងមិនស្មើ នៃគ្រែរបស់ព្យាការី ដែលធ្វើឱ្យអូមើរយំយ៉ាងខ្លាំង ដោយនឹកគិតដល់អ្នកគ្រប់គ្រង ឬអ្នកដឹកនាំផ្សេងទៀតនៅសម័យនោះ ដែលពួកគេគេងលក់យ៉ាងស្កប់ស្កល់។ ខណៈពេលដែលអ្នកជាទីស្រលាញ់របស់អល់ឡោះ លោកគេងនៅក្នុងស្ថានភាពលំបាកបែបនេះ។

# គ្រាដ៏រីករាយ និងសោកសៅ
# របស់បុគ្គលជាទីស្រលាញ់នៃយើង

វ៉ស៊ុលុលឡោះ រស់នៅមានជីវិតជាមនុស្សធម្មតា ដែលមានអារម្មណ៍ និងមនោសញ្ចេតនា មិនខុសពីយើងនោះទេ។ តែអ្វីដែលជាទម្លាប់របស់លោក គឺលោកតែងតែខ្ទាប់ខ្លួនចំពោះអល់ឡោះ ដោយបង្ហាញនូវការដឹងគុណចំពោះទ្រង់ រាល់ពេលដែលលោកទទួលបានការពេញចិត្ត ឬទទួលបានដំណឹងដែលធ្វើឱ្យលោកសប្បាយចិត្ត។ អាពូប៉ាកើរ បាននិយាយថា៖

**នៅពេលដែលព្យាការីបានឮដំណឹងដែលធ្វើឱ្យលោករីករាយ ឬនៅពេលដែលនរណាម្នាក់នាំដំណឹងល្អមកប្រាប់ នោះលោកនឹងក្រាបចុះ ហើយថ្វាយបង្គំចំពោះព្រះជាម្ចាស់ដ៏ជាទីគោរពសក្ការៈជាមិនខាន។**

*ហាទីស អ៊ីបនូម៉ាជះ ១៣៩៤*

ពេលខ្លះលោកសប្បាយចិត្តជាខ្លាំង រហូតដល់លោកញញឹម ដោយសារតែបានដឹងអំពីសេចក្តីមេត្តាករុណាគ្រប់បែបយ៉ាងរបស់អល់ឡោះ។ មានពេលមួយនោះព្យាការី មានប្រសាសន៍ទាក់ទងនឹងរឿងរបស់ខ្ញុំបម្រើម្នាក់របស់ អល់ឡោះនៅថ្ងៃបរលោក ដែលត្រូវបានផ្តន្ទាទោសនៅក្នុងនរក ដោយគេប្រាថ្នាចង់ស្លាប់(ដោយការឈឺចាប់) លែងចង់នៅត្រង់ចំណុចនោះទៀត។ បន្ទាប់មក អល់ឡោះបានយកគេចេញពីនរក ហើយបានបង្ហាញអំពើបាបតូចៗរបស់គេនៅចំពោះមុខគេ ហើយទ្រង់ក៏មានបន្ទូលថា៖ ឯងត្រូវបានអត់ទោសឱ្យទាំងអស់ហើយ ដោយអំពើបាបទាំងនោះ ត្រូវបានបំប្លែងទៅជាផលបុណ្យវិញ។ បន្ទាប់មកខ្ញុំបម្រើរបស់អល់ឡោះបានសួរអំពីអំពើបាបធំរបស់គេ ដោយសង្ឃឹមចង់ឱ្យទ្រង់អត់ទោសឱ្យគេ រួចបំប្លែងទៅជាផលបុណ្យវិញទៀត។ បន្ទាប់ពីមានប្រសាសន៍រឿងនេះចប់ ព្យាការីបានអស់សំណើច ដោយនឹកឃើញអំពីភាពលោភលន់នៃខ្ញុំបម្រើរបស់អល់ឡោះ ចំពោះសេចក្តីមេត្តាករុណានៃទ្រង់។

ជួនកាលព្យាការីញញឹមដោយក្ដីរីករាយ ពេលលោកបានទទួលដំណឹងល្អអំពីសហការីរបស់លោក។ ជាឧទាហរណ៍ មានហេតុការមួយ នៅពេលដែលអូសាម៉ាស់ ពិន សៃទ ត្រូវបានគេជេរប្រមាថ និងធ្វើឱ្យពូជពង្សរបស់គាត់កើតមានជម្លោះ ដោយសារតែមានមនុស្សលាក់ពុត(មូណាហ្វិច) ព្រោះតែគាត់មានស្បែកខ្មៅ ខណៈពេលដែលឪពុករបស់គាត់(សៃទ)មានស្បែកស។ ដោយបន្ទាប់ពីត្រូវបានបញ្ជាក់ដោយអ្នកជំនាញខាងពង្សាវតារថា អូសាម៉ាស់ ពិតជាកូនប្រុសបង្កើតរបស់សៃទនោះ។ រ៉ស៊ូលុលឡោះក៏បានចូលទៅក្នុងផ្ទះរបស់លោក ហើយបានជួបអ្នកស្រីអាអ៊ីស្ហះភរិយារបស់លោក ជាមួយនឹងទឹកមុខ ដែលពោរពេញដោយសុភមង្គលក្រៃលែង។

មានពេលមួយ អាណាស ពិន ម៉ាលីគ បានរៀបរាប់ថា៖ រ៉ស៊ូលុលឡោះបានភ្ញាក់ពីដំណេករបស់លោកហើយញញឹមយ៉ាងរីករាយ។ ពេលនោះអាណាសបានសួរព្យាការីអំពីមូលហេតុដែលលោកញញឹម ហើយលោកក៏បានមានប្រសាសន៍ថា៖ លោកបានឃើញដំណឹងល្អខ្លះអំពីអនាគតនៃប្រជាជាតិរបស់លោកនៅក្នុងសុបិនរបស់លោក។

ព្យាការីញញឹមហើយញញឹមទៀត ក្នុងឱកាសនេះ ដើម្បីចែករំលែកនូវសេចក្ដីសុខដល់សហការីរបស់លោក។ ហើយលោកនឹងញញឹមដើម្បីជួយសម្រាលអារម្មណ៍សហការីរបស់លោក នៅពេលដែលពួកគេមានអារម្មណ៍ព្រួយបារម្ភ ឬអស់កម្លាំង។ លោកថែមទាំងញញឹមជាការឆ្លើយតបទៅនឹងអ្នកដែលធ្វើបាបលោកយ៉ាងធ្ងន់ធ្ងរ ដែលវាអាចនឹងជួយបើកភ្នែក និងបេះដូងរបស់អ្នកដែលតែងតែប្រឆាំងនឹងលោកតាំងពីដំបូង។ មានស្ថានភាពមិនល្អជាច្រើន ដែលព្យាការីបានប្រែក្លាយវាទៅជាល្អវិញ តាមរយៈស្នាមញញឹម និងសំណើចរបស់លោក។ មានពេលមួយ អាណាស ពិន ម៉ាលីគ កំពុងដើរជាមួយព្យាការី ដែលពេលនោះលោកបានពាក់កន្សែងរុំករបស់លោក។ រំពេចនោះ មានបុរសប៉ាដាវី(ជាប្រជាជនដែលរស់នៅតាមវាលខ្សាច់ដាច់ស្រយាល) ម្នាក់បានចូលមក ហើយបានកន្ត្រាក់កន្សែងរុំករបស់

លោករហូតវាបានបន្សល់ស្លាកស្នាមក្រហមនៅលើករបស់លោក។ បន្ទាប់មក បុរសប៉ាដាវីនោះបានបន្លឺសម្លេងឡើងថា៖ នែ៎ មូហាំម៉ាត់! ចូរយកឱ្យខ្ញុំ នូវទ្រព្យសម្បត្តិមួយចំនួនរបស់អល់ឡោះដែលអ្នកមាន! បន្ទាប់មក រ៉ស៊ូលុលឡោះ ក៏បានបែរមុខមករកគេ ហើយសើច រួចបានសុំឱ្យសហាការីដែលជាអ្នកតំណាងរបស់លោក ដើម្បីផ្តល់របស់ខ្លះដល់បុរសប៉ាដាវីនោះ។ ពិតណាស់ វាជារឿងចម្លែកបំផុតដែលព្យាការីអាចញញឹមចេញនៅពេលជួបរឿងបែបនេះ។ នេះក៏ព្រោះលោកមានការអត់ធ្មត់ និងសេចក្តីមេត្តាករុណា ដែលគ្មានអ្នកណាអាចធ្វើបានក្រៅពីលោកនោះឡើយ។

ដូចដែលយើងបានឃើញច្បាស់ គឺព្យាការីបានដោះស្រាយស្ថានការណ៍ និងយល់ពីស្ថានភាពរបស់បុរសប៉ាដាវី ដែលបានបញ្ចេញនូវអាកប្បកិរិយាមិនល្អបែបនោះ ក៏ព្រោះតែគេមិនបានយល់អ្វីទាំងអស់។ ពេលខ្លះលោកញញឹមជាការឆ្លើយតបចំពោះអាកប្បកិរិយារបស់សហការីរបស់លោកផងដែរ ដូចជានៅក្នុងហេតុការណ៍នៃសមរភូមិ សាត អាស្សាលាស៊ីល នៅពេលដែល អាមរ៉ូរ ពិន អោស្ស ដែលជាមេដឹកនាំយោធា បានគេងយល់សប្តិ ដែលបណ្តាលឱ្យគាត់ស្ថិតក្នុងស្ថានភាពជូនូប។ ពេលនោះ អាមរ៉ូរ ពិន អោស្ស គ្រាន់តែការធ្វើតាយ៉ាំមុំ(ជូតមុខ និងដៃជាមួយនឹងធូលីដីជំនួសទឹក) ដោយមិនបានងូតទឹកនោះឡើយ ព្រោះគាត់បារម្ភថាគាត់នឹងធ្វើបាបខ្លួនឯង ប្រសិនបើគាត់ងូតទឹក ព្រោះតែកាលនោះអាកាសធាតុត្រជាក់ខ្លាំង។ បន្ទាប់មកគាត់ក៏បានដឹកនាំ សហការីដែលនៅសល់ធ្វើការថ្វាយបង្គំហ្វាជើរ(សឡាតសូពូហ) ដែលបណ្តាលឱ្យមានការជជែកគ្នាក្នុងចំណោមសហការីដែលបានដឹងពីស្ថានភាពរបស់គាត់។ ដូច្នេះហើយ ពួកគេបាននិយាយប្រាប់រ៉ស៊ូ-លុលឡោះ ដើម្បីចង់បានការពន្យល់ពីលោក ទាក់ទងនឹងរឿងនោះ។ ពេលនោះ អាមរ៉ូរ ពិន អោស្ស ក៏បានការពារសកម្មភាពរបស់គាត់ ដោយលើកយកព្រះបន្ទូលរបស់អល់ឡោះថា៖

**ហើយចូរពួកអ្នកកុំសម្លាប់ខ្លួនឯង! ពិតប្រាកដណាស់ អល់ឡោះ ពិតជាអាណិតអាសូរចំពោះពួកអ្នកបំផុត។**

*គួរអាន អាន់នីសាក ៤ : ២៩*

ក្រោយពេលបានស្តាប់អំណះអំណាងរបស់ អាមរូរ ពិន អោស្ស ព្យាការី បានសើច ដោយលោកមិននិយាយអ្វីទាំងអស់។ លោកតែងតែទទួលបានភាពរីករាយ នៅពេលដែលសហាការីរបស់លោក ចែករំលែកភាពរីករាយដល់លោក។ ពួកគេបានចែករំលែករឿងរ៉ាវជាមួយគ្នា និងសើចជាមួយគ្នា។ ជាធម្មតាលោកនឹងអង្គុយនៅក្នុងវិហាររបស់លោក បន្ទាប់ពីថ្វាយបង្គំហ្វាជើររួច។ ខណៈពេលដែលរង់ចាំថ្ងៃរះ ពេលខ្លះលោកបានឮដោយអចេតនា នូវអ្វីដែលសហាការីរបស់លោកនិយាយអំពីរឿងឆោតល្ងង់ដែលពួកគេបានធ្វើ ក្នុងសម័យចាហ៊ីលីយ៉ះ(សម័យនៃភាពល្ងង់ខ្លៅ) របស់ពួកគេ រហូតដល់ពួកគេសើច ហើយលោកក៏បានញញឹមផងដែរនៅពេលដែលបានឮ។ ស្នាមញញឹមមិនដែលបាត់ពីវង់ភក្ត្ររបស់ព្យាការីពេលណានោះឡើយ។ លោកចារៀរ ពិន អាប់ទុលឡោះ បាននិយាយថា៖

**ចាប់តាំងពីគាត់បានចូលកាន់អ៊ីស្លាមមក គឺគ្មានម្តងណាដែលគាត់បានឃើញវង់ភក្ត្ររបស់រ៉ស៊ូលុលឡោះនោះឡើយ លើកលែងតែមានស្នាមញញឹមជានិច្ចដែលវាពិតជាស្រស់ស្អាតខ្លាំងណាស់ ប្រៀបដូចព្រះច័ន្ទពេញបូណ៌មីដូច្នោះឯង។**

*ហាទីស ពូខរី ៣០៣៦ និង មូស្លីម ២៤៧៥*

ទោះយ៉ាងណាក៏ដោយ សំណើច និងស្នាមញញឹមរបស់ព្យាការី គឺមានដែនកំណត់។ លោកមិនដែលសើចខ្លាំងៗ ឬ ខឹកៗ ដោយមិនអាចគ្រប់គ្រងបាននោះឡើយ។ ភាគច្រើននៃការសើចរបស់លោក គឺគ្រាន់តែជាស្នាមញញឹមដ៏រីករាយតែប៉ុណ្ណោះ។ អ្នកស្រីអាអ៊ីស្ហះបាននិយាយថា៖

**ខ្ញុំមិនដែលឃើញព្យាការីសើចរហូតដល់កម្រិត ដែលគេអាចមើលឃើញក្រអូមមាត់របស់លោកនោះឡើយ ប៉ុន្តែលោកតែងតែញញឹមតែប៉ុណ្ណោះ។**

*ហាទីស ពូខរី ៤៨២៩ និង មូស្លីម ១៤៩៧*

នៅក្នុងហាទីសមួយផ្សេងទៀត អាប់ទុលឡោះ ពិន ហារីស បាននិយាយថា៖

**ការសើចរបស់ព្យាការី គឺគ្រាន់តែជាការញញឹមតែប៉ុណ្ណោះ។**

*ហាទីស តៀរមីហ្ស៊ី ៣៦៤២*

នេះហើយគឺជាការសើចរបស់បុរសដ៏ល្អឥតខ្ចោះម្នាក់នេះ។ ជាបុគ្គលដែលគេតែងតែឃើញលោកញញឹម ទាំងដែលការញញឹមនោះ មិនមែនជាគោលបំណងរបស់លោកនោះឡើយ។ ផ្ទុយទៅវិញ ស្នាមញញឹមដែលនៅលើមុខរបស់លោក គ្រាន់តែជាមធ្យោបាយដើម្បីកាត់បន្ថយទុក្ខព្រួយ និងធ្វើឱ្យបិត្តមានភាពទន់ភ្លន់តែប៉ុណ្ណោះ ជាពិសេសចំពោះអ្នកដែលនៅជុំវិញលោក។ នៅពេលដែលនៅម្នាក់ឯង ព្យាការីលោកមានភាពសោកសៅ និងព្រួយបារម្ភជាខ្លាំងអំពីជោគវាសនាប្រជាជាតិរបស់លោកនៅក្នុងថ្ងៃបរលោក ដែលជាថ្ងៃដែលរាល់អំពើទាំងអស់ដែលមនុស្សលោកបានប្រព្រឹត្តគឺនឹងត្រូវអល់ឡោះជាម្ចាស់ជំនុំជម្រះ។

ព្យាការីបានមានប្រសាសន៍ថា៖

**ដោយអល់ឡោះជាម្ចាស់ ឱប្រជាជាតិរបស់មូហាំម៉ាត់! បើអ្នកបានដឹងរឿងដូចដែលខ្ញុំបានដឹង នោះអ្នកនឹងសើចតិច ហើយយំច្រើនជាមិនខានឡើយ។**

*ហាទីស ពូខរី ១០៤៤*

បេះដូងរបស់ព្យាការីក៏មិនមែនជាថ្មនោះដែរ លោកមិនបានចាត់ទុកការយំជាសញ្ញានៃភាពទន់ខ្សោយសម្រាប់បុរសនោះទេ។ តាមពិតលោកជាមនុស្សដែលទន់ភ្លន់ មានបេះដូងពោរពេញដោយក្តីមេត្តាករុណា។ លោកយំយ៉ាងងាយ នៅពេលដែលស្ថានភាពសោកសៅបានកើតឡើងចំពោះលោក។

តើមានស្ថានភាពសោកសៅអ្វីខ្លះ ដែលបានកើតឡើងលើបុគ្គលដែលជាទីស្រលាញ់របស់អល់ឡោះម្នាក់នេះ? លោកធ្លាប់បានឆ្លងកាត់ស្ទើរតែរាល់ស្ថានភាពលំបាកទាំងអស់ មិនថាជាការស្លាប់នៃមនុស្សដែលលោកស្រលាញ់ បាត់បង់ទ្រព្យសម្បត្តិ និងទីជម្រក ត្រូវនិរទេសខ្លួន ការបង្អាប់បង្ខូច ការប្រមាថ មានរបួសលើរាងកាយ ការស្អប់ ត្រូវគេបដិសេធ ការសាកល្បង និងទុក្ខលំបាកគ្រប់ប្រភេទ ដែលជាការលំបាកខ្លាំងណាស់សម្រាប់មនុស្សយើង នាពេលបច្ចុប្បន្ននេះក្នុងការទ្រាំទ្រ។ នោះហើយជាអ្វីដែលអល់ឡោះបានសាកល្បង មកលើព្យាការីជាទីស្រលាញ់របស់ទ្រង់ដើម្បីលើកឋានៈរបស់លោកនៅថ្ងៃបរលោក។ សហាការីដែលមានឈ្មោះថា សាអាត់ ពិន អាពីវ៉ាកោស ធ្លាប់បានសួរទៅកាន់ព្យាការីថា៖ ក្នុងចំណោមមនុស្សជាតិទាំងអស់ តើអ្នកណាដែលត្រូវឆ្លងកាត់ការសាកល្បងដ៏លំបាកជាងគេបំផុត? ព្យាការីក៏បានតបថា៖

**គឺបណ្តាព្យាការី បន្ទាប់មក អ្នកដែលមានឋានៈជិតពួកគេបំផុត បន្ទាប់មកអ្នកដែលមានឋានៈ(បន្ទាប់) ជិតពួកគេបំផុត។ មនុស្សម្នាក់ៗត្រូវបានសាកល្បងយោងទៅតាមកម្រិតនៃជំនឿរបស់ពួកគេ។ ប្រសិនបើគេមានជំនឿរឹងមាំនៅក្នុងសាសនារបស់គេ នោះការសាកល្បងរបស់គេក៏កាន់តែធ្ងន់ដែរ ហើយប្រសិនបើជំនឿរបស់គេទន់ខ្សោយ នោះការសាកល្បងរបស់គេក៏ទៅតាមកម្រិតនោះដូចគ្នា។ មនុស្សទាំងឡាយនឹងត្រូវរងការសាកល្បងជាបន្តបន្ទាប់ រហូតដល់ពួកគេ ត្រូវបានគេទុកឱ្យដើរនៅលើផែនដីនេះ ដោយគ្មាននៅសល់អំពើបាបជាប់ខ្លួននោះឡើយ។**

*ហាទីស តៀរមីហ្ស៊ី ២៣៩៨*

ទោះយ៉ាងណាក៏ដោយ ព្យាការីមិនបានយំព្រោះតែការសាកល្បងដែលលោកបានជួបប្រទះទាំងនោះនោះទេ។ ផ្ទុយទៅវិញ លោកតែងតែយំរាល់ពេលដែលលោកធ្វើការសន្ទនា(ដោយការសូត្រគួរអាន និងការថ្វាយបង្គំ) ជាមួយជាមួយនឹងអល់ឡោះជាម្ចាស់។ អាល់ស៊ីខៀរ ពិន អាហ្វ បាននិយាយថា៖

**ខ្ញុំបានឃើញរ៉ស៊ូលុលឡោះកំពុងតែថ្វាយបង្គំ ហើយខ្ញុំក៏បានឮសំឡេងចេញពីក្នុងទ្រូងរបស់លោក ដូចជាសំឡេងទឹកពុះ ដោយសារការយំរបស់លោក។**

*ហាទីស ណាសាអ៊ី ១២១៤*

នៅក្នុងហាទីសមួយផ្សេងទៀត ព្យាការីបានស្នើសុំឱ្យ អាប់ទុលឡោះ ពិន ម៉ាសអូដ សូត្រគួរអានឱ្យលោកស្តាប់។ នៅពេលនោះ អាប់ទុលឡោះ ពិន ម៉ាសអូដ បានសូត្រជំពូក អាន់នីសាក រហូតដលវាក្យខណ្ឌនៃគម្ពីរ៖

**ដូច្នេះ តើស្ថានភាពមនុស្សលោកនឹងទៅជាយ៉ាងណា នៅពេលដែលយើងនាំយកអ្នកនាំសាររបស់ពួកគេ ដើម្បីធ្វើជាសាក្សីលើជាតិសាសន៍របស់ពួកគេ ហើយយើងបាននាំអ្នក(មូហាំម៉ាត់) ដើម្បីធ្វើជាសាក្សីលើប្រជាជនគ្រប់ជំនាន់ទាំងអស់។**

*គួរអាន អាន់នីសាក ៤ : ៤១*

ពេលបានឮវាក្យខណ្ឌមួយនេះ ព្យាការីបានសុំឱ្យគាត់ឈប់សូត្រមួយភ្លែត ខណៈដែលទឹកភ្នែករបស់លោកកំពុងស្រក់ហូរជោកថ្ពាល់ ដោយសារតែវាក្យខណ្ឌនោះបានពាល់អារម្មណ៍របស់លោកជាខ្លាំង។

# ព្យាការីមូហាំម៉ាត់
# ជាមួយជនពុតត្បុត

ពេលដ៏លំបាកបំផុត សម្រាប់មនុស្សម្នាក់ក្នុងធ្វើការអំពាវនាវនោះ គឺនៅពេលចាប់ផ្ដើម ដែលតម្រូវឱ្យមានការលះបង់ជាច្រើន។ ពុំមានមនុស្សច្រើនទេដែលអាចទប់ទល់នឹងរយៈពេលនៃការសាកល្បងនេះ លើកលែងតែអ្នកដែលមានឆន្ទៈមុតមាំ និងស្មោះត្រង់ប៉ុណ្ណោះ។ មនុស្សភាគច្រើននឹងចូលរួមនៅពេលដែលទទួលបានជោគជ័យហើយ អ្នកខ្លះគ្រាន់តែចូលរួមដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឯខ្លះទៀតគ្រាន់តែចូលរួម ព្រោះពួកគេអាចប្រមូលផលបានដោយមិនចាំបាច់ចូលរួមក្នុងការតស៊ូបណ្ដុះគ្រាប់ពូជនោះឡើយ។

រ៉ស៊ូលុលឡោះ បានតស៊ូដើម្បីផ្សព្វផ្សាយអ៊ីស្លាម ដោយការស៊ូទ្រាំបំផុត។ នៅក្នុងដំណាក់កាលដំបូងនៃ ការអំពាវនាវរបស់លោកនៅក្នុងទីក្រុង ម៉ាក្កះ ដែលមានរយៈពេល១៣ឆ្នាំមកនោះ គ្មានទេមនុស្សលាក់ពុត នៅក្នុងសហគមន៍មូស្លីមដែលនឹងធ្វើពុតជាបង្ហាញជំនឿរបស់ពួកគេ ដើម្បីគ្រាន់តែទទួលបានប្រយោជន៍នោះឡើយ។ ដោយសារតែសម័យនោះ ពោរពេញទៅដោយការសាកល្បង ភាពលំបាក និងការលះបង់ផ្សេងៗ ដែលជាក់ស្ដែងមិនទទួលបានផលប្រយោជន៍ដូចជាសម្ភារៈ ឬរង្វាន់អ្វីនោះឡើយ។ សូម្បីតែនៅដើមនៃយុគសម័យម៉ាទីណះ (ជារយៈពេល១០ឆ្នាំដែលព្យាការីរស់នៅក្រុងម៉ាទីណះ) ក្រុមពុតត្បុតនេះ គឺមិនទាន់ចាប់អារម្មណ៍គិតអំពីកលល្បិចនេះឡើយ រហូតដល់ពេលមួយ បន្ទាប់ពីការទទួលជ័យជម្នះរបស់កងទ័ពមូស្លីមនៅក្នុងសមរភូមិប៉ាទើរ ដែលបានបង្ហាញពីភាពខ្លាំងក្លារបស់ប្រជាជនមូស្លីម។ ដូច្នេះហើយក្រុមពុតត្បុតជាច្រើនបានព្យាយាមបន្លំខ្លួនជាមូស្លីម ដើម្បីទទួលបានគ្រប់ប្រភេទនៃរង្វាន់ ឬសម្ភារៈផ្សេងៗ ក៏ដូចជាដើម្បីទទួលបានឥទ្ធិពលនៅក្នុងជួរប្រជាជនមូស្លីម ដែលត្រូវបានគេមើលឃើញថាកំពុងរីកចម្រើនយ៉ាងឆាប់រហ័សនៅពេលនោះ។ ហើយក៏មានជនពុតត្បុតខ្លះទៀត បន្លំខ្លួនឡើង ព្រោះតែចង់ញុះញង់បង្កចលាចល និងរំខានដល់កិច្ចការរបស់ប្រជាជនមូស្លីម។

អល់ឡោះបានមានបន្ទូលនៅក្នុងគម្ពីគួរអានថា៖

ហើយមានមនុស្សមួយចំនួន(មនុស្សលាក់ពុត)បាននិយាយថា៖ យើងមានជំនឿលើអល់ឡោះ និងថ្ងៃបរលោក ប៉ុន្តែពួកគេមិនមែនជាអ្នកមានជំនឿនោះទេ។ ពួកគេកំពុងតែបោកបញ្ឆោតអល់ឡោះជាម្ចាស់ និងបណ្ដាអ្នកដែលមានជំនឿ។ ផ្ទុយទៅវិញ ពួកគេកំពុងតែបោកបញ្ឆោតខ្លួនឯង តែពួកគេមិនដឹងខ្លួនឡើយ។ នៅក្នុងចិត្តរបស់ពួកគេគឺមានជម្ងឺ(មន្ទិលសង្ស័យ) ដូច្នេះ អល់ឡោះបានបន្ថែមជម្ងឺនេះលើពួកគេថែមទៀត ហើយពួកគេនឹងទទួលទារុណកម្មយ៉ាងឈឺចាប់ ដោយសារតែពួកគេបានភូតកុហក។

*គួរអាន អាល់ប៉ាក៏រ៉ោះ ២ : ៨-១០*

ដូច្នេះរ៉ស៊ូលុលឡោះ ត្រូវមានការប្រុងប្រយ័ត្នជាខ្លាំង ក្នុងការប្រាស្រ័យទំនាក់ទំនងជាមួយក្រុមពុតត្បុតនេះ ពីព្រោះពីខាងក្រៅ ពួកគេបានប្រកាសជំនឿ និងបង្ហាញពីភក្ដីភាព ប៉ុន្តែជាតុពិតរបស់ពួកគេគឺផ្ទុយស្រលះ។ ភាពពុតត្បុតរបស់ពួកគេត្រូវបានលាក់បាំង ហើយពិបាកនឹងត្រូវគេមើលដឹងណាស់។

ជាទូទៅ រ៉ស៊ូលុលឡោះ បានប្រាស្រ័យទំនាក់ទំនងជាមួយពួកគេ លើសពីពាក្យថាយុត្តិធម៌ ពីព្រោះលោកដឹងថា ភាពពុតត្បុតនោះនឹងកាន់តែលេចឡើង ប្រសិនបើបរិយាកាសប្រែខុសប្រក្រតី ហើយអាចនឹងមានអ្វីកើតឡើងលើសពីនេះទៅទៀត ប្រសិនបើក្រុមនេះមានអារម្មណ៍ថាពួកគេត្រូវបានគេកំណត់គោលដៅ និងដាក់ឱ្យដាច់ដោយឡែកពីសង្គមរបស់ពួកគេ។

អស់រយៈពេលប្រហែល៩ឆ្នាំ ដែលព្យាការីបានដឹងអំពីវត្តមានរបស់ជនពុតត្បុតទាំងនេះ ក្នុងចំណោមសហគមន៍មូស្លីមម៉ាទីណះ ប៉ុន្តែលោកមិនដែលធ្លាប់បាត់វិធានការណាមួយប្រឆាំងនឹងពួកគេដោយផ្អែកលើពាក្យសម្ដីនោះទេ។ តែលោកផ្ដោតលើសកម្មភាពដើម្បីប្រឆាំងនឹងពួកគេ ដោយផ្អែកលើភស្ដុតាងច្បាស់លាស់ ដូចអ្វីដែលលោកធ្វើប្រាស្រ័យទំនាក់ទំនងជាមួយសហការីផ្សេងទៀត អ៊ុបឹងដែរ។

អល់ឡោះមានព្រះបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

**ហើយប្រសិនបើយើងមានចេតនា យើងពិតជានឹងបង្ហាញឱ្យអ្នកឃើញពួកគេ ហើយអ្នកពិតជានឹងស្គាល់ពួកគេតាមរយៈសញ្ញា(ពុតត្បុត)របស់ពួកគេជាមិនខាន។ ហើយអ្នកពិតជានឹងស្គាល់ពួកគេទៀតតាមរយៈអត្ថន័យនៃពាក្យសម្ដីរបស់ពួកគេ។ ហើយអល់ឡោះជ្រាបបៅផុត នូវរាល់ទង្វើរបស់ពួកអ្នក។**

*គួរអាន មូហាំម៉ាត់ ៤៧ : ៣០*

មិនមែនជារឿងដែលងាយស្រួលនោះទេក្នុងការរក្សានូវភាពយុត្តិធម៌ និងថែរក្សាអារម្មណ៍របស់មនុស្ស។ ពេលខ្លះរ៉ស៊ូលុលឡោះ អនុវត្តនូវវិធានការជាក់លាក់ ព្រោះតែចង់ឱ្យបានទទួលផលប្រយោជន៍សម្រាប់មនុស្សគ្រប់គ្នា ប៉ុន្តែត្រូវបានចាត់ទុកថាអយុត្តិធម៌ដោយអ្នកដែលមិនបានយល់នូវប្រាជ្ញា និងហេតុផលរបស់លោកទៅវិញ។ ដូចជាក្នុងអំឡុងពេលបន្ទាប់ពីសមរភូមិហូណៃននៅ តអៀហ្វ ដែលកងទ័ពមូស្លីមទទួលបានទ្រព្យជ័យភណ្ឌជាច្រើន។ ជាទូទៅទ្រព្យជ័យភណ្ឌត្រូវបានបែងចែកដោយស្មើភាព ទៅឱ្យកងទ័ពទាំងអស់ដែលបានចូលរួមក្នុងសមរភូមិ។ ប៉ុន្តែ ព្យាការីដឹងច្បាស់ថា ជាការយុត្តិធម៌នៅពេលនោះ គឺលោកត្រូវបែងចែកទៅឱ្យកងទ័ពម៉ាក្កះ(មូហាជីរីន)ឱ្យបានច្រើន ព្រោះតែពេលនោះកងទ័ពម៉ាក្កះទើបតែបានចូលកាន់សាសនាអ៊ីស្លាម ហើយនៅមានជំនឿទន់ខ្សោយនៅឡើយ។ មិនដូចជាកងទ័ពដែលមកពីម៉ាទីណះ(អាន់សើរ)នោះទេ ដែលនៅទីនោះជាយូរមកហើយ(មានជំនឿរឹងមាំ និងទ្រព្យជ័យភណ្ឌក៏ធ្លាប់ទទួលបានរហូតមក) និងតែងតែតស៊ូក្នុងសាសនារបស់អល់ឡោះ។ តែលើកនេះមិនបានទទួលចំណែកណាមួយនៃទ្រព្យជ័យភណ្ឌនោះទេ។ ការសម្រេចចិត្តរបស់ព្យាការីបែបនេះជៀសមិនផុតពីការអាក់អន់ចិត្ត នៅក្នុងចំណោមប្រជាជនអាន់សើរ ដែលបង្កឱ្យមានការប្រណែនរវាងពួកគេ។ ពេលនោះផងដែរ ពួកពុតត្បុតក៏មិនឱ្យឱកាសនេះ

ខកខាននោះដែរ ក្នុងការអុជអាលបំបែកបំបាក់ប្រជាជនអាន់សើរ និងប្រជាជនមូហាជីរីន ដែលបានរួបរួមគ្នាជាយូរមកហើយ។ ដោយនិយាយថារ៉ស៊ូលុលឡោះពេលនេះលែងខ្វល់ពីពួកយើងហើយ ព្រោះលោកបានជួបនឹងប្រជាជនម៉ាក្កះ និងគូរ៉ាយស៍វិញហើយ។ បន្ទាប់ពីព្យាការី បានឮដំណឹងបែបនោះភ្លាម លោកក៏បានកោះហៅប្រជាជនអាន់សើរមកភ្លាម ដើម្បីពន្យល់បកស្រាយដល់ពួកគេ៖

ឱ ប្រជាជនអាន់សើរ! មានដំណឹងមួយបានឮមកដល់ខ្ញុំអំពីពួកអ្នកថា ពួកអ្នកមានអារម្មណ៍មិនសប្បាយចិត្តមែនទេ? តើមិនមែនទេឬដែលអ្នកធ្លាប់បានវង្វេងហើយអល់ឡោះបានប្រទាននូវការចង្អុលបង្ហាញដល់អ្នកតាមរយៈខ្ញុំ? តើមិនមែនទេឬដែលអ្នកធ្លាប់នៅក្នុងស្ថានភាពនៃភាពទុរគ៌ត ហើយអល់ឡោះបានធ្វើឱ្យអ្នកមានទ្រព្យសម្បត្តិតាមរយៈខ្ញុំ? តើមិនមែនទេឬ ដែលអ្នកធ្លាប់នៅក្នុងស្ថានភាពនៃអរិយភាព(សត្រូវ)ចំពោះគ្នាទៅវិញទៅមក ហើយអល់ឡោះបានបន្ទន់ចិត្តឱ្យពួកអ្នកត្រូវរ៉ូវគ្នាតាមរយៈខ្ញុំ?

ពួកគេ(ប្រជាជននៃអាន់សើរ)បានឆ្លើយថា៖ ពិតប្រាកដណាស់ ឱ រ៉ស៊ូ-លុលឡោះ! លោកបានសួរទៀតថា៖ ហេតុអ្វីបានជាអ្នករាល់គ្នាមិនឆ្លើយតបនឹងខ្ញុំ ឱ ប្រជាជនអាន់សើរ។ ពេលនោះពួកគេបានតបវិញថា៖ តើឱ្យយើងឆ្លើយយ៉ាងដូចម្តេចថា ឱរ៉ស៊ូលុលឡោះ? ពិតប្រាកដណាស់ អល់ឡោះ និងរ៉សូលរបស់ទ្រង់គឺមានចិត្តសប្បុរស និងបានប្រទាននូវសេចក្តីសុខដល់ពួកយើង!

លោកបានមានប្រសាសន៍ថា៖ ដោយអល់ឡោះជាម្ចាស់! ប្រសិនបើដូចអ្វីដែលអ្នកប្រាថ្នាចង់បាន ចូរនិយាយមក និយាយការពិត ហើយគេនឹងជឿអ្នកថា៖ អ្នក(មូហាំម៉ាត់) បានមករកយើងក្នុងស្ថានភាពដែលត្រូវគេចោទថាភូតកុហក ប៉ុន្តែយើងបានជឿអ្នក! ហើយអ្នកបានមករកយើង ក្នុងស្ថានភាពដែលត្រូវគេបោះបង់ចោល ហើយយើងបានជួយអ្នក! ហើយអ្នកបានមករកយើងក្នុងនាមជា

ជនភៀសខ្លួន ហើយយើងបានផ្ដល់ជម្រកដល់អ្នកហើយអ្នកបានមករកយើងក្នុងស្ថានភាពក្រីក្រ ហើយយើងបានជួយអ្នក!

លោកបានបន្ថែមថា៖ តើអ្នកមានអារម្មណ៍ស្ដាយឬ ឱ្យប្រជាជនអាន់សើរ បំពោះទ្រព្យលោកិយបន្តិចបន្តួចនេះ! យើងបានធ្វើការផ្សះផ្សាដួងចិត្តរបស់អ្នកឱ្យបានយល់នូវសាសនាអ៊ីស្លាម ហើយផ្ដល់ឱ្យអ្នកនូវជំនឿពេញលេញ តើមិនទាន់គាប់ចិត្តអ្នករាល់គ្នាទៀតឬ? ឱប្រជាជនជនអាន់សើរអើយ! តើអ្នកមិនចង់បានទេ ឬ ឱ្យពួកគេ(មូហាជីរីន) ត្រឡប់ទៅផ្ទះសំបែងរបស់ពួកគេវិញ ដោយមានហ្វូងចៀម និងអូដ្ឋ ហើយអ្នកត្រឡប់ទៅផ្ទះរបស់អ្នកវិញជាមួយរ៉ស៊ូលុលឡោះ? ដោយព្រះជាម្ចាស់ដែលជីវិតរបស់ខ្ញុំ(មូហាំម៉ាត់) ស្ថិតនៅក្នុងដៃរបស់ទ្រង់! ប្រសិនបើគ្មានការធ្វើចំណាកស្រុកទេនោះ ខ្ញុំក៏នឹងមិនបានក្លាយជាផ្នែកមួយនៃប្រជាជនអាន់សើរនោះដែរ ហើយប្រសិនបើប្រជាជនទាំងអស់យកផ្លូវមួយ ហើយប្រជាជនអាន់សើរបានយកផ្លូវមួយផ្សេងទៀត ខ្ញុំនឹងជ្រើសយកផ្លូវនៃប្រជាជនអាន់សើរ។ បពិត្រអល់ឡោះជាម្ចាស់ សូមទ្រង់មេត្តាអាណិតអាសូរដល់ប្រជាជន អាន់សើរ និងកូនចៅទាំងអស់នៃពួកគេផង!

នៅពេលនោះ ប្រជាជនអាន់សើរបានស្រែកយំ រហូតដល់ពុកចង្ការរបស់ពួកគេសើមដោយទឹកភ្នែក ហើយពួកគេបានស្រែកថា៖ យើងពិតជារីករាយណាស់ចំពោះអ្វីដែលរ៉ស៊ូលុលឡោះបានរៀបចំ និងបែងចែកសម្រាប់ពួកយើង!

*ហាទីស អះម៉ាត់ ១១៧៣០*

ពួកពុតត្បុតដែលដឹកនាំដោយ អាប់ទុលឡោះ ពិន អ៊ូប៉ៃ មិនដែលឈប់បង្កភាពចលាចលក្នុងចំណោមប្រជាជនមូស្លីមឡើយ។ ជាក់ស្ដែងក្នុងអំឡុងពេលសមរភូមិ អូហូដ ដែលពួកគេមានចំនួនប្រហែលមួយភាគបីនៃកងទ័ពមូស្លីមទាំងមូលនៅពេលនោះ បានដកខ្លួនចេញពីសមរភូមិនៅនាទីចុងក្រោយ មុនពេលសង្គ្រាមផ្ទុះឡើង។ ពួកគេស្នាក់នៅក្នុងទីក្រុងម៉ាទីណះ ហើយមានបំណងមិនចូល

រួមជាមួយទាហានមូស្លីមតាំងពីដំបូងមកម្លេះ។ ទោះយ៉ាងណាក៏ដោយ ពួកគេមានចេតនាធ្វើអ្វីដែលពួកគេចង់ធ្វើ ដើម្បីឱ្យកងទ័ពមូស្លីមមានអារម្មណ៍រង្គោះរង្គើដោយការបាត់បង់កងទ័ពមួយផ្នែកធំរបស់ពួកគេ។

ដំបូងព្យាការីមិនចង់លាតត្រដាងអំពីមនុស្សពុតត្បុតទាំងនេះឡើយ។ តែការញុះញង់ និងការបង្កភាពចលាចលមិនចេះចប់របស់ពួកគេបានបង្ខំឱ្យព្យាការីបង្ហាញពីគ្រោះថ្នាក់របស់ពួកគេ ជាពិសេសពួកគេបានធ្វើឱ្យខូចកិត្តិយសរបស់លោក និងក្រុមគ្រួសាររបស់លោកឥតឈប់ឈរ ហើយបានព្យាយាមបំផ្លាញការរួបរួមគ្នានៃប្រជាជនមូស្លីម តាមរយៈការអំពាវនាវឱ្យមានការរើសអើងជាតិសាសន៍ដែលបានកើតឡើងជាញឹកញាប់។

បន្ទាប់ពីការស្លាប់របស់មេដឹកនាំរបស់ពួកគេ អាប់ទុលឡោះ ពិន អូប៉ៃ ក្រុមពុតត្បុតបានព្យាយាមរៀបចំចលនារបស់ពួកគេនៅក្នុងកន្លែងមួយដែលគ្មាននរណាម្នាក់អាចនឹងសង្ស័យ បន្ទាប់មកពួកគេបានសាងសង់វិហារមួយ(វិហារទីរ៉ត)នៅឆ្ងាយពីក្រុងម៉ាទីណះ។ ហើយបានរៀបផែនការក្បត់នឹងព្យាការី នៅពេលលោកត្រឡប់មកពីសមរភូមិតាពូកក្នុងឆ្នាំទី៩ នៃហ៊ិជរ៉ោះ។ តែទោះជាយ៉ាងណាក៏ដោយ អល់ឡោះបានរារាំងនូវល្បិចកលដ៏សាហាវរបស់ពួកគេ។ ទីបំផុតព្យាការីបានសម្រេចចិត្តបំផ្លាញវិហាររបស់ពួកគេនោះចោល ហើយបានបញ្ចប់ទំនាក់ទំនងទាំងអស់ជាមួយពួកពុតត្បុត។

អល់ឡោះមានព្រះបន្ទូលនៅក្នុងគម្ពីរគួរអានថា៖

**ហើយពួកដែលបានកសាងវិហារដើម្បីបង្កគ្រោះថ្នាក់ ដល់អ្នកមានជំនឿ ក៏ដូចជានាំឱ្យខូចជំនឿ និងបង្កការបែកបាក់រវាងបណ្តាអ្នកដែលមានជំនឿ ព្រមទាំងធ្វើជាកន្លែងសម្រាប់ជនណា ដែលបានធ្វើសង្គ្រាមប្រឆាំងនឹងអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់តាំងពីមុនមក។ ហើយពួកគេប្រាកដជានឹងស្បថថា៖ យើងមិនចង់បានអ្វីក្រៅពីផលល្អ អំពីការសាងសង់វិហារនេះឡើយ។ ហើយអល់ឡោះបានជាអ្នកធ្វើ**

សាក្សីថា ពិតប្រាកដណាស់ ពួកគេគឺជាពួកដែលភូតកុហក។ ចូរអ្នក(មូហាំម៉ាត់) កុំសឡាតក្នុងវិហារនោះជាដាច់ខាត។ តែវិហារគូហ្បាកដែលត្រូវបានគេកសាងឡើងសម្រាប់ជាគ្រឹះនៃការកោតខ្លាចអល់ឡោះតាំងពីថ្ងៃដំបូង វាស័ក្តិសមបំផុតដែលអ្នកត្រូវថ្វាយបង្គំនៅទីនោះ។ ដោយនៅទីនោះមានបុរសជាច្រើនដែលពួកគេចូលចិត្តភាពស្អាតស្អំ។ ហើយអល់ឡោះជាម្ចាស់ស្រលាញ់បណ្តាអ្នកដែលស្អាតស្អំ។

*គួរអាន អាត់តាវប៉ាត់ ៩ : ១០៧-១០៨*

# ព្យាការីមូហាំម៉ាត់
# ជាមួយសហការី

ប្រវត្តិសាស្ត្របានបន្សល់ទុកនូវអត្ថន័យនៃមិត្តភាពដ៏អស្ចារ្យដែលត្រូវបានបង្ហាញដោយបុគ្គលដ៏អស្ចារ្យជាមួយសហការីរបស់លោកយ៉ាងគួរឱ្យកត់សម្គាល់ និងពិតជាមិនធម្មតានោះឡើយភក្ដីភាពរបស់ពួកគេ។ ទំនាក់ទំនងដែលធ្វើឱ្យមិត្តភក្ដិហ៊ានលះបង់អ្វីៗគ្រប់យ៉ាង ដើម្បីមិត្តជាទីស្រលាញ់របស់ខ្លួន។ នេះក៏ព្រោះតែសេចក្ដីស្រលាញ់ដ៏ធំធេងដែលពួកគេមានឱ្យគ្នា។ ជាមួយគ្នានេះ ក៏មានមូលហេតុដ៏ចម្បងមួយទៀតផងដែរ នោះគឺអល់ឡោះទ្រង់បានប្រទាននូវភាពជោគជ័យដល់សាសនាមួយនេះ ពីពេលមួយទៅពេលមួយជាបន្តបន្ទាប់។

ជាការពិតណាស់ទំនាក់ទំនងរវាងព្យាការីជាមួយនិងសហការីរបស់លោក គឺប្រៀបដូចជាឪពុកហើយនិងកូន ដែលតែងតែគិតអំពីភាពប្រសើរឡើងរបស់កូន រីករាយចំពោះសុភមង្គលរបស់កូន សោកសៅនៅពេលមានឧបសគ្គ ឬគ្រោះថ្នាក់ណាមួយដែលបានកើតឡើងលើកូន។ លោកយល់អំពីអារម្មណ៍នៃការឈឺចាប់របស់ពួកគេ ក៏ដូចជា ចែករំលែកបញ្ហា និងឈ្វេងរកដំណោះស្រាយរួមគ្នា។ ដោយលោកគឺមានតួនាទីជាអ្នកអប់រំ ណែនាំ ប្រឹក្សា និងផ្សេងៗទៀត ដែលទាំងអស់នោះគឺដើម្បីសុភមង្គល និងជោគជ័យរបស់កូន បើទោះបីជាមានសហការីមួយចំនួនមានអាយុច្រើនជាងលោកក៏ដោយ។

ព្យាការីមានប្រសាសន៍ទៅកាន់សហការីជាទីស្រលាញ់របស់លោកថា៖

**ពិតណាស់ ខ្ញុំប្រៀបដូចជាឪពុករបស់អ្នករាល់គ្នា ហើយខ្ញុំនឹងង្រៀនដល់អ្នករាល់គ្នា។**

*ហាទីស អាពូដាវូឌ (៨)*

ហើយនៅពេលដែល អាល់អាប់ពើស ពិន អាប់ទុលមូតឡិប ដែលជាឪពុកមារបស់ព្យាការី ត្រូវបានគេសួរគាត់ថា៖ តើអ្នកណាដែលចាស់ជាង? អ្នក ឬព្យាការី? គាត់បានឆ្លើយថា៖ ព្យាការីមានវ័យចំណាស់ជាង [ក្នុងន័យធៀប] ទោះបីជាខ្ញុំបានកើតមុនលោកក៏ដោយ។

នេះហើយ រ៉ស៊ូលុលឡោះ លោកជាមនុស្សម្នាក់ដែលត្រូវបានសហការី ស្រលាញ់ និងគោរពជាខ្លាំង។ លោកជាអភិបាល ជាទីប្រឹក្សា របស់សហការី គ្រប់ពេលវេលាដែលពួកគេត្រូវការ។ អូស្មាន ពិន អាហ្វហ្វាន បាននិយាយថា៖

**ដោយអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ យើងបាននៅជាប់រ៉ស៊ូលុលឡោះ មិនថាក្នុងពេលធ្វើដំណើរ និងមិនធ្វើដំណើរនោះទេ លោកតែងតែទៅសួរសុខទុក្ខពួកយើង ចូលរួមពិធីបុណ្យសពរបស់ពួកយើង ចេញទៅប្រយុទ្ធជាមួយពួកយើង ជួយលួងលោម និងរំលែកទុក្ខពួកយើង តាមមធ្យោបាយដែលលោកអាចធ្វើបាន។**

*ហាទីស ហាគីម ៥៣៩៨*

សូម្បីតែ អាពូ សាហ្វយ៉ាន ដែលតាំងខ្លួនជាសត្រូវ និងតែងតែប្រឆាំងជាមួយនឹងរ៉ស៊ូលុលឡោះ ក៏ធ្លាប់បាននិយាយដែរថា៖

**ខ្ញុំមិនដែលឃើញនរណាម្នាក់ ដែលស្រលាញ់ចំពោះនរណាម្នាក់ទៀត ដូចដែលសហការីរបស់មូហាំម៉ាត់ ស្រលាញ់ចំពោះមូហាំម៉ាត់នោះឡើយ!**

*ហាទីស អ៊ីពិន ហ៊ីសាម ៣ : ១២៦-១២៧*

សាអាត់ ពិន មូអាស្ស បាននិយាយទៅកាន់ព្យាការីក្នុងអំឡុងពេលសមរភូមិប៉ាទើរថា៖

**ឱ រ៉ស៊ូលុលឡោះ តើអ្នកចង់ឱ្យពួកយើងសាងសង់ជម្រកសម្រាប់អ្នកអង្គុយសម្រាក ហើយនិងរៀបចំសេះសម្រាប់អ្នកជិះដែរឬទេ? ខណៈពេលដែលយើងនឹងប្រឈមមុខនឹងសត្រូវរបស់យើងបន្តិចទៀតនេះ ប្រសិនបើអល់ឡោះទ្រង់ផ្តល់នូវជ័យជម្នះសម្រាប់ពួកយើងក្នុងការប្រយុទ្ធនេះ គឺវាជាការចង់បានបំផុតហើយសម្រាប់យើង**

ទាំងអស់គ្នា ។ ប៉ុន្តែប្រសិនបើបរាជ័យវិញនោះ ចូរអ្នកឡើងអង្គុយលើសត្វសេះរបស់អ្នក ហើយត្រលប់ទៅម៉ាទីណះវិញចុះ ដើម្បីរស់នៅជាមួយប្រជាជនរបស់យើងនៅទីនោះ។ ដោយអល់ឡោះជាម្ចាស់! មនុស្សនៅទីនោះ ពួកគេក៏ស្រលាញ់អ្នកដូចគ្នា ឬប្រហែលជាលើសពីសេចក្តីស្រលាញ់របស់យើងចំពោះអ្នកទៅទៀត។ បើពួកគេបានដឹងថាពួកយើងកំពុងតែប្រយុទ្ធនោះ នោះពួកគេនឹងមិនទៅណាចោលអ្នកឡើយ ពួកគេស្រលាញ់អ្នកខ្លាំងណាស់ ពួកគេនឹងជួយអ្នកជាមិនខាន!

*ហាទីស ប៉ៃហាគី ៣/៤៤*

អាំរូរ ពិន អោស្ស ក៏បានសម្តែងនូវសេចក្តីស្រលាញ់ ដែលមិនអាចកាត់ថ្លៃបានរបស់គាត់ចំពោះព្យាការីផងដែរ នៅក្នុងពេលសូត្រសាហាហ្ទះ (ការប្រកាសជំនឿ) របស់គាត់មុនទទួលមរណភាពថា៖

**គ្មាននរណាម្នាក់ដែលខ្ញុំស្រលាញ់ជាងអ្នកនាំសាររបស់អល់ឡោះនោះឡើយ ហើយក៏គ្មាននរណាដែលអស្ចារ្យជាងលោកនោះដែរនៅក្នុងកែវភ្នែករបស់ខ្ញុំ ។**

*ហាទីស មូស្លីម ១២១*

អាលី ពិន អាពី តឡិប ធ្លាប់ត្រូវបានគេសួរអំពីកម្រិតនៃសេចក្តីស្រលាញ់ដែលសហាការីមានចំពោះព្យាការីបែបណា គាត់បាននិយាយថា៖

**ដោយអល់ឡោះជាម្ចាស់! ពួកយើងស្រលាញ់លោកជាងទ្រព្យសម្បត្តិរបស់យើង កូនចៅរបស់យើង ឪពុកម្តាយរបស់យើង និងលើសពីទឹកត្រជាក់ នៅពេលដែលស្រេកទឹកខ្លាំងទៅទៀត។**

*ហាទីស កទី អ៊ីយ៉ាទ (១២១៦)*

ស៊ែលុលឡោះ នឹងសួររកសហការីរបស់លោកនៅពេលដែលបាត់មុខពួកគេ ហើយលោកនឹងសួរអំពីស្ថានភាពរបស់ពួកគេ។ ប្រសិនបើពួកគេឈឺ លោកនឹងទៅសួរសុខទុក្ខពួកគេជាបន្ទាន់។ ប្រសិនបើពួកគេខ្វះខាត លោកនឹងផ្តល់ជំនួយភ្លាមតាមដែលលោកអាចធ្វើទៅបាន។ នេះហើយជាភាពស្និទ្ធស្នាលរបស់ព្យាការី ជាមួយនឹងសហការីរបស់លោក ដោយមិនគិតពីអ្វីទាំងអស់ ទោះបីមានភាពខុសគ្នានៃអាយុ ទ្រព្យសម្បត្តិ ឬឋានៈក៏ដោយ។ ជាក់ស្តែងក្នុងអំឡុងពេលនៃសមរភូមិ តាពូក ដែលកងទ័ពមូស្លីមមានចំនួន ៣ម៉ឺននាក់ មកពីគ្រប់ទិសទីបានប្រមូលផ្តុំគ្នាដើម្បីប្រឈមមុខនឹងកងទ័ព ប៊ីហ្សីនទីន(តួរគីបច្ចុប្បន្ន) ព្យាការីបានក្រឡេកមើលទៅសហការីរបស់លោក ជាពិសេសក្នុងអំឡុងពេលធ្វើដំណើរ។ ហើយកបានសួរថា៖ តើកាអាប់ ពិន ម៉ាលីគ កំពុងធ្វើអ្វី? លោកសួរអំពីស្ថានភាពរបស់គាត់ ហើយព្យាយាមស្វែងរកគាត់ក្នុងចំណោមកងទ័ពរាប់ម៉ឺននាក់។

កង្វល់របស់ព្យាការី មិនត្រឹមតែត្រូវបានកំណត់ចំពោះសហការី ឬនៅក្នុងសមរភូមិប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ លោកក៏បានបង្ហាញពីការយកចិត្តទុកដាក់របស់លោកចំពោះសហការានីដូចគ្នាដែរ។ ជាឧទាហរណ៍ មានស្ត្រីចំណាស់ទុគ៌តម្នាក់ដែលតែងតែសម្អាតវិហារ ស្រាប់តែលែងឃើញមុខគាត់នៅវិហារមួយរយៈ ហើយក៏គ្មានដំណឹងពីគាត់ដែរ។ ព្យាការីបានសួរអំពីស្ថានភាពរបស់គាត់ តែត្រូវបានគេប្រាប់ថា គាត់បានទទួលមរណភាពទៅហើយ។ ព្យាការី ពោរពេញទៅដោយទុក្ខព្រួយ និងសោកស្តាយជាខ្លាំងពេលឮដំណឹងនោះ ហើយលោកក៏បានមានប្រសាសន៍ថា៖

**ហេតុអ្វីបានជាពួកអ្នកមិនជូនដំណឹងដល់ខ្ញុំ អំពីការទទួលមរណភាពរបស់គាត់? បន្ទាប់មកលោកបានទៅកាន់ផ្នូររបស់គាត់ ដើម្បីបួងសួងសុំសេចក្តីសុខដល់គាត់។**

*ហាទីស ពូខរី ៤៦០ និង មូស្លីម ៩៥៦*

បុរសម្នាក់នេះហើយ ដែលតែងតែយកចិត្តទុកដាក់ក្នុងការណែនាំទៅកាន់សហការីឱ្យឈានទៅរកសេចក្ដីល្អ។ ពួកគេតែងតែត្រូវការលោកដើម្បីផ្ដល់ការណែនាំ និងផ្ដល់ដំបូន្មានគ្រប់ស្ថានការណ៍ទាំងអស់។ លោកតែងតែព្យាយាមឈ្វេងយល់ពីបញ្ហា និងស្ថានភាពនៃសហការីគ្រប់គ្នា ហើយតែងតែផ្ដល់ដំបូន្មានជាបន្តបន្ទាប់សម្រាប់ពួកគេ ឱ្យបានសមស្របទៅតាមស្ថានភាពជាក់ស្ដែងរបស់ពួកគេ។

ជាក់ស្ដែងលោកត្រូវបានសួរដោយមនុស្សចំនួនបីនាក់ ក្នុងពេលផ្សេងគ្នាទាក់ទងនឹងទង្វើអ្វីដែលអល់ឡោះស្រលាញ់បំផុត។

លោកបានឆ្លើយតបទៅកាន់បុរសទីមួយថា៖

**ការមានជំនឿលើអល់ឡោះ និងជីហាត(តស៊ូ)ក្នុងបុព្វហេតុរបស់ទ្រង់។**

*ហាទីស មូស្លីម ៨៤*

បំណែកសម្រាប់បុរសម្នាក់ទៀត លោកបានឆ្លើយប្រាប់គេថា៖

**ការថ្វាយបង្គំ មួយថ្ងៃ៥ពេលឱ្យបានទាប់តាមពេលវេលារបស់វា សេចក្ដីសប្បុរសចំពោះមាតាបិតា និងការជីហាត(តស៊ូ)ក្នុងបុព្វហេតុរបស់អល់ឡោះជាម្ចាស់។**

*ហាទីស ពូខរី ៧៥៣៤*

និងសម្រាប់បុរសទីបីវិញ លោកបានឆ្លើយប្រាប់គេថា៖

**មានជំនឿលើអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ បន្ទាប់មក ជីហាត(តស៊ូ) ក្នុងបុព្វហេតុរបស់ទ្រង់ និងបន្ទាប់មកទៀត គឺការធ្វើធម្មយាត្រា(ហាជ្ជី) ដែលត្រូវបានអល់ឡោះទទួលយក។**

*ហាទីស ពូខរី ១៥១៩*

សហការីខ្លះក៏បានសុំយោបល់សម្រាប់ខ្លួនគេផ្ទាល់ពីព្យាការីផងដែរ ហើយលោកបានទូន្មានដល់សហការីរបស់លោក ដោយផ្តោតទៅលើស្ថានភាពរបស់ពួកគេរៀងៗខ្លួនថា៖

**ចូរអ្នកអត់ធ្មត់ និងទប់កំហឹង។**

*ហាទីស ពូខរី ៦១១៦*

**ចូរកោតខ្លាចអល់ឡោះជាម្ចាស់។**

*ហាទីស អះម៉ាត់ ៩៧២៤*

**ចូរកុំធ្វើជាអ្នកដែលចូលចិត្តប្រមាថអ្នកដទៃ។**

*ហាទីស អះម៉ាត់ ២០៦៧៨*

**ត្រូវមានសុជីវធម៌ ហើយត្រូវបង្កើននូវអំពើល្អរបស់ខ្លួន**
**ដើម្បីជម្រះនូវអំពើអាក្រក់។**

*ហាទីស អះម៉ាត់ ២១៤០៣*

**ចូរកុំមើលស្រាលអំពើល្អណាមួយឱ្យសោះ**
**សូម្បីតែជារឿងតូចតាចក៏ដោយ។**

*ហាទីស អាពូដាវូដ ៤០៨៤*

នេះហើយជារបៀបដែលព្យាការីបានបង្រៀនប្រជាជាតិរបស់លោកអំពីអត្ថន័យនៃមិត្តភាព៖ ការបង្រៀនឱ្យដឹងគុណដល់មិត្ត ធ្វើឱ្យមិត្តបានសប្បាយចិត្ត និងផ្តល់កិត្តិយសដល់មិត្ត។ ទំនាក់ទំនងរវាងព្យាការី ជាមួយនឹងសហការីរបស់លោក មិនដូចជាស្តេចដែលព្រះប្រមុខនៃទ្រង់ ពោរពេញដោយមន្ត្រី ឬពិធីការឡើយ។ ផ្ទុយទៅវិញ ទំនាក់ទំនងរបស់ពួកគេ គឺពោរពេញទៅដោយសេចក្តីអាណិតស្រលាញ់ ការយកចិត្តទុកដាក់ ការគោរព និងការដឹងគុណ ដែលនេះជាលក្ខណៈពិសេសនៅក្នុងទំនាក់ទំនងដែលមនុស្សជាតិត្រូវការ។

# ព្យាការីមូហាំម៉ាត់
# ជាមួយស្ត្រី

ការមកដល់របស់ព្យាការីបានលើកកម្ពស់ឋានៈរបស់ស្ត្រី ដោយផ្តល់ឱ្យពួកគេនូវសិរីរុងរឿង កិត្តិយស និងតួនាទីក្នុងសង្គមដែលត្រូវបានគេបដិសេធចំពោះពួកនាងរាប់ពាន់ឆ្នាំមកហើយនៅជុំវិញពិភពលោក។ នៅសម័យនោះ ស្ត្រីត្រូវបានគេចាត់ទុកដូចជាទំនិញដែលអាចជួញដូរបានតាមចិត្ត និងបោះបោលនៅពេលណាក៏បាន។ ពួកនាងត្រូវបានគេមើលឃើញថាជារបស់សម្រាប់បំពេញតណ្ហា ឬគ្រាន់តែជាទាសករប៉ុណ្ណោះ។ ពួកនាងមិនដែលត្រូវបានគេផ្តល់ឱ្យនូវតួនាទី ឬឋានៈអ្វីមួយនៅក្នុងសង្គមឡើយ។ ជារឿយៗ ពួកនាងត្រូវបានគេមើលងាយ និងចាត់ទុកថាគ្មានប្រយោជន៍។ សហគមន៍អារ៉ាប់នៅទីក្រុងម៉ាក្កះ គ្មានករណីលើកលែងនោះទេ ដោយពួកគេបានចាត់ទុកកំណើតកូនស្រីជាប្រភពនៃភាពអាម៉ាស់ដែលត្រូវតែលាក់បាំង។ រហូតដល់ពួកគេបានអនុវត្តនូវការសម្លាប់កូនស្រីដែលទើបនឹងកើតរបស់ពួកគេ។ រហូតពេលដែលព្យាការី មូហាំម៉ាត់មកដល់ លោកក៏បានអំពាវនាវទៅកាន់អរិយធម៌ និងយុត្តិធម៌វិញ។ ស្ត្រីត្រូវបានផ្តល់សិទ្ធិស្មើគ្នាដូចបុរសក្នុងការទាមទារ និងការសម្រេចចិត្ត កម្មសិទ្ធិ មរតក តួនាទី សង្គម និងសិទ្ធិផ្សេងៗទៀត។ គម្ពីរគួរអានបានមានបន្ទូលទៅកាន់ស្ត្រីតាមរបៀបដូចគ្នាដែលព្រះបានមានបន្ទូលទៅកាន់បុរស។

អល់ឡោះមានព្រះបន្ទូលថា៖

**អ្នកណាហើយដែលបានសាងអំពើល្អក្នុងចំណោមបុរស ឬស្ត្រី ហើយគេជាអ្នកមានជំនឿទៀតនោះ គឺយើងពិតជានឹងធ្វើឱ្យគេមានជីវិតរស់នៅដ៏ល្អប្រសើរ និងតបស្នងនូវផលបុណ្យទៅដល់ពួកគេ ដោយសារតែអំពើល្អដែលពួកគេធ្លាប់បានសាង។**

*គួរអាន អាន់ណាហាល ១៦ : ៩៧*

នៅក្នុងវាក្យខណ្ឌផ្សេងទៀត ទ្រង់ក៏បានមានព្រះបន្ទូលថា៖

ហើយម្ចាស់របស់ពួកគេបានទទួលយក(ការទូអាបួងសួង)ពីពួកគេ
ពិតប្រាកដណាស់ ពួកយើងមិនបំបាត់នូវរាល់ទង្វើដែលពួកអ្នកបានធ្វើ
នោះឡើយ ទោះបីជាបុរស ឬស្ត្រីក្តី ដោយពួកអ្នកមកពីពូជអម្បូរតែមួយ។

*គួរអាន អាលីអ៊ិមរ៉ន ៣ : ១៩៥*

នៅក្នុងវាក្យខណ្ឌផ្សេងទៀត ទ្រង់មានព្រះបន្ទូលថា៖

ពិតប្រាកដណាស់ បណ្តាអ្នកមូស្លីម និងបណ្តាអ្នកមានជំនឿ និងបណ្តាអ្នកគោរព
ប្រតិបត្តិ និងបណ្តាអ្នកសច្ចៈ និងបណ្តាអ្នកដែលអត់ធ្មត់ និងបណ្តាអ្នកឱនលំទោន
និងបណ្តាអ្នកបរិច្ចាគទាន និងបណ្តាអ្នកបួសតមអាហារ និងបណ្តាអ្នកដែលរក្សា
កេរ្តិ៍ខ្មាស់របស់ពួកគេ ហើយនិងបណ្តាអ្នកដែលតែងតែរំលឹកទៅចំពោះអល់ឡោះ
ទាំងប្រុសស្រី គឺអល់ឡោះបានរៀបចំសម្រាប់ពួកគេនូវការអភ័យទោស និងផល
បុណ្យដ៏ធំធេង(ឋានសួគ៌)។

*គួរអាន អាល់អះសាប ៣៣ : ៣៥*

និងនៅក្នុងវាក្យខណ្ឌផ្សេងទៀត ទ្រង់មានព្រះបន្ទូលថា៖

ហើយបណ្តាអ្នកដែលមានជំនឿទាំងប្រុសទាំងស្រី គឺពួកគេជួយគ្នាទៅវិញទៅមក
ប្រើគ្នាឱ្យសាងអំពើល្អ និងហាមឃាត់គ្នាពីការប្រព្រឹត្តអំពើអាក្រក់ ហើយពួកគេ
ប្រតិបត្តិសឡាតថ្វាយបង្គំ និងបរិច្ចាគហ្សាកាត់ និងគោរពប្រតិបត្តិតាមបទបញ្ជា
អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់(មូហាំម៉ាត់)។ អ្នកទាំងនោះ គឺអល់ឡោះ
នឹងអាណិតស្រលាញ់ពួកគេ។ ពិតប្រាកដណាស់ អល់ឡោះមានឫទ្ធិអំណាចបេស្កា
និងមហាប្រាជ្ញាញាណ។

*គួរអាន អាត់តាវ៉ាស ៩ : ៧១*

ព្យាការីបានបង្ហាញនូវអារម្មណ៍ដែលពោរពេញទៅដោយ សេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់ទៅកាន់ស្ត្រី ដូចជាលោកបានហាមឪពុកទាំងឡាយមិនឱ្យរៀបការកូនស្រីរបស់ពួកគេ ដោយគ្មានការយល់ព្រមពីពួកនាងនោះទេ ព្រមទាំងមិនឱ្យយកទ្រព្យសម្បត្តិរបស់ពួកនាងដោយគ្មានហេតុផល ដែលជាទម្លាប់ធម្មតាក្នុងសម័យចាហ៊ីលីយ៉ះ (សម័យនៃភាពល្ងង់ខ្លៅ)ធ្លាប់ធ្វើនោះទេ។ ហើយលោកក៏បានហាមប្តីពីការត្រឡប់ទៅផ្ទះវិញ នៅពេលយប់ដោយមិនបានប្រាប់ភរិយាជាមុន ដើម្បីការពារកុំឱ្យភរិយាមានការសង្ស័យ ឬបារម្ភអំពីប្តី របស់ពួកនាងក៏ដូចជាដើម្បីឱ្យនាងអាចមានពេលវេលាសម្រាប់រៀបចំខ្លួន។

តម្លៃរបស់ស្ត្រី ត្រូវបានទទួលស្គាល់ដោយក្បួនច្បាប់ និងនីតិសាស្ត្រនៃសាសនាអ៊ីស្លាម។ អូមើរ ពិន ខុត្តប ក៏បាននិយាយថា៖

**ដោយអល់ឡោះជាម្ចាស់! នៅមុនសម័យអ៊ីស្លាមមកដល់ ដែលជាសម័យនៃភាពល្ងង់ខ្លៅ យើងមិនបានពិចារណាឡើយថាស្ត្រីមានឋានៈ រហូតដល់អល់ឡោះ ទ្រង់បានបើកបង្ហាញដល់ពួកយើងអំពីពួកនាង( ទាក់ទងនឹងការបង្គាប់ឱ្យបំពេញសិទ្ធិរបស់ពួកនាង )។**

*ហាទីស ពូខរី ៥២៤៦ និង មូស្លីម ៧១៥*

ពិតប្រាកដណាស់ ព្យាការី ពិតជាបានឱ្យតម្លៃ និងអាណិតស្រលាញ់ស្ត្រីជាខ្លាំង។ លោកបានមានប្រសាសន៍ថា៖

**អ្នកដែលល្អបំផុត គឺជាអ្នកដែលធ្វើល្អបំផុតចំពោះភរិយារបស់គេ ហើយខ្ញុំគឺជាអ្នកដែលធ្វើល្អបំផុតចំពោះភរិយារបស់ខ្ញុំជាងគេ។**

*ហាទីស អ៊ីបនូ ម៉ាជះ ១៩៧៧*

ព្យាការីបានភ្ជាប់នូវឋានៈ ឬស្តង់ដារសម្រាប់បុរសទៅតាមកម្រិតនៃសេចក្តីសប្បុរស និងការឱ្យតម្លៃដែលពួកគេបានផ្តល់ទៅចំពោះភរិយារបស់ពួកគេ។ ដោយស្វាមីត្រូវខិតខំធ្វើល្អចំពោះភរិយារបស់ពួកគេ ដើម្បីក្លាយជាអ្នកដែលធ្វើតាមព្យាការីពិតប្រាកដ។ នៅពេលដែលស្វាមីនៅក្នុងសង្គមអារ៉ាប់ពួកគេហាក់ដូចជាផ្តាច់ការ ឬកៀបសង្កត់ចំពោះភរិយាបស់ពួកគេ ដោយពួកគេចាត់ទុកថានោះជាសញ្ញានៃភាពជាបុរសពិតនោះ រ៉ស៊ូលុលឡោះ ក៏បានហៅពួកគេមក ហើយមានប្រសាសន៍ទូន្មានទៅកាន់ពួកគេថា៖

**ចូរទទួលយកដំបូន្មានរបស់ខ្ញុំ ដោយការល្អចំពោះស្ត្រី! ស្ត្រីត្រូវបានបង្កើតឡើងពីឆ្អឹងជំនីដែលកោង ហើយផ្នែកដែលកោងបំផុតនៃឆ្អឹងជំនីគឺផ្នែកខាងលើរបស់វា។ ប្រសិនបើអ្នកព្យាយាមតម្រង់ នោះវានឹងបាក់ ហើយប្រសិនបើអ្នកទុកវាឱ្យនៅដដែល វានឹងនៅតែកោង។ ដូច្នេះ ចូរទទួលយកដំបូន្មានរបស់ខ្ញុំ ដោយការធ្វើល្អចំពោះស្ត្រី។**

*ហាទីស មូស្លីម ១៤៦៨*

នៅក្នុងហាទីសមួយផ្សេងទៀត លោកបានមានប្រសាសន៍ថា៖

**ចូរកោតខ្លាចអល់ឡោះចំពោះស្ត្រី! ដ្បិតអ្នកបានទទួលពួកនាងជាទំនួលខុសត្រូវពីអល់ឡោះជាម្ចាស់ ហើយមានសិទ្ធិរួមដំណេកស្របច្បាប់ជាមួយនឹងពួកនាងតាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់ (ដោយធ្វើកិច្ចសច្ចាព្រមព្រៀង(អ៊ីចាប កូពូល) ពីអាណាព្យាបាលកូនក្រមុំ ជាមួយនឹងកូនកំលោះ)។**

*ហាទីស មូស្លីម ១២១៨*

ព្យាការីបានអនុវត្តនូវអ្វីដែលលោកបានមានប្រសាសន៍មុនគេ។ លោកជាស្វាមីដែលបេះគ្រប់បែបយ៉ាង ជាមនុស្សដែលឧស្សាហ៍ព្យាយាម។ ដោយជារឿយៗ

លោកបានជួយកិច្ចការភរិយារបស់លោកក្នុងការរៀបចំទុកដាក់ផ្ទះសំបែង និងជួយការងារផ្សេងៗទៀត។ មិនតែប៉ុណ្ណឹងលោកក៏ជាស្វាមីដែលពោរពេញដោយមនោសញ្ចេតនាជាមួយភរិយា និងមិនរឹងរូសនោះឡើយ។

អ្នកស្រីអាអ៊ីស្ហះភរិយារបស់លោកធ្លាប់ត្រូវបានគេសួរថា៖ តើជាធម្មតាព្យាការីធ្វើអ្វីពេលនៅផ្ទះ? អ្នកស្រីបានឆ្លើយថា៖

**លោកតែងតែជួយកិច្ចការគ្រួសាររបស់លោក ហើយពេលលោកបានឮអាហ្សាន (ការប្រកាសប្រាប់ពីការចូលមកដល់នៃវេលាសឡាតថ្វាយបង្គំ) លោកក៏ចេញទៅវិហារ(ម៉ាស្ជិទ)។ លោកជាស្វាមីដែលជួយធ្វើកិច្ចការផ្ទះច្រើនណាស់។**

*ហាទីស ពូខរី ៥៣៦៣*

**លោកដេរសម្លៀកបំពាក់ និងស្បែកជើងខ្លួនឯង និងធ្វើកិច្ចការទូទៅដែលបុរសតែងតែធ្វើនៅផ្ទះ។**

*ហាទីស អះម៉ាត់ ២៤៩០៣*

រ៉ស៊ូលុលឡោះ ក៏ជាស្វាមីដែលតែងតែយកចិត្តទុកដាក់ចំពោះភរិយាផងដែរ។ អ្នកស្រីអាអ៊ីស្ហះបានរៀបរាប់ថា៖

**លោកថើបភរិយារបស់លោកសិន មុនពេលចេញទៅថ្វាយបង្គំនៅម៉ាស្ជិទ។**

*ហាទីស អាពូដោឌ ១៧៩*

**រ៉ស៊ូលុលឡោះ ហើយនិងខ្ញុំ ធ្លាប់ងូតទឹកពីធុងទឹកតែមួយ ហើយយើងបានដងទឹកស្រោចក្នុងពេលជំណាលគ្នា។**

*ហាទីស ពូខរី ២៧៣*

ដូច្នេះ ការធ្វើល្អចំពោះភរិយា គឺជាផ្នែកមួយនៃការគោរពសក្ការៈ ដែលត្រូវបានគេជម្រុញយ៉ាងខ្លាំងនៅក្នុងសាសនាអ៊ីស្លាម។ មានភស្តុតាងជាច្រើន ដែលរ៉ស៊ូ-លុលឡោះ ក៏ដូចជាអ្នកជំនាន់មុនបានបង្ហាញយ៉ាងច្បាស់ថា ពួកគេពិតជាបានធ្វើល្អជាខ្លាំងចំពោះភរិយារបស់ពួកគេ។ ប្រសិនបើការធ្វើល្អចំពោះភរិយា ដោយចេតនាល្អចំពោះអល់ឡោះជាម្ចាស់នោះ អ៊ីនស្ហាអល់ឡោះ ទ្រង់នឹងផ្តល់ផលបុណ្យយ៉ាងល្អប្រសើរជាមិនខាន។

លើសពីនេះ ព្យាការីបានលើកឡើងបន្ថែមនូវឋានៈរបស់ស្ត្រី ដោយលើកតម្កើងឋានៈនៃភាពជាម្តាយ និងផ្តល់ឱ្យពួកនាងនូវកម្រិតនៃការទទួលស្គាល់យ៉ាងខ្ពស់បំផុត។ នោះគឺម្តាយត្រូវបានគេផ្តល់តម្លៃ ក្នុងការគោរពដោយកូនរបស់ពួកគេលើសឳពុកបីដង។

មានបុរសម្នាក់បានដើរទៅកាន់រ៉ស៊ូលុលឡោះ ហើយបានសួរលោកថា៖ ឱរ៉ស៊ូលុលឡោះ! តើអ្នកណាដែលមានសិទ្ធិទទួលបានការធ្វើល្អបំផុតពីខ្ញុំ? ព្យាការីបានមានប្រសាសន៍ថា៖

**គឺម្តាយរបស់អ្នក។ គេក៏សួរទៀតថា៖ ចុះបន្ទាប់មក អ្នកណា? ព្យាការីបានមានប្រសាសន៍ថា៖ ម្តាយរបស់អ្នក។ បុរសនោះក៏សួរទៀតថា៖ បន្ទាប់មក អ្នកណាទៀត? ព្យាការីបានមានប្រសាសន៍ថា៖ ម្តាយរបស់អ្នក។ បុរសនោះបានសួរជាលើកទីបួន៖ បន្ទាប់មក អ្នកណា? ព្យាការីក៏មានប្រសាសន៍ថា៖ ឳពុករបស់អ្នក។**

*ហាទីស ពូខរី ៥៩៧១*

លោកក៏បានសន្យានូវការផ្តល់ផលបុណ្យយ៉ាងច្រើនអនេកដល់មាតាបិតាដែលមានចិត្តអត់ធ្មត់ និងមានទំនួលខុសត្រូវចំពោះកូនស្រី នៅក្នុងការ មើលថែ អប់រំ ណែនាំ ចិញ្ចឹមបីបាច់ ផ្តល់ម្ហូបអាហារ សម្លៀកបំពាក់ និងការប្រាស្រ័យទាក់ទង

ដោយល្អចំពោះពួកនាង។ នោះពួកនាង(កូនស្រី ) នឹងក្លាយជាខែលសម្រាប់ការពារគាត់ពីភ្លើងនរកនៅថ្ងៃបរលោក។

ចំណែកអ្នកដែលមើលថែ និងប្រាស្រ័យទាក់ទងល្អជាមួយបងប្អូនស្រីរបស់គេនោះ ព្យាការីក៏បានសន្យាផ្តល់ផលបុណ្យដូចគ្នា។ ដូចនៅក្នុងហាទីសមួយផ្សេងទៀត ព្យាការីបានមានប្រសាសន៍ថា៖

**អ្នកណាហើយដែលមានកូនស្រីបីនាក់ ឬបងប្អូនស្រីបីនាក់ ឬកូនស្រីពីរនាក់ ឬបងប្អូនស្រីពីរនាក់ ហើយគេបានប្រាស្រ័យទាក់ទងយ៉ាងល្អជាមួយពួកនាងដោយការកោតខ្លាចអល់ឡោះជាម្ចាស់ នោះគេនឹងទទួលបានឋានសួគ៌។**

*ហាទីស តៀរមីហ្ស៊ី ១៩១៦*

ព្យាការីក៏បានស្តាប់ ហើយនិងទទួលយកទស្សនៈរបស់ស្ត្រីនៅពេលដែលប្រពៃណីនៃសង្គមអារ៉ាប់មានការមិនពេញចិត្តជាខ្លាំងចំពោះការចូលរួមរបស់ស្ត្រីនៅក្នុងការសម្រេចកិច្ចការ។ លើសពីនេះទៅទៀត ប្រសិនបើបុរសដែលចូលរួមក្នុងការសម្រេចកិច្ចការដែលមានស្ត្រីជាមេ ឬជាអ្នកដឹកនាំនៅក្នុងកុលសម្ព័ន្ធរបស់គេនោះ វាត្រូវបានចាត់ទុកថាជារឿងដែលគួរឱ្យអាម៉ាស់ និងចម្លែកបំផុត។

រ៉ស៊ូលុលឡោះ បានក្លាយជាគំរូល្អដល់អ្នកដទៃ នៅក្នុងការទទួលស្គាល់ប្រាជ្ញារបស់ស្ត្រី ដោយការទទួលយកនូវទស្សនៈរបស់ពួកនាង។ មិនត្រឹមតែបញ្ហាដែលទាក់ទងនឹងស្ត្រីតែប៉ុណ្ណោះទេ តាមពិតទៅមានបញ្ហាដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រជាជនមូស្លីមទាំងមូល ក៏ដូចជាក្នុងកិច្ចការធំៗនៃសាសនាផងដែរ។ ឧទាហរណ៍ក្នុងអំឡុងពេលព្រឹត្តិការណ៍ហ៊ូដៃពីយ៉ះ ដែលជាពេលដែលប្រជាជនមូស្លីមមានអារម្មណ៍ខឹងសម្បារ និងបាក់ទឹកចិត្ត ដោយសារតែការដាក់កំហិតពីពួកមូស្ហ្ករីគីននៅក្រុងម៉ាក្កះ ដោយការរារាំងពួកគេពីការធ្វើអ៊ុំរ៉ោះ។ ប្រជាជនមូស្លីមត្រូវបំណាយពេលរង់ចាំ និងងឿងឆ្ងល់ចំពោះការអនុម័តរបស់ព្យាការីដោយឱ្យធ្វើ

ការតាហាលលុល(កោរសក់)។ ពេលលោកបានឃើញប្រតិកម្មរបស់ប្រជាជនមូស្លីម បែបនេះ លោកក៏មានចិត្តព្រួយបារម្ភ ដូច្នេះហើយលោកក៏បានពិភាក្សាជាមួយ ភរិយារបស់លោក ដែលមានឈ្មោះថា អ៊ុំមូសាល់ម៉ះ ដោយលោកស្រីបានណែនាំ លោកឱ្យធ្វើការតាហាលលុលខ្លួនឯងមុនគេ នៅចំពោះមុខសហាការីរបស់លោក។ វិធីសាស្ត្រនេះ ពិតជាមានប្រសិទ្ធភាព និងទទួលបានជោគជ័យក្នុងការធ្វើឱ្យ សហាការីរបស់លោកបានស្ងប់ចិត្តវិញ ដោយពួកគេក៏បានធ្វើការតាហាលលុល តាមលោកភ្លាមៗ។

ដូច្នេះសហាការីជាច្រើន បានរៀនសូត្រពីព្យាការីក្នុងទទួលស្គាល់ទស្សនៈ របស់ស្ត្រី។ ហើយខលីហ្វះ(មេដឹកនាំ)ទាំងបួន (អាពូប៉ាកើរ អូមើរ អូស្មាន និង អាលី) ក៏បានគិតគូរពីទស្សនៈរបស់ស្ត្រីមួយចំនួន នៅក្នុងកិច្ចប្រជុំ និងពិភាក្សារបស់ពួក គេ។ ជាឧទាហរណ៍ៈ សហាការីតែងតែទៅរកអ្នកស្រីអាអ៊ីស្ហះ ដើម្បីសុំដំបូន្មាន ឬយោបល់របស់អ្នកស្រីទាក់ទងនឹងកិច្ចការសាសនា។ អាត់ ពិន អាពីរ៉ាប៉ាស ដែលជា តាពីអ៊ីន(អ្នកជំនាន់បន្ទាប់ពីសហាការី)ម្នាក់ធ្លាប់និយាយថា៖ អ្នកស្រីអាអ៊ីស្ហះ ជាស្ត្រី ម្នាក់ដែលមានចំណេះដឹងផ្នែកនីតិសាស្ត្រអ៊ីស្លាម(ហ្វីកោះ)ជាងគេបំផុត ហើយ បានរៀនសូត្រច្រើនជាងគេបំផុត និងមានមតិល្អបំផុត សម្រាប់បញ្ហាមនុស្សទូទៅ។

ព្យាការីក៏បានជំរុញឱ្យស្វាមីបបួលភរិយារបស់ពួកគេឱ្យចូលរួមនៅក្នុង សកម្មភាពនៃការគោរពសក្ការៈទៅចំពោះអល់ឡោះ។ នៅក្នុងហាទីសមួយ ដែលត្រូវ បានរាយការណ៍ដោយអាពូហ៊ូរ៉ៃយ៉ារ៉ះថា ព្យាការីបានមានប្រសាសន៍ថា៖

**សូមអល់ឡោះប្រទាននូវសេចក្តីមេត្តាករុណាដល់ស្វាមីដែលក្រោកពីដំណេក នៅពេលយប់ដើម្បីគោរពថ្វាយបង្គំ រួចហើយដាស់ភរិយារបស់គេឱ្យក្រោក គោរពថ្វាយបង្គំផងដែរ។ ប្រសិនបើនាងមិនក្រោក ចូរប្រោះទឹកលើមុខនាង។ ហើយសូមអល់ឡោះប្រទាននូវសេចក្តីមេត្តាករុណាចំពោះភរិយាដែលក្រោក**

**ពីដំណេកនៅពេលយប់ដើម្បីគោរពថ្វាយបង្គំ បន្ទាប់មក ដាស់ស្វាមីរបស់នាង ប្រសិនបើស្វាមីនាងមិនព្រមក្រោកទេនោះ ចូរនាងប្រោះទឹកនៅលើមុខរបស់គាត់។**

*ហាទីស អាពូដាវូឌ ១៤៥០*

នៅក្នុងហាទីសមួយផ្សេងទៀត ដែលត្រូវបានរៀបរាប់ដោយ អាពូ សាអ៊ីត អាល់ខុទរីថា ព្យាការីបានមានប្រសាសន៍ថា៖

**នៅពេលដែលបុរសភ្ញាក់ពីដំណេកពេលយប់ ហើយដាស់ភរិយារបស់គេ បន្ទាប់មកពួកគេថ្វាយបង្គំពីររ៉ក់អាត់ នោះនឹងត្រូវបានគេកត់ត្រាចូលក្នុងចំណោមបុរស និងស្ត្រី ដែលតែងតែរំលឹក និងចង់ចាំអល់ឡោះជាម្ចាស់។**

*ហាទីស អ៊ីបនូ ម៉ាជះ ១៣៣៥*

រ៉ស៊ូលុលឡោះ ក៏បានហាមឃាត់សហការីរបស់លោកមិនឱ្យរារាំងភរិយារបស់ពួកគេពីការទៅវិហារ(ម៉ាស្ជិទ) ដើម្បីស្វែងរកចំណេះដឹង ឬធ្វើអ៊ីប៉ាហ្ទាត់ (សកម្មភាពនៃការគោរពសក្ការៈ)នោះឡើយ ដរាបណាពួកគេប្រកាន់ខ្ជាប់នូវក្បួនច្បាប់ដែលសាសនាអ៊ិស្លាមបានដាក់ចេញ។ ព្យាការីបានមានប្រសាសន៍ថា៖

**ចូរកុំហាមស្ត្រី ពីការទៅវិហាររបស់អល់ឡោះ (ម៉ាស្ជិទ)។**

*ហាទីស ពូខរី ៩០០ និង មូស្លីម ៤៤២*

មនុស្សជាច្រើន បានភ្លេចអ្នកដែលបានជួយពួកគេជាញឹកញាប់ក្នុងពេលមានការខ្វះខាត តែចំពោះព្យាការីវិញ គឺលោកមិនដែលភ្លេចនោះទេ។ លោកបានបង្ហាញនូវអត្ថន័យនៃសេចក្តីស្រលាញ់ពិត និងភាពស្មោះត្រង់។

ជាក់ស្តែង អ្នកស្រី ខទីជះ គឺជាភរិយាដែលលោកស្រលាញ់ពេញបេះដូង ដោយលោកបានរៀបការជាមួយអ្នកស្រីតាំងពីលោកនៅវ័យក្មេង ហើយទទួលបានបុត្រជាទីស្រលាញ់ជាច្រើននាក់ជាមួយគ្នា និងបានឆ្លងកាត់ឧបសគ្គនៅក្នុងជីវិតជាច្រើនរួមគ្នាផងដែរ។

ព្យាការីមិនអាចបំភ្លេចនូវការលះបង់ និងការបម្រើរបស់អ្នកស្រីមកចំពោះលោកបានឡើយ។ ដូច្នេះហើយ នៅអំឡុងពេលនោះ (មុនពេលលោកត្រូវបានតែងតាំងជាព្យាការី) លោកមិនយកភរិយាផ្សេងទៀតនោះឡើយ បើទោះបីជាពហុពន្ធភាព(ការយកប្រពន្ធលើសពីម្នាក់)ត្រូវបានអនុវត្តយ៉ាងទូលំទូលាយនៅក្នុងសហគមន៍អារ៉ាប់ក៏ដោយ។ ព្រោះតែគ្មានអ្នកណាអាចជំនួសអ្នកស្រីបាននោះឡើយនៅក្នុងបេះដូងរបស់លោក។ ពិតណាស់ អ្នកស្រីបានជឿជាក់លើលោកនៅពេលដែលមនុស្សភាគច្រើនមិនបានជឿលើលោក ហើយអ្នកស្រីបានទទួលលោកនៅពេលដែលមនុស្សភាគច្រើនបានបដិសេធលើរូបលោក។

បន្ទាប់ពីការស្លាប់របស់ អ្នកស្រី ខទីជះ បានកន្លងផុតទៅជាយូរឆ្នាំ មានស្ត្រីចំណាស់ម្នាក់បានមកផ្ទះរបស់ព្យាការី ហើយគោះទ្វាររបស់លោក បន្ទាប់មកលោកបានស្វាគមន៍នាងដោយភាពរីករាយយ៉ាងក្រៃលែង។ ដែលវាបានធ្វើឱ្យអ្នកស្រីអាអ៊ីស្ហះ ហាក់ឆ្ងល់ ព្រោះអ្នកស្រីមិនធ្លាប់ស្គាល់ និងមិនធ្លាប់ឃើញស្ត្រីចំណាស់នោះពីមុនមកនោះទេ ហើយអ្នកស្រីបានសួរព្យាការីថា៖ ហេតុអ្វីបានជាអ្នកសប្បាយចិត្តម្លេះ ពេលជួបគាត់? ជាការឆ្លើយតប លោកបានមានប្រសាសន៍ថា ៖

**ឱ អាអ៊ីស្ហះ! គាត់ធ្លាប់មកលេងយើងក្នុងសម័យ ដែលអ្នកស្រីខទីជះនៅមានជីវិត។**

*ហាទីស ប៉ៃហាគី ៨៧០១*

អ្នកស្រីអាអ៊ីស្ហះក៏បានរៀបរាប់នៅក្នុងហាទីសមួយផ្សេងទៀតថា៖

**មានពេលមួយ អ្នកស្រី ហាឡាស ពិនតី ខូវ៉ៃលីត ដែលជាប្អូនស្រីរបស់អ្នកស្រី ខទីជះ បានសុំការអនុញ្ញាតពីព្យាការី ដើម្បីចូលផ្ទះរបស់លោក។ ដោយហេតុនោះ វាធ្វើឱ្យព្យាការីនឹកឃើញឡើងវិញ នូវរបៀប និងសម្លេង ដែលអ្នកស្រី ខទីជះ ធ្លាប់ធ្វើកាលពីមុន ដែលវាបានធ្វើឱ្យលោកមានអារម្មណ៍សប្បាយចិត្តជាខ្លាំង។**

*ហាទីស ពូខរី ៣៨២១*

អ្នកស្រីអាអ៊ីស្ហះបាននិយាយទៀតថា៖

**ខ្ញុំមិនដែលប្រច័ណ្ឌនឹងភរិយាណាម្នាក់របស់ព្យាការី ជាងប្រច័ណ្ឌអ្នកស្រី ខទីជះនោះទេ ទោះបីខ្ញុំមិនដែលបានជួបអ្នកស្រី ក៏ប៉ុន្តែរ៉ស៊ូលុលឡោះ តែងតែរំលឹក និងរៀបរាប់ពីអ្នកស្រីយ៉ាងច្រើន មិនត្រឹមតែប៉ុណ្ណោះ នៅពេលណាដែលលោកសំឡេះចៀម លោកនឹងរកមើលមិត្តភក្តិ និងក្រុមគ្រួសាររបស់អ្នកស្រីខទីជះ ដើម្បីចែកសាច់ខ្លះដល់ពួកគេ។**

*ហាទីស តៀរម៉ីហ្ស៊ី ២០១៧*

នេះហើយជាការប្រាស្រ័យទាក់ទងរបស់ព្យាការីមូហាំម៉ាត់ជាមួយស្ត្រី លោកបានគោរព និងឱ្យតម្លៃចំពោះស្ត្រីជាខ្លាំង។ ហើយអ្នកដែលស្គាល់ព្យាការីច្បាស់ គេនឹងបានឃើញពីចរិកលក្ខណៈដ៏ល្អប្រពៃរបស់លោក ដែលស្ត្រីមានជំនឿគ្រប់រូបតែងប្រាថ្នាចង់បាន។

# ព្យាការីមូហាំម៉ាត់

# ជាមួយកុមារ

ការប្រាស្រ័យទាក់ទងជាមួយកុមារមិនមែនជារឿងងាយស្រួលនោះទេ ដោយសារក្នុងដំណាក់កាលនេះ គំនិតរបស់ពួកគេនៅក្មេងខ្ចី ចង់បានអ្វីតាមចិត្តចង់ និងងាយធ្វើឱ្យយើងខឹងគ្រប់ពេល។ ទោះជាយ៉ាងណាក៏ដោយ កុមារចូលចិត្តអ្នកដែលស្រលាញ់ពួកគេ យកចិត្តទុកដាក់ចំពោះពួកគេ ហើយធ្វើដូចជាយើងហើយនិងគេគឺមានអាយុស្មើគ្នា។ ជាធម្មតា ក្នុងដំណាក់កាលនេះ ពួកគេនឹងស្រូបយកព័ត៌មាន និងចំណេះដឹងគ្រប់ប្រភេទ ដោយមិនទាន់អាចថ្លឹងថ្លែងអ្វីបាននោះឡើយ។ អ្វីគ្រប់យ៉ាងដែលពួកគេបានចាប់យក នឹងក្លាយជាផ្នែកមួយនៃចរិតលក្ខណៈរបស់ពួកគេ ដែលនឹងកំណត់អត្តសញ្ញាណរបស់ពួកគេ នាពេលអនាគត។

រ៉ស៊ូលុលឡោះ យល់ពីការពិតនៃរឿងនេះច្បាស់ណាស់។ លោកបានប្រាស្រ័យទាក់ទងជាមួយកុមារតាមវិធីសាស្ត្រ ដែលស្របតាមតម្រូវការ និងបំណងប្រាថ្នារបស់ពួកគេ។ លោកពោរពេញដោយភាពជាឪពុក មានការលេងសើចលួងលោម និងអប់រំ ដែលវាមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការរៀបចំបុគ្គលិកលក្ខណៈរបស់កុមារ។ ប្រៀបដូចជាលោកកំពុងចុះទៅកម្រិតកុមារ ខណៈពេលដែលលោកធ្វើការទំនាក់ទំនងជាមួយពួកគេ។ ទាំងនេះហើយគឺជាសញ្ញានៃអ្នកដឹកនាំដែលពោរពេញដោយភាពឈ្លាសវៃ។ ប្រហែលជាយើងធ្លាប់បានឮរួចមកហើយនូវទង្វើដែលលោកបានធ្វើចំពោះចៅជាទីស្រលាញ់របស់លោក៖ ហាសាន់ និង ហ៊ូសេនដែលពួកគេបានឡើងជិះលើខ្នងរបស់លោក នៅពេលដែលលោកកំពុងដឹកនាំការថ្វាយបង្គំនៅក្នុងវិហារ។

វាជារឿងធម្មតា ដែលកុមារមិនទាន់ពេញវ័យ មិនទាន់អាចបែងចែកបានរវាងល្អ និងអាក្រក់ ឬក៏យល់ពីបទបញ្ជានៅក្នុងសាសនា និងសង្គមនោះឡើយ។ ដូច្នេះហើយ ព្យាការីបានអនុវត្តនូវបទដ្ឋានធម្មជាតិនេះ ពោរពេញដោយការអនុគ្រោះ និងសេចក្តីស្រលាញ់។

នៅក្នុងហាទីសមួយ សហការិនី អ៊ុំមូ ខលីត បានរៀបរាប់ពីការចងចាំរបស់នាងពីកាលកុមារភាពជាមួយនឹងព្យាការីថា៖

**ខ្ញុំ និង ឪពុករបស់ខ្ញុំ បានទៅជួបនឹងរ៉ស៊ូលុលឡោះ ដោយថ្ងៃនោះ ខ្ញុំបានពាក់អាវពណ៌លឿង។ ពេលនោះ រ៉ស៊ូលុលឡោះបានមានប្រសាសន៍មកកាន់ខ្ញុំថា៖ នាងពិតជាស្អាតមែន! ស្អាតណាស់! ហើយខ្ញុំក៏បានរត់ទៅកាន់ រ៉ស៊ូលុលឡោះ ហើយកាន់ប្រជ្រុយ( ជាត្រាដែលបញ្ជាក់ពីភាពជាព្យាការី )របស់លោកលេង។ ពេលឃើញដូច្នោះ ឪពុករបស់ខ្ញុំក៏បានហាមខ្ញុំ។ តែរ៉ស៊ូលុលឡោះបានតបថា៖ មិនអីនោះទេ លែងនាងឱ្យលេងចុះ សូមឱ្យនាងមានអាយុវែង សូមឱ្យស្លៀកសំលៀកបំពាក់នេះបានយូរ!**

*ហាទីស ពូខរី ៣០៧១*

ព្យាការីមានប្រជាប្រិយភាពខ្លាំងណាស់ ជាពិសេសនៅពេលលោកទទួលភ្ញៀវ ហើយមានកុមារតូចៗមកជាមួយ លោកទទួលពួកគេដោយភាពរីករាយ ហើយព្យាយាមផ្គាប់ចិត្ត ក៏ដូចជាយល់អារម្មណ៍ និងតម្រូវការពួកគេច្បាស់។

អ៊ុំមូកែស ពិនតី មីហាស៊ុន បានរៀបរាប់អំពីបទពិសោធន៍របស់នាង នៅពេលដែលនាងបានទៅលេងរ៉ស៊ូលុលឡោះ ចៃដន្យកូនរបស់នាងបាននោមដាក់អាវរបស់ព្យាការី នៅពេលដែលលោកកំពុងតែពរូបគេ។ ព្យាការីមិនបានបញ្ចេញប្រតិកម្មអវិជ្ជមានបន្តិចសោះឡើយ។ នេះបានបង្ហាញថា លោកពិតជាស្រលាញ់កូនក្មេងខ្លាំងណាស់។ លើសពីនេះលោកបានចំណាយពេលសម្រាប់ក្មេងៗ មិនថានៅពេលណា ឬកន្លែងណានោះទេ ទោះបីនៅពេលលោកកំពុងធ្វើដំណើរ ឬកំពុងថ្វាយបង្គំក៏ដោយ។

អ៊ូសាម៉ះ ពិន សេ៊ត បានរៀបរាប់ថា៖ រ៉ស៊ូលុលឡោះដាក់ខ្ញុំនៅលើភ្លៅម្ខាង ហើយដាក់ ហាសាន់ ពិន អាលី លើភ្លៅម្ខាងទៀតរបស់លោក បន្ទាប់មកលោកបានឱបយើងទាំងពីរ ហើយមានប្រសាសន៍ថា៖

បពិត្រអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាអាណិតស្រលាញ់ពួកគេ
ដូចដែលខ្ញុំបានអាណិតស្រលាញ់ចំពោះពួកគេផង។

*ហាទីស ពូខរី ៦០០៣*

មានពេលមួយនោះ អូម៉ាម៉ះ កូនស្រីរបស់ ស៊ៃណាប់ ដែលត្រូវជាចៅស្រីរបស់លោកបានមករកលោកនៅពេលលោកកំពុងតែថ្វាយបង្គំ លោកក៏បានពនាងក្នុងពេលដែលលោកកំពុងឈរថ្វាយបង្គំ ហើយក៏ដាក់នាងចុះនៅក្បែរខ្លួនលោកនៅពេលលោកឱនរូកុ និងពេលក្រាបស៊ូជូត។

មានពេលខ្លះ លោកកំពុងតែដឹកនាំការថ្វាយបង្គំជាក្រុម ហើយស្រាប់តែបានឮសម្លេងទារកកំពុងតែស្រែកយំនៅក្នុងវិហារ លោកក៏បានសូត្រខ្លីៗវិញ។ ក្រោយថ្វាយបង្គំចប់ លោកក៏បានមានប្រសាសន៍ថា៖

ខ្ញុំមានបំណងធ្វើការថ្វាយបង្គំឱ្យបានវែងបន្តិច ប៉ុន្តែខ្ញុំបានឮសម្រែកយំរបស់
ទារក ដូច្នេះខ្ញុំក៏បានធ្វើការថ្វាយបង្គំខ្លីវិញ ព្រោះខ្ញុំដឹងថាមានម្តាយកំពុងតែ
ព្រួយបារម្ភអំពីទារករបស់នាង។

*ហាទីស ពូខរី ៧០*

បាពៀរ ពិន សាមូរ៉ោះ បានរៀបរាប់ថា៖

ខ្ញុំបានថ្វាយបង្គំហ្សូហ៊្ររជាមួយរ៉ស៊ូលុលឡោះ បន្ទាប់មកលោកក៏បានវិលត្រឡប់ទៅ
រកគ្រួសាររបស់លោក ហើយខ្ញុំក៏បានដើរទៅជាមួយលោកផងដែរ។ ពេលដែល
លោកបានជួបក្មេងៗមួយចំនួននៅតាមផ្លូវ លោកក៏បានចាប់កាន់ថ្ពាល់របស់ពួកគេ
ហើយលោកក៏កាន់ថ្ពាល់ខ្ញុំផងដែរ ហើយខ្ញុំមានអារម្មណ៍ថាត្រជាក់ហើយដៃរបស់
លោក មានក្លិនក្រអូប ប្រៀបដូចជាខ្លិនទឹកអប់អ៊ុំបឹង។

*ហាទីស មូស្លីម ២៣២៩*

លោកបានលេងសើចជាមួយប្អូនប្រុសរបស់ អាណាស ពិន ម៉ាលីគ ដែលកំពុងតែកើតទុក្ខ ដោយសារតែសត្វស្លាបជាទីស្រលាញ់របស់គេបានស្លាប់។ ពេលព្យាការីបានឃើញបែបនោះ លោកក៏បាននិយាយលួងលោមគេថា៖

**ឱ អាប៉ា អូមើរ តើចាបកំពុងធ្វើអ្វីហ្នឹង?**

*ហាទីស ពូខរី ៦១២៩*

ព្យាការីបានផ្តល់តម្លៃដល់កុមារ និងថែរក្សាអារម្មណ៍របស់ពួកគេជាខ្លាំង ដោយបានហាមមនុស្សធំមិនឱ្យកុហកពួកគេនោះឡើយ សូម្បីតែក្នុងគោលបំណងដើម្បីសម្រាលទុក្ខពួកគេក៏ដោយ។ អាប់ទុលឡោះ ពិន អាមៀរ និងម្តាយរបស់គាត់បានរៀបរាប់ពីបទពិសោធន៍របស់គាត់ថា៖ ថ្ងៃមួយម្តាយរបស់ខ្ញុំ បានហៅខ្ញុំនៅពេលដែលរ៉ស៊ូលុលឡោះកំពុងអង្គុយជាភ្ញៀវនៅក្នុងផ្ទះរបស់យើង។ ម្តាយរបស់ខ្ញុំបាននិយាយមកកាន់ខ្ញុំថា៖ មកនេះ! ម្តាយចង់ឱ្យអ្វីមួយដល់កូន។ ខ្ញុំមានអារម្មណ៍ថាម្តាយរបស់ខ្ញុំដូចមិនប្រាកដចិត្តថានឹងឱ្យនោះទេ។ ពេលនោះព្យាការីបានសួរម្តាយរបស់ខ្ញុំថា៖ តើនាងពិតជាចង់ឱ្យអ្វីមួយដល់គេ ពិតមែនដែរឬទេ? ម្តាយខ្ញុំឆ្លើយថា៖ ខ្ញុំចង់ឱ្យផ្លែល្មើខ្លះដល់គេ។ បន្ទាប់មកព្យាការីបានមានប្រសាសន៍ថា៖

**ប្រសិនបើអ្នកមិនបានឱ្យអ្វីមួយដល់គេ តាមអ្វីដែលអ្នកបានសន្យាទេនោះ នោះអ្នកនឹងត្រូវបានគេកត់ត្រាថាជាអ្នកដែលភូតកុហកជាមិនខានឡើយ។**

*ហាទីស អាពូដាវូឌ ៤៩៩១*

នៅពេលដែលព្យាការីបានឃើញកុមារធ្វើខុស ហើយត្រូវការសេចក្តីណែនាំនោះលោកនឹងមិនចាប់កំហុសពួកគេ ឬស្តីបន្ទោសពួកគេឡើយ។ ផ្ទុយទៅវិញលោកនឹងណែនាំពួកគេដោយពាក្យសម្តីទន់ភ្លន់។ ដូចដែលលោក អូមើរ ពិន អាពី

សាឡាម៉ះ ដែលត្រូវជាកូនប្រសារបស់លោកបានប្រាប់ថា៖ មានពេលមួយនោះ នៅពេលដែលគាត់នៅក្មេង គាត់បានញ៉ាំយ៉ាងរញ៉េរញ៉ៃ ដោយចាប់យកអាហារពីគ្រប់ចាន។ ហើយក៏មិនបានសូត្រ ពិសមិលឡា (ដោយព្រះនាមនៃអល់ឡោះ) មុនពេលបរិភោគដែរ។ បន្ទាប់មកព្យាការីបានទូន្មានគាត់ ប្រកបដោយសេចក្ដីស្រលាញ់ និងសំដីទន់ភ្លន់ ដោយលោកបានមានប្រសាសន៍ថា៖

**ឱកូនប្រុស! ចូរពោល ពិសមិលឡា សិន! (ដោយព្រះនាមនៃអល់ឡោះ) ហើយត្រូវបរិភោគដោយដៃស្ដាំរបស់កូន និងបរិភោគអាហារដែលនៅជិតកូនបំផុត។**

*ហាទីស ពូខរី ៥៣៧៦ និង មូស្លីម ២០២២*

ជួនកាល ព្យាការីក៏ជាមិត្តដែលជួយសម្រាលទុក្ខដល់កុមារ នៅពេលពួកគេមានអារម្មណ៍កើតទុក្ខ បាក់ទឹកចិត្ត ឬពេលពួកគេចង់បានអ្វីមួយ តែមិនបានដូចបំណង នោះលោកនឹងបង្រៀនពួកគេអំពីអត្ថន័យ និងតម្លៃនៃការអត់ធ្មត់ជាមួយនឹងការសាកល្បងរបស់អល់ឡោះ។

លោកក៏ធ្លាប់បានមានប្រសាសន៍ទៅកាន់កុមារតូចម្នាក់ដែលឪពុករបស់គេទើបតែទទួលមរណភាពថា៖ សូមអល់ឡោះជាម្ចាស់! ប្រទាននូវផលបុណ្យដល់អ្នកចំពោះភាពអត់ធ្មត់នៃការបាត់បង់ឪពុករបស់អ្នក។

ពេលខ្លះ ព្យាការីក៏បានធ្វើការប្រាស្រ័យទាក់ទងជាមួយពួកគេប្រៀបដូចជាពួកគេជាមនុស្សពេញវ័យអ៊ីចឹងដែរ។ ដែលបានធ្វើឱ្យពួកគេមានអារម្មណ៍ថាមានតម្លៃ និងទទួលបានការកោតសសើរ ដែលនាំឱ្យពួកគេមានទំនុកចិត្តលើខ្លួនឯង និងបង្កើនភាពវិជ្ជមានចំពោះបុគ្គលិកលក្ខណៈរបស់ពួកគេផងដែរ។ ជាឧទាហរណ៍ លោកបានអញ្ជើញសហការីវ័យក្មេងមួយចំនួនដូចជា អ៊ុបនូ អាប់ប៉ាស និង អ៊ុបនូ អូមើរ ឱ្យចូលរួមក្នុងការប្រជុំជាមួយសហការីជើងចាស់ដទៃទៀត ដើម្បីឱ្យពួកគេអាចទទួលបានចំណេះដឹង និងបទពិសោធន៍។ អ៊ុបនូ អូមើរ បាននិយាយថា៖ មាន

ពេលមួយ ពួកយើងបាននៅជាមួយព្យាការី ហើយយើងក៏បានឃើញគេយកដើមល្មើមកឱ្យលោក។ បន្ទាប់មកព្យាការីបានមានប្រសាសន៍ថា៖

**ក្នុងបំណោមដើមឈើទាំងឡាយ មានដើមឈើម្យ៉ាង ដែលមានលក្ខណៈដូចទៅនឹងអ្នកមូស្លីម។ ពេលនោះ ខ្ញុំចង់និយាយថាដើមនោះគឺជាដើមល្មើដែរ ប៉ុន្តែក្នុងបំណោមមនុស្សទាំងអស់នៅទីនោះ ខ្ញុំក្មេងជាងគេ ហើយខ្ញុំក៏នៅស្ងៀម បន្ទាប់មក ព្យាការីបានមានប្រសាសន៍ថា៖ វាគឺជាដើមល្មើ។**

*ហាទីស ពូខរី ៧២ និង មូស្លីម ២៨១១*

ពេលខ្លះ ព្យាការីបានឱ្យសហការីដែលមានអាយុក្មេង អង្គុយនៅខាងស្តាំលោក នៅពេលដែលលោកកំពុងពិភាក្សាជាមួយសហការីផ្សេងទៀត នូវកិច្ចការដែលត្រូវទទួលបន្ទុកដោយសហការីជាន់ខ្ពស់ដូចជា អាពូ ប៉ាកើរ ជាដើម។ សាហាល ពិន សាអាត់ អាល់សាក់ទី បានរៀបរាប់ថា៖ មានពេលមួយ គេបានលើកភេសជ្ជៈជូនរ៉ស៊ូលុលឡោះ ហើយលោកក៏បានពិសាវា។ ដោយនៅខាងស្តាំដៃរបស់លោកគឺជាក្មេង ហើយខាងឆ្វេងដៃគឺជាមនុស្សចាស់មួយក្រុម។ លោកបានមានប្រសាសន៍ទៅកាន់ក្មេងថា៖

**តើអ្នកអាចអនុញ្ញាតឱ្យខ្ញុំជូនភេសជ្ជៈនេះដល់មនុស្សចាស់មុនសិនបានទេ? ក្មេងប្រុសនោះបាននិយាយថា៖ ដោយអល់ឡោះជាម្ចាស់! ឱ រ៉ស៊ូលុលឡោះ! ខ្ញុំមិនលះបង់ចំណែករបស់ខ្ញុំទៅអ្នកដទៃឡើយ (គេមានសិទ្ធិជាង ព្រោះតែគេស្ថិតនៅខាងស្តាំដៃរ៉ស៊ូលុលឡោះ)។ ដូច្នេះ រ៉ស៊ូលុលឡោះ ក៏បានផ្តល់ពែងទឹកដល់ក្មេងប្រុសនោះមុន។**

*ហាទីស ពូខរី ៥៦២០ និង មូស្លីម ២០៣០*

តាមហាទីសមួយនេះ យើងអាចមើលឃើញថា ព្យាការីគោរពភាគីទាំងពីរស្មើគ្នា។ លោកគោរពសិទ្ធិរបស់អ្នកដែលអង្គុយនៅខាងស្តាំរបស់លោក ដែលនៅពេលនោះ ត្រូវបានអង្គុយដោយសហការីវ័យក្មេង ដោយលោកបានសុំការអនុញ្ញាតពីគេជាមុន។ ហើយលោកក៏បានគោរពសិទ្ធិរបស់សហការីចាស់ៗ ដោយសុំការអនុញ្ញាតពីសហការីវ័យក្មេង ក្នុងការប្រគល់សិទ្ធិរបស់គេទៅ សហការីចាស់ៗ។

ទោះជាយ៉ាងណាក៏ដោយ ពេលដែលសហការីវ័យក្មេងមិនអនុញ្ញាតដោយសារតែគេមានចិត្តចង់ពិសាកែវទឹកបន្ទាប់ពីរ៉ស៊ូលុលឡោះ ដែលជាទីស្រលាញ់របស់គេនោះ ព្យាការីក៏មិនបានដាស់តឿន ឬស្តីបន្ទោសចំពោះគេថា៖ អាត្មានិយមនោះឡើយ ហើយលោកក៏បានផ្តល់ឱ្យសហការីវ័យក្មេងនោះនូវសិទ្ធិរបស់គេ។

មានរឿងរ៉ាវជាច្រើន ទាក់ទងនឹងកុមារដែលត្រូវបានអប់រំដោយនីតិសាស្ត្រអ៊ីស្លាម តាំងពីថ្ងៃចាប់កំណើតរបស់ពួកគេ ដូចជា ការដាក់ឈ្មោះទារកទើបនឹងកើត (អាគីកោះ) កិច្ចអប់រំ សិទ្ធិ និងតួនាទីនៃអាណាព្យាបាលក្នុងការថែទាំកុមារ ភាពជាម្ចាស់ការ ភាពជាអ្នកដឹកនាំ ការទទួលមរតក និងផ្សេងៗទៀត។ រឿងទាំងអស់នេះបានបង្ហាញយ៉ាងច្បាស់ ពីការខ្វល់ខ្វាយរបស់បុរសម្នាក់ដែលឈ្មោះថា មូហាំម៉ាត់ ចំពោះកុមារ និងមនុស្សជាតិគ្រប់គ្នា។

# ព្យាការីមូហាំម៉ាត់
# ជាមួយអ្នកជិតខាង

វ៉ស៊ូលុលឡោះ ត្រូវបានតែងតាំងឡើងនៅក្នុងប្រទេសមួយ ដែលមិនធ្លាប់មានការយកចិត្តទុកដាក់ចំពោះអ្នកជិតខាងរបស់ពួកគេនោះឡើយ ទោះបីជាអ្នកជិតខាងនោះ ជាប់សាច់ឈាមនឹងពួកគេបំផុតក៏ដោយ។ ជាក់ស្តែង ចាក់ហ្វើរ ពិន អាពី តឡិប ធ្លាប់និយាយទៅកាន់ស្តេច អាន់ណាចាស៊ី នៃចក្រភព អេត្យូពីថា៖

**ឱ ព្រះរាជាអើយ! កាលនោះ ពួកយើងគឺជាមនុស្សល្ងង់ខ្លៅបំផុត យើងបានគោរពបូជារូបបដិមា ហូបសាកសព ប្រព្រឹត្តអំពើអសីលធម៌ ផ្តាច់ចំណងសាច់សារលោហិត និងធ្វើបាបអ្នកជិតខាង ហើយអ្នកខ្លាំងក្នុងចំណោមពួកយើងនឹងលេបត្របាក់ និងកៀបសង្កត់អ្នកទន់ខ្សោយ។**

*ហាទីស អះម៉ាត់ ១៧៤០*

វាជាសម័យកាលដែលមនុស្សម្នាក់ៗ មានអារម្មណ៍ថាគ្មានសុវត្ថិភាពពីទង្វើរបស់អ្នកជិតខាងខ្លួននោះឡើយ។ តែបន្ទាប់ពីព្យាការីមានវត្តមាន លោកក៏បានឱ្យតម្លៃ និងផ្តល់សេចក្តីថ្លៃថ្នូរដល់អ្នកជិតខាង ព្រមទាំងបានផ្តល់សិទ្ធិឱ្យពួកគេអាចរស់នៅក្នុងសហគមន៍ប្រកបដោយសុខសន្តិភាពផងដែរ។ ជាក់ស្តែងហាទីសខាងក្រោយនេះ បានបញ្ជាក់ពីតួនាទី និងសារៈសំខាន់នៃអ្នកជិតខាងជាខ្លាំងនៅក្នុងសាសនាអ៊ីស្លាម ដោយត្រូវមានភាពជិតស្និទ្ធ និងចាត់ទុកពួកគេដូចជាគ្រួសារយើងអ៊ីចឹងដែរ។ ព្យាការីបានមានប្រសាសន៍ថា៖

**ជីបរ៉ីល(កាព្រីយ៉ែល) បានណែនាំខ្ញុំជារឿយៗ ឱ្យប្រព្រឹត្តទៅចំពោះអ្នកជិតខាងដោយក្តីសប្បុរស និងក្តីអាណិតអាសូរ រហូតធ្វើឱ្យខ្ញុំគិតថា ជីបរ៉ីលនឹងបញ្ជាឱ្យខ្ញុំបែងចែកមរតកដល់អ្នកជិតខាងផងដែរ។**

*ហាទីស ពូខរី ៦០១៤ និង មូស្លីម ២៦២៤*

ជាងស្តែង មានតែសមាជិកគ្រួសារតែប៉ុណ្ណោះ ដែលនឹងមានសិទ្ធិទទួលបាននូវមរតក។ ទោះបីអ្នកជិតខាងគ្មានសិទ្ធិទទួលបានមរតកក៏ដោយ តែអ៊ីស្លាមបានជំរុញយើងឱ្យយកចិត្តទុកដាក់ធ្វើល្អចំពោះពួកគេ ប្រៀបដូចជាគ្រួសាររបស់យើងដូច្នោះដែរ។

ពិតប្រាកដណាស់ ព្យាការីលោកបានសង្កត់ធ្ងន់ទៅលើភាពជាអ្នកជិតខាង និងសិទ្ធិរបស់អ្នកពួកគេដែលត្រូវតែបំពេញឱ្យបានល្អ។

រ៉ស៊ូលុលឡោះ បានមានប្រសាសន៍ថា៖

**មិនមែនជាអ្នកដែលមានជំនឿពេញលេញលើខ្ញុំនោះឡើយ ចំពោះអ្នកដែលហូបឆ្អែត គេងលក់ស្រួល ខណៈពេលដែលគេដឹងថាអ្នកជិតខាងរបស់គេកំពុងតែឃ្លាន។**

*ហាទីស តប់រ៉នី ៧៥១*

ក្នុងហាទីសមួយផ្សេងទៀត រ៉ស៊ូលុលឡោះ បានមានប្រសាសន៍ថា៖

**អ្នកជិតខាងដែលល្អបំផុត គឺជាអ្នកដែលធ្វើល្អបំផុតចំពោះអ្នកជិតខាងរបស់គេ។**

*ហាទីស តៀរមីហ្ស៊ី ១៩៤៤*

ព្យាការីក៏ធ្លាប់ត្រូវបានគេសួរអំពីអំពើបាបដ៏ធំបំផុត លោកក៏បានឆ្លើយថា៖

**ក្នុងចំណោមអំពើបាបដ៏ធំបំផុត គឺការរួមដំណេក ដោយខុសច្បាប់ជាមួយភរិយារបស់អ្នកជិតខាង។**

*ហាទីស ពូខរី ៤៤៧៧ និង មូស្លីម ៨៦*

នៅក្នុងហាទីសមួយផ្សេងទៀត ព្យាការីបានមានប្រសាសន៍ថា៖

**ប្រសិនបើបុរសម្នាក់រួមដំណេកដោយខុសច្បាប់ជាមួយស្ត្រីដប់នាក់ នោះអំពើបាបរបស់គេ គឺនៅស្រាលជាងការរួមដំណេកដោយខុសច្បាប់ជាមួយនឹងភរិយារបស់អ្នកជិតខាងម្នាក់នោះទេ។**

*ហាទីស អះម៉ាត់ ២៣៨៥៤*

ហាទីសមួយនេះមិនបានបង្ហាញថាគ្មានបញ្ហា ឬអនុញ្ញាតឱ្យមានការរួមដំណេកដោយខុសច្បាប់នោះទេ។ ដរាបណា មិនមែនជាភរិយាស្របច្បាប់ គឺមិនត្រូវបានអនុញ្ញាតនោះឡើយ។ លើសពីនេះទៅទៀត ការប្រព្រឹត្តិនូវទង្វើបែបនេះជាបញ្ហាដ៏ធំ និងជាអំពើបាបដ៏ធ្ងន់ធ្ងរ ដោយវាបានបំផ្លាញនូវកិត្តិយស ទំនុកចិត្ត និងបំពានសិទ្ធិរបស់អ្នកដទៃជាខ្លាំង។ វាដូចជាការប្រមាថដល់វង្សត្រកូលរបស់អ្នកជិតខាង និងបង្កភាពខូចខាតដែលមិនអាចនឹងជួសជុលបានឡើយនៅក្នុងគ្រួសាររបស់គេ។ ជាការពិតណាស់ នៅក្នុងនាមជាអ្នកជិតខាង យើងគួរតែជាអ្នកការពារសុវត្ថិភាព រក្សានូវសន្តិភាព និងសេចក្តីថ្លៃថ្នូរដល់អ្នកជិតខាងរបស់យើង ដោយមិនត្រូវបំផ្លាញពួកគេឡើយ។

ព្យាការីធ្លាប់បានអះអាងថា ការរំខានដល់អ្នកជិតខាង និងធ្វើឱ្យពួកគេពិបាកមិនស្រណុកចិត្ត គឺជាសញ្ញាបញ្ជាក់ថា រូបគេមិនទាន់មានជំនឿពេញលេញនោះឡើយ។ ហើយវាក៏អាចជាឧបសគ្គដែលរារាំងពួកគេមិនឱ្យចូលឋានសួគ៌ ដែលជាកន្លែងដែលពោរពេញដោយសុភមង្គលបាននោះដែរ។

ព្យាការីក៏បានបញ្ជាក់យ៉ាងម៉ឺងម៉ាត់អំពីរឿងនេះដែរថា៖

**រូបគេមិនទាន់មានជំនឿពេញលេញនោះឡើយ! (លោកលើកឡើងបែបនេះ ចំនួន៣ដង) ប្រសិនបើអ្នកជិតខាងរបស់គេមានអារម្មណ៍ថា គ្មានសុវត្ថិភាពអំពីទង្វើអាក្រក់របស់គេទេនោះ។**

*ហាទីស ពូខរី ៦០៦១*

លោកក៏បានមានប្រសាសន៍ដែរថា៖

**អ្នកណាហើយដែលមានជំនឿចំពោះអល់ឡោះ ហើយនិងថ្ងៃបរលោក នោះគេមិនត្រូវបង្កគ្រោះថ្នាក់ដល់អ្នកជិតខាងរបស់គេនោះឡើយ។**

*ហាទីស ពូខរី ៦០១៨*

ពិតប្រាកដណាស់ ព្យាការីតែងតែប្រាស្រ័យទាក់ទងជាមួយអ្នកជិតខាងរបស់លោកយ៉ាងល្អ។ ហើយជារឿយៗ លោកបានលើកទឹកចិត្តដល់សហការីរបស់លោកឱ្យធ្វើល្អទៅចំពោះអ្នកជិតខាងដូចគ្នា។ ជាក់ស្តែង លោក អាប់ទុលឡោះ ពិន អាមៀរ ពិតជាបានអនុវត្តតាមដំបូន្មានរបស់ព្យាការី ដោយនៅពេលដែលគាត់សំឡេះចៀម គាត់នឹងបែកសាច់មួយចំណែកដល់អ្នកជិតខាងរបស់គាត់ ទោះបីជាអ្នកជិតខាងរបស់គាត់ជាជនជាតិយូដាក៏ដោយ។

ទោះបីមានតិចតួច ក៏ព្យាការីព្យាយាមចែករំលែកវាជាមួយអ្នកជិតខាងតាមដែលលោកអាចធ្វើទៅបាន។ លោកថែមទាំងបានណែនាំ អ្នកស្រី អាអ៊ីស្ហះ ឱ្យចែករំលែកដល់អ្នកជិតខាងដែលនៅជិតគ្នាបំផុត ប្រសិនបើគេមានតម្រូវការជាងគេ។

អ្នកស្រីអាអ៊ីស្ហះបានសួរព្យាការីថា៖

**ឱ រ៉សូលុលឡោះ! ខ្ញុំមានអ្នកជិតខាងពីរនាក់ ហើយខ្ញុំចង់ដឹងថា តើខ្ញុំគួរជូនអំណោយដល់ម្នាក់ណាមុនគេ? លោកបានតបថា៖ គឺជូនអ្នកដែលទ្វារផ្ទះរបស់គេនៅជិតផ្ទះរបស់យើងជាងគេ។**

*ហាទីស ពូខរី ២២៥៩*

ព្យាការីលោកក៏នឹងចម្អិនម្ហូបច្រើនបន្ថែម ដើម្បីបានចែកទៅដល់អ្នកជិតខាងរបស់លោកផងដែរ។ នៅក្នុងហាទីសមួយ រ៉ស៊ូលុលឡោះ បានមានប្រសាសន៍ទៅកាន់អាពូហ្សើរថា៖

**នៅពេលដែលអ្នកចម្អិនសម្ល ចូរអ្នកបន្ថែមទឹកឱ្យបាន**
**ច្រើនបន្តិចផង ដើម្បីបានចែកដល់អ្នកជិតខាងខ្លះ។**
*ហាទីស មូស្លីម ២៦២៥*

# ព្យាការីមូហាំម៉ាត់
# ក្នុងនាមជាឪពុក

រ៉ស៊ូលុលឡោះ គឺជាឪពុកគំរូម្នាក់ ដែលពោរពេញដោយសេចក្តីស្រលាញ់បំពោះកូន។ ទោះបីជាលោកមានការមមាញឹកនឹងការងារ និងទំនួលខុសត្រូវច្រើនលើសលប់ក៏ដោយ ក៏លោកមិនបណ្តោយឱ្យវាក្លាយជាឧបសគ្គ ក្នុងការបំពេញនូវតួនាទីជាឪពុកនោះឡើយ។

អាណាស ពិន ម៉ាលីគ បានរាយការណ៍ថា៖

**ខ្ញុំមិនដែលឃើញអ្នកណាមានចិត្តសប្បុរសជាងរ៉ស៊ូលុលឡោះឡើយ។ ពេលមួយ អ៊ីព្រហ៊ីម ដែលជាកូនប្រុសពៅរបស់ព្យាការី ត្រូវបានបញ្ជូនទៅជាយក្រុងម៉ាទីណះ ដើម្បីបំបៅដោះ ជាមួយនឹងម៉ែដោះនៅទីនោះ។ លោកធ្លាប់ទៅទីនោះ ហើយយើងក៏បានទៅជាមួយលោកដែរ។ លោកក៏បានដើរចូលទៅក្នុងផ្ទះម៉ែដោះរបស់អ៊ីព្រហ៊ីម ដែលនៅក្នុងផ្ទះនោះ ពោរពេញដោយផ្សែង ព្រោះតែស្វាមីរបស់ម៉ែដោះ អ៊ីព្រហ៊ីម ជាជាងដែក។ លោកបានលើកពអ៊ីព្រហ៊ីម ហើយថើបគេ បន្ទាប់មកក៏ត្រឡប់ទៅវិញ។**

*ហាទីស មូស្លីម ២៣១៦*

មានពេលមួយនោះ សហការីម្នាក់បានឃើញព្យាការីថើបចៅរបស់លោកហាសាន់ ហើយគាត់ក៏សួរព្យាការី ដោយការងឿងឆ្ងល់ថា តើអ្នកថើបចៅរបស់អ្នក? ហើយគាត់ក៏បានបន្តទៀតថា៖ ដោយអល់ឡោះជាម្ចាស់! ខ្ញុំមានកូនដប់នាក់ ប៉ុន្តែខ្ញុំមិនដែលថើបពួកគេនោះឡើយ។ ពេលឮដូច្នោះ ព្យាការីក៏បានទូន្មានដល់គាត់ ហើយលោកបានមានប្រសាសន៍ថា៖

**អ្នកណាហើយ ដែលគ្មានសេចក្តីមេត្តាករុណាដល់អ្នកដទៃ នោះរូបគេ ក៏នឹងមិនអាចទទួលបាននូវសេចក្តីមេត្តាករុណាពីអល់ឡោះនោះដែរ។**

*ហាទីស មូស្លីម ២៣១៨*

នេះហើយជាសេចក្តីស្រលាញ់របស់ព្យាការីចំពោះកូនៗ។ លោកធ្លាប់បានមានប្រសាសន៍អំពីកូនស្រីជាទីស្រលាញ់របស់លោកថា៖

**ហ្វាទីម៉ះ គឺជាផ្នែកមួយនៃខ្ញុំ អ្នកណាហើយដែលធ្វើឱ្យនាងខឹង ខ្ញុំក៏ខឹងដូចគ្នា។**

*ហាទីស ពូខរី ៣៧១៤*

សហការីម្នាក់ដែលមានឈ្មោះថា អាល់ប៉ារ៉ក បានរាយការណ៍ថា៖ ខ្ញុំបានឃើញព្យាការី ខណៈពេលដែលចៅប្រុសរបស់លោក ហាសាន់ ពិន អាលី នៅលើស្មារបស់លោកនោះ លោកក៏បានទូអាបួងសួងថា៖

**បពិត្រអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំពិតជាស្រលាញ់ចៅរបស់ខ្ញុំណាស់ ដូច្នេះសូមទ្រង់មេត្តាស្រលាញ់រូបគេ ព្រមទាំងអ្នកណាដែលស្រលាញ់រូបគេផង។**

*ហាទីស ពូខរី ៣៧៤៩ និង មូស្លីម ២៤២២*

ព្យាការីមិនមែនជាឪពុកដែលផ្តាច់ការ មិនផ្តល់ជម្រើសដល់កូនៗរបស់លោក ឬបង្ខំឱ្យពួកគេធ្វើតាមជម្រើសរបស់លោកនោះឡើយ។ ផ្ទុយទៅវិញ លោកនឹងណែនាំពួកគេប្រកបដោយប្រាជ្ញា និងសេចក្តីស្រលាញ់ ដែលវាពិតជាបានផ្តល់ឥទ្ធិពលវិជ្ជមានដល់ចរិតលក្ខណៈរបស់ពួកគេ មិនថាកូនៗរបស់លោកស្ថិតនៅក្នុងវ័យកុមារ ឬក៏ពេញវ័យនោះទេ។ ម៉្យាងវិញទៀត លោកនឹងមិនបណ្តោយឱ្យការស្រលាញ់របស់លោកចំពោះកូន ក្លាយជាមូលហេតុដែលធ្វើឱ្យកូនរបស់លោកបរាជ័យ នៅក្នុងភាពឯករាជ្យរបស់ពួកគេនោះទេ។ ព្យាការីបានអប់រំកូនរបស់លោក ឱ្យពួកគេមានទំនួលខុសត្រូវចំពោះសកម្មភាព និងការសម្រេចចិត្តរបស់ពួកគេ។ ពិតប្រាកដណាស់ លោកបានណែនាំទៅដល់ហ្វាទីម៉ះ កូនស្រីរបស់លោក

នៅក្នុងយុគសម័យមុនសាសនាអ៊ីស្លាមមកដល់ ដែលពេលនោះ នាងនៅក្មេងនៅឡើយនោះទេ ដោយលោកមានប្រសាសន៍ថា៖

**ឱ ហ្វាទីម៉ះ កូនស្រីពុក កូនអាចសុំអ្វីក៏បាន នូវទ្រព្យសម្បត្តិដែលពុកមាន តែទោះជាយ៉ាងណាក៏ដោយ កូនត្រូវដឹងថា ពុកមិនអាចជួយសង្គ្រោះកូន ពីការដាក់ទណ្ឌកម្មរបស់អល់ឡោះ នៅថ្ងៃបរលោកបាននោះឡើយ។**

*ហាទីស ពូខរី ២៧៥៣ និង មូស្លីម ២០៦*

ក្រោយមកទៀត ពេលដែលហ្វាទីម៉ះបានធំដឹងក្តី ហើយបានរៀបការ ពេលនោះនាងបានមករកឪពុករបស់នាង(ព្យាការី) ហើយក៏បានត្អូញត្អែរទៅកាន់លោក អំពីអារម្មណ៍នឿយហត់ ក្នុងការរៀបចំផ្ទះសំបែងរបស់នាង ហើយនាងបានសុំលោករកអ្នកបម្រើម្នាក់ សម្រាប់ជួយកិច្ចការផ្ទះនាង។ ដោយព្យាការីបានដឹងពីភាពលំបាករបស់នាង និងស្ថានភាពផ្នែកសេដ្ឋកិច្ចដែលនាងកំពុងតែប្រឈមនៅពេលនោះ លោកក៏បានណែនាំនាងឱ្យសូត្រ តាសពេហ្ស (ស៊ុបហា-នុលឡោះ ៣៣ ដង) (អាល់ហាំទូលិលឡា ៣៣ ដង ) និង អល់ឡហ៊ូអឹកពើរ ៣៤ ដង )មុនពេលចូលគេង និងបានប្រាប់កូនស្រីជាទីស្រលាញ់របស់លោកថា ការអនុវត្តបែបនេះនឹងផ្តល់ប្រយោជន៍ដល់នាងជាងអ្នកបម្រើទៅទៀត។

វាពិតជាមិនដូចឪពុកនាពេលបច្ចុប្បន្ននេះឡើយ ដែលអះអាងថាខ្លួនស្រលាញ់កូន តែក៏មិនបានណែនាំពួកគេទៅរកផ្លូវដែលអល់ឡោះស្រលាញ់នោះឡើយ។ ចំណែកឯព្យាការីយើងវិញ គឺលោកមិនដែលនឿយហត់អំពីការដាស់តឿនកូនចៅរបស់លោកឱ្យខិតខំស្វែងរកផ្លូវទៅកាន់ឋានសួគ៌នោះទេ។ ជារឿយៗលោកបានដាស់តឿនដល់កូនៗរបស់លោកថា៖

**ចូរសង្គ្រោះខ្លួនរបស់កូនពីភ្លើងនរករបស់អល់ឡោះ។**

*ហាទីស មូស្លីម ២០៤*

នៅក្នុងការគ្រប់គ្រងលើកិច្ចអាពាហ៍ពិពាហ៍កូនៗ ព្យាការីលោកបានផ្តល់អទិភាពដល់កូនប្រសារ ដែលមានតម្លៃសីលធម៌ល្អ ជាងអ្នកដែលមានទ្រព្យសម្បត្តិ និងឋានៈខ្ពង់ខ្ពស់នៅក្នុងសង្គម។ ជាក់ស្តែង សូម្បីតែមុនពេលលោកមិនទាន់ត្រូវបានតែងតាំងជាអ្នកនាំសាររបស់អល់ឡោះក៏ដោយ។ លោកបានរៀបការ ហៃរ្យណាប់ ជាមួយ អាពូអោស្ស ពិន អាល់រ៉ពៀក ដែលលោកជាបុរសមានសីលធម៌ល្អ ហើយក៏បានរៀបការ អ៊ុំមូ កាល់ហ្សូម ជាមួយ អូស្មាន ពិន អាហ្វាន ដែលជាមនុស្សដែលគេគ្រប់គ្នាស្គាល់ថា មានភាពសប្បុរស និងភាពអៀនខ្មាសជាខ្លាំង។ ក្រោយមកទៀត បន្ទាប់ពីសាសនាអ៊ីស្លាមបានមកដល់ លោកក៏បានរៀបការ ហ្វាទីម៉ះ ជាមួយនឹង អាលី ពិន អាពី តឡិប ដែលត្រូវបានគេស្គាល់ថាមានសីលធម៌ល្អ មានប្រាជ្ញា និងមានភាពក្លាហាន។ ព្យាការីបានដាស់តឿនប្រជាជាតិរបស់លោកថា៖

**នៅពេលដែលមាននរណាម្នាក់ដែលប្រកាន់ខ្ជាប់សាសនាបានល្អ និងមានចរិតលក្ខណៈល្អប្រពៃ ចូលស្តីដណ្តឹងកូនចៅរបស់ពួកអ្នក ចូរអ្នកទទួលយល់ព្រមចុះ ពុំដូច្នោះទេ វានឹងបង្កភាពចលាចល និងការមិនចុះសម្រុងគ្នាជាខ្លាំងមិនខានឡើយ។**

*ហាទីស តៀរម៊ីហ្ស៊ី ១០៨៤*

ជាការពិត លោកបានរៀបអាពាហ៍ពិពាហ៍ ហ្វាទីម៉ះ ជាមួយនឹង អាលី ដោយទទួលយកថ្លៃបណ្ណាការដ៏សាមញ្ញបំផុតពីគាត់ គឺត្រឹមឧបករណ៍ប្រើប្រាស់ដែលផលិតអំពីដែកតែប៉ុណ្ណោះ ដែលវាជាអ្វីដែលអាលីមាននៅពេលនោះ។

ព្យាការីក៏មិនដែលជ្រៀតជ្រែកក្នុងជីវិតអាពាហ៍ពិពាហ៍របស់កូនចៅនោះឡើយ នៅពេលណាដែលពួកគេមានជម្លោះនឹងគ្នា។ ផ្ទុយទៅវិញ លោកគ្រាន់តែណែនាំពួកគេ ហើយព្យាយាមបន្ធូរបន្ថយស្ថានការណ៍តែប៉ុណ្ណោះ។

មានពេលមួយ ព្យាការីបានមកដល់ផ្ទះរបស់ ហ្វាទីម៉ះ ហើយលោកមិនបានឃើញអាលីនៅទីនោះទេ។ ដូច្នេះហើយ លោកក៏បានសួររកកូនប្រសាររបស់

លោក។ បន្ទាប់មក ហ្វាទីម៉ះ បានប្រាប់លោកថា ពួកគេបានឈ្លោះគ្នា ដែលធ្វើឱ្យអាលីខឹង ដូច្នេះគាត់ក៏បេញពីផ្ទះ ហើយមិនបានត្រឡប់មកវិញទេនៅរសៀលនេះ។ ព្យាការីយល់ថា វាជារឿងធម្មតាសម្រាប់ជីវិតប្តីប្រពន្ធដែលតែងមានរឿងបែបនេះពេលខ្លះ។ ដូច្នេះហើយលោកបានព្យាយាមផ្សះផ្សាដល់អ្នកទាំងពីរ ដោយមិនបានសួរនាំ ជីកឫសគល់នៃបញ្ហាអ្វីទាំងអស់។

ដោយហេតុផលនៃជម្លោះវាអាចជារឿងរ៉ាវនៃភាគីទាំងសងខាង។ ហើយការដែលអាចស្តារស្ថានការណ៍ឱ្យប្រសើរឡើងវិញបាន ទើបជាគោលបំណងដែលសំខាន់បំផុត។ លោកបានបេញទៅរកអាលី ដែលកំពុងគេងនៅក្នុងវិហារ ខណៈដែលខ្លួនប្រាណរបស់គេប្រឡាក់ទៅដោយធូលី។ ដោយសារតែអាវរបស់លោកបានជ្រុះនៅពេលនោះ។ បន្ទាប់មក លោកបានហៅកូនប្រសារ ដោយប្រើពាក្យលេងសើចថា៖ ឱ បុរសដែលប្រឡាក់ធូលីដី! ក្រោកឡើងមកនេះ។ បន្ទាប់ពីពេលនោះមក ស្ថានភាពរបស់ហ្វាទីម៉ះ និង អាលី ក៏បានវិលមករកភាពប្រក្រតីវិញ។

មានពេលមួយ ហៃ្សណាប់ ដែលជាកូនស្រីរបស់លោក បានបញ្ជូនមនុស្សម្នាក់ទៅប្រាប់លោកថា៖ កូនរបស់នាងម្នាក់ទើបតែបានស្លាប់។ នៅពេលទទួលដំណឹងនោះ ព្យាការីក៏មានការសោកសៅយ៉ាងខ្លាំង បន្ទាប់មកលោកបានបញ្ជូនសហការីមួយចំនួនរបស់លោក ដើម្បីជួយក្នុងកិច្ចការបញ្ចុះសព និងជួយសម្រាលស្ថានការណ៍ដ៏សោកសៅរបស់នាង។ ហើយបានធ្វើការផ្ញើសាររំលែកទុក្ខ ដោយលោកមានប្រសាសន៍ថា៖

**ពិតប្រាកដណាស់ អ្វីទាំងអស់ជាគឺកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់! ទ្រង់ជាអ្នកដែលប្រទាន ហើយក៏ជាអ្នកដែលដកហូតវិញផងដែរ ហើយអ្វីៗទាំងអស់ គឺស្ថិតនៅក្នុងរយៈពេលដែលទ្រង់បានកំណត់យ៉ាងជាក់លាក់។ ដូច្នេះ ចូរអ្នកអត់ធ្មត់ និងសង្ឃឹមផលបុណ្យពីអល់ឡោះជាម្ចាស់ចុះ។ ក្រោយមកលោកបានទៅផ្ទះរបស់ហៃ្សណាប់ ហើយលោកបានបីត្រកងចៅរបស់លោកដោយខ្លួនឯងផ្ទាល់ និងជួយ**

កិច្ចការបញ្ចុះសពចៅរបស់លោក ខណៈពេលដែលទឹកភ្នែករបស់លោកក៏កំពុងហូរចុះ។ ពេលឃើញលោកស្រក់ទឹកភ្នែក សហការីម្នាក់បានសួរលោកថា៖ តើអ្នកកំពុងយំមែនទេ ឱ រ៉ស៊ូលុលឡោះ? ដោយសារគេប្រហែលជាជឿថាការយំ គឺជាសញ្ញានៃការដែលមិនបេះអត់ធ្មត់ទៅនឹងការកំណត់ទុក(ក៏ទ័រ ក៏ទើរ) ពីអល់ឡោះជាម្ចាស់។ បន្ទាប់មក លោកបានតបទៅកាន់សហការីថា ការយំមិនមែនជាសញ្ញាដែលបញ្ជាក់ថាគ្មានការអត់ធ្មត់ ឬមិនព្រមទទួលយកការពិតនៃការស្លាប់នោះឡើយ។ តែផ្ទុយទៅវិញ វាគឺជាសញ្ញានៃសេចក្តីស្រលាញ់ និងមេត្តាករុណាទៅវិញទេ។ លោកបានមានប្រសាសន៍ថា៖ នេះគឺជាសេចក្តីមេត្តាករុណា ដែលអល់ឡោះបានដាក់បំពេញនៅក្នុងដួងចិត្តអ្នកណាដែលទ្រង់មានបំណង។ ហើយអល់ឡោះនឹងមិនប្រទានសេចក្តីមេត្តាករុណារបស់ទ្រង់នោះឡើយ លើកលែងតែបំពោះអ្នកណាដែលគេមានសេចក្តីមេត្តាករុណាទៅចំពោះអ្នកផ្សេងផងឯទៀតតែប៉ុណ្ណោះ។

*ហាទីស ពូខរី ៥៦៥៥*

នេះហើយជាក្តីសេចក្តីស្រលាញ់ដែលគ្មានដែនកំណត់របស់ឪពុកដែលមានចំពោះកូន។ ឪពុកដែលតែងតែចែករំលែក នូវភាពរីករាយ ទុក្ខព្រួយ ជាំជួយដោះស្រាយបញ្ហា និងផ្តល់ការណែនាំដល់កូន ចំពោះអ្វីដែលពួកគេត្រូវការ ដោយគ្មានការព្រងើយកន្តើយនោះឡើយ។

ក្នុងនាមជាកូនៗ យើងពិតជាត្រូវការតួអង្គឪពុកបែបនេះនៅគ្រប់ទិដ្ឋភាពនៃជីវិតរបស់យើងជាខ្លាំង មិនថាជាពេលរីករាយ ឬសោកសៅនោះឡើយ។

# ប្រសិនបើយើង
# ចាននៅក្បែរលោក...

វែស៊ូលុលឡោះ គឺជាបុរសម្នាក់ដែលមានវង់ភក្ត្រស្រស់ស្អាតផូរផង់។ ពន្លឺដ៏ត្រចះត្រចង់នៃវង់ភក្ត្ររបស់លោក គឺប្រៀបដូចជាសម្រស់នៃពន្លឺព្រះច័ន្ទពេញបូណ៌មី។ លោកមានរាងកាយមាំមួន មានកំពស់ខ្ពស់ល្មម។ មានដើមទ្រូង និងស្មាធំទូលាយ និងមានស្បែកសម្បុរស្អាត មិនសូវសពេកទេ រាងក្រហមបន្តិច តែក៏មិនមែនជាពណ៌ខ្មៅទេ។ សក់របស់លោកមិនរួញ ក៏មិនត្រង់ភ្លឹងនោះដែរ។ ពេលខ្លះលោកទុកសក់របស់លោកដល់ត្រចៀក និងថ្ពាស ហើយពេលខ្លះទៀត ដល់ស្មារ។ សក់ និងពុកចង្ការរបស់លោក គឺមិនមានស្កូវច្រើននោះទេ ពោលគឺមិនដល់ម្ភៃសរសៃនោះទេ នៅពេលលោកលាចាកលោក។ ដំណើររបស់លោក មានជំហានវែងស្វាហាប់ ហើយមានស្ថេរភាព។ ជារឿយៗ សហការីរបស់លោក ត្រូវព្យាយាមដើរតាម ដើម្បីឱ្យទាន់លោក។ លោកជាមនុស្សដែលមានភាពអៀនខ្មាសជាខ្លាំង។

នៅពេលដែលលោកមិនចូលចិត្តអ្វីមួយ គឺគេអាចដឹងបាន ដោយការសង្កេតមើលលើការផ្លាស់ប្តូរទឹកមុខរបស់លោក។នៅពេលលោកថ្លែងសុន្ទរកថា គឺមានភាពស្ងប់ស្ងាត់ ទន់ភ្លន់ និងពន្យល់ពាក្យនីមួយៗ យ៉ាងច្បាស់លាស់ ងាយស្រួលយល់ និងចងចាំ។ លោកមិនប្រើពាក្យពេចន៍ដែលពិបាកយល់ ហើយលោកក៏មិនចេះប្រើពាក្យប្រមាថ ឬប្រើអណ្តាតជាកាំបិតមុតស្រួច ធ្វើឱ្យអ្នកដែលកំពុងស្តាប់មានការអាក់អន់ចិត្ត ឬឈឺចាប់នោះឡើយ។ ពេលខ្លះលោកមានប្រសាសន៍ឡើងវិញ៣ដង ដើម្បីឱ្យបានអ្នកស្តាប់បានយល់កាន់តែច្បាស់។

លោកជាមនុស្សម្នាក់ដែលតែងតែយកចិត្តទុកដាក់ខ្ពស់ចំពោះអនាម័យផ្ទាល់ខ្លួន ហើយតែងតែស្ថិតក្នុងស្ថានភាពមានទឹកវូឌូជានិច្ច។ អ្នកដែលចូលជិតលោកប្រាកដជានឹងធុំក្លិនក្រអូបឈ្ងុយឈ្ងប់នៃលោក ដូចដែល អាណាស ពិន ម៉ាលីគ បាននិយាយថា៖

**ហើយខ្ញុំមិនដែលធ្លាប់បានធុំក្លិនគ្រឿងក្រអូប ឬក្លិនទឹកអប់ឯណាដែលក្រអូបជាងក្លិនរបស់អ្នកនាំសាររបស់អល់ឡោះនោះឡើយ។**

*ហាទីស ពូខរី ១៩៧៣*

ជាការពិតណាស់ ក្លិនក្រអូបរបស់លោកនៅតែស្ថិតស្ថេរ ផ្លូវដែលលោកបានដើរនៅតែបន្សល់នូវខ្លិនក្រអូប ទោះបីជាលោកលែងមានវត្តមានជាយូរមកហើយក៏ដោយ។ អ្នកដែលមានឱកាសបានជួបលោក មិនថាអ្នកក្រ ឬអ្នកមានគឺតែងតែមានអារម្មណ៍ស្ងប់ និងស្រណុកក្នុងចិត្តជាមួយនឹងស្នាមញញឹមដ៏រីករាយ ក៏ដូចជាអាកប្បកិរិយាដ៏ប្រពៃរបស់លោក ក្នុងការគោរពមនុស្សចាស់ និងស្រលាញ់ក្មេងៗ។ នៅពេលណាដែលលោកនិយាយទៅកាន់អ្នកណាម្នាក់ លោកនឹងសម្លឹងមើលមុខម្នាក់នោះដោយកែវភ្នែកភ្លឺថ្លា ប្រកបដោយការយកចិត្តទុកដាក់ទាំងស្រុងចំពោះអ្វីដែលគេកំពុងតែនិយាយ ដែលធ្វើឱ្យគេមានអារម្មណ៍ថាត្រូវបានឱ្យតម្លៃ។ នៅពេលឱ្យសាឡាម(គារវកិច្ច) ហើយចាប់ដៃគ្នា លោកនឹងមិនលែងដៃរបស់គេឡើយ រហូតដល់អ្នកម្ខាងទៀតលែងដៃលោកជាមុនសិន។

ព្យាការីតែងតែធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នកដែលជួបលោកក្នុងលក្ខណៈដ៏រីករាយ។ អ្នកដែលធ្លាប់បានជួបលោកនឹងមានអារម្មណ៍ថាជិតស្និទ្ធបំផុតជាមួយលោក។

មានពេលមួយនោះ អាំមើរ ពិន អាល់អោស្ស បានជួបនិយាយជាមួយព្យាការី។ ដោយគាត់សង្ឃឹម ហើយនិងគិតថា គាត់នឹងក្លាយជាមនុស្សដែលជាទីស្រលាញ់បំផុតរបស់ព្យាការី។ ដោយលោកបានសួរទៅកាន់ព្យាការីថា៖

**តើអ្នកណាដែលជាមនុស្សជាទីស្រលាញ់បំផុតសម្រាប់លោក? លោកបានមានប្រសាសន៍ថា៖ អាអ៊ីស្ហះ។ គាត់ក៏បានសួរទៀតថា៖ ចុះក្នុងចំណោមបុរសវិញនោះ? លោកបានមានប្រសាសន៍ថា៖ ឪពុករបស់នាង (អាពូ ប៉ាកើរ)។ ខ្ញុំក៏បានបន្តសួរទៀតថា៖ ចុះបន្ទាប់មកទៀតនរណាគេ? លោកបានមានប្រសាសន៍ថា៖ អូមើរ ពិន ខុត្តប។ បន្ទាប់ពីព្យាការី បានរៀបរាប់ឈ្មោះមួយចំនួនខាងលើរួចមក គាត់ក៏សម្រេចចិត្តមិនធ្វើការសួរបន្តទៀតនោះទេ ដោយខ្លាចថាគាត់នឹងក្លាយជាមនុស្សចុងក្រោយ ដែលបានលើកឡើងដោយព្យាការី។**

*ហាទីស ពូខរី ៣៦៦២ និង មូស្លីម ២៣៨៤*

ពិតប្រាកដណាស់ មនុស្សជាច្រើនបានអះអាងថាពួកគេស្រលាញ់ រ៉ស៊ូ-លុលឡោះ។ ក៏ប៉ុន្តែពួកគេមិនបានបង្ហាញភស្តុតាងនៃសេចក្តីស្រលាញ់របស់ពួកគេចំពោះព្យាការី ដោយខិតខំអនុវត្តតាមមាគ៌ា(ស៊ុណ្ណះ)របស់លោកនោះឡើយនៅក្នុងជីវិតរស់នៅរបស់ពួកគេ។ ជាពិសេសសេចក្តីណែនាំរបស់លោកនៅក្នុងកិច្ចការសាសនា។

ពិតប្រាកដណាស់ មនុស្សជាច្រើនអះអាងថាពួកគេនឹករ៉ស៊ូលុលឡោះ និងចង់ជួបលោកជាខ្លាំង។ ប៉ុន្តែពួកគេមិនដែលស្រក់ទឹកភ្នែកដោយសារតែចង់ជួបលោកដូចជាម្តាយ ដែលយំនឹកកូននៅពេលដែលគេនៅឆ្ងាយនោះឡើយ។

បពិត្រអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាអនុញ្ញាតឱ្យពួកយើងជួបជាមួយនឹងអ្នកជាទីស្រលាញ់របស់ទ្រង់ (រ៉ស៊ូលុលឡោះ)ផង ទោះបីជាបានជួបក្នុងរយៈពេលខ្លីមួយនៅក្នុងសុបិនរបស់យើងនៅក្នុងលោកិយនេះក៏ដោយចុះ។

សូមទ្រង់មេត្តាប្រមូលផ្តុំពួកយើងនៅក្នុងថ្ងៃបរលោកជាមួយនឹងលោកសហាការីរបស់លោក ក្រុមមនុស្សដែលសុចរិត និងគួរឱ្យទុកចិត្តបំផុត ក៏ដូចជាទុក្ករ-បុគ្គល(អ្នកដែលស្លាប់ក្នុងបុព្វហេតុសាសនា) និងអ្នកទាំងឡាយដែលមានចិត្តបរិសុទ្ធជ្រះថ្លាផងចុះ។

ខ្ញុំគ្រាន់តែជាអ្នកម្ហូបម្នាក់ប៉ុណ្ណោះ !
ប្រសិនបើខ្ញុំធ្វើខុស ចូរអ្នកបន្ទោសលើរូបខ្ញុំចុះ តែសូមកុំបន្ទោសលើព្យាការី
មូហាំម៉ាត់អី ព្រោះលោកជាបុគ្គលដ៏ល្អឥតខ្ចោះ ប៉ុន្តែរូបខ្ញុំមិនបានល្អនោះទេ។

# ព្យាការី
# មូហាំម៉ាត់
## សូមសុខសន្តិភាពមានដល់លោក

ខ្ញុំជឿថាមានមនុស្សជាច្រើន ដែលធ្លាប់បានឮឈ្មោះបុរសម្នាក់នេះ តែភាគច្រើននៃអ្នកទាំងអស់នោះ ប្រហែលជាមិនទាន់បានស្គាល់អំពីបុរសម្នាក់នេះនៅឡើយទេ។ ជាពិសេសគឺអ្នកមូស្លីមតែម្តង ដែលអះអាងថា ខ្លួនស្រលាញ់លោក និងជាប្រជាជាតិរបស់លោក

តើបានស្គាល់លោកបានប៉ុនណាដែរហើយ ?